ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សៀវភៅ

# កម្រងព័ត៌មានសេវាសាធារណៈ

## ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា


អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ

ទូរស័ព្ទ ទូរសារ ៖ (៨៥៥) ២៣ ៧២ ៦០ ៨៦

គេហទំព័រ .www.mosvy.gov.kh

# អារម្ភកថា

កន្លងមក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានរៀបចំនូវឯកសារជាច្រើនដូចជា ផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ២០១៩-២០២៣ ផែនការសកម្មភាពអភិវឌ្ឍន៍កុមារ ផែនការជាតិស្តីពីពិការភាព និងឯកសារផ្សេងៗទៀត ដែលមានលក្ខណៈជាផែនការគោលនយោបាយ កម្មវិធី និងសេចក្តីណែនាំជាដើម។ កម្រងព័ត៌មានសេវាសាធារណៈ គឺជាឯកសារដ៏មានសារសំខាន់មួយទៀតរបស់ក្រសួង ជាឯកសារជំនួយស្មារតីនិងបណ្តុះនូវពុទ្ធិសម្រាប់អ្នកដឹកនាំ និងមន្ត្រីសង្គមកិច្ចគ្រប់លំដាប់ថ្នាក់ ដែលបំពេញតួនាទីក្នុងនាមជាអ្នកផ្តល់សេវាប្រកបដោយសមធម៌ យុត្តិធម៌ ប្រសិទ្ធភាព និងការទទួលខុសត្រូវ និងសម្រាប់អ្នកដែលមានតម្រូវការសេវាចាំបាច់ ក្នុងការស្វែងរកប្រភេទសេវា និងប្រភពនៃសេវា ដែលផ្តល់ដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ការរៀបចំតាក់តែងសៀវភៅនេះឡើងគឺទទួលបានធាតុចូលពីគ្រប់ផ្នែក និងអ្នកពាក់ព័ន្ធក្នុងការផ្តល់សេវា។

ឯកសារនេះ ឆ្លុះបញ្ចាំងអំពីប្រភេទសេវា បែបបទ នីតិវិធីនៃការផ្តល់ឬទទួលបានសេវា និងឯកសារគាំទ្រចាំបាច់នានាដើម្បីទទួលបានសេវាពីនីតិបុគ្គល ឬរូបវន្តបុគ្គល ជាអង្គភាព ឬមន្ត្រីរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

ក្នុងនាមក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះដៃគូអភិវឌ្ឍន៍ អង្គការជាតិ អន្តរជាតិ ឥស្សរជន និងសប្បុរសជននានា ដែលតែងតែជួយឧបត្ថម្ភគាំទ្រទាំងផ្នែកស្មារតី បច្ចេកទេស និងហិរញ្ញវត្ថុ រួមចំណែកធ្វើឲ្យវិស័យសង្គមកិច្ចមានការវិវត្តរីកចម្រើនគួរជាទីមោទនៈ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនកាន់តែប្រសើរឡើង។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាសង្ឃឹមយ៉ាងមុតមាំថា គ្រប់អង្គភាព និងអ្នកដែលមានចំណែកពាក់ព័ន្ធ អាចប្រើប្រាស់សៀវភៅនេះជាឯកសារជំនួយស្មារតីក្នុងការបំពេញការងារ និងជាផែនទីបង្ហាញផ្លូវសម្រាប់ស្វែងរកសេវា។

ថ្ងៃចន្ទ ១៤រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

**វង សូត**

## ០១. កម្មវិធីជំនួយសង្គ្រោះបន្ទាន់ដល់ជនរងគ្រោះដោយដាច់ស្បៀង ទីទ័លក្រ គ្រោះធម្មជាតិ និងគ្រោះមហន្តរាយដោយយថាហេតុនៅតាមសហគមន៍

| | |
|---|---|
| ឈ្មោះសេវា | កម្មវិធីជំនួយសង្គ្រោះបន្ទាន់ជនរងគ្រោះដោយដាច់ស្បៀង ទីទ័លក្រ គ្រោះធម្មជាតិ និងគ្រោះមហន្តរាយដោយយថាហេតុនៅតាមសហគមន៍ |
| ក្រសួង/ស្ថាប័នផ្តល់សេវា | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- អគ្គនាយកដ្ឋានបច្ចេកទេស<br>- នាយកដ្ឋានសុខុមាលភាពសង្គម<br>- ទូរស័ព្ទនាយកដ្ឋាន ៖ ០២៣ ២១២ ៦៧៣<br>- ការិយាល័យសង្គ្រោះសង្គម<br>- ទូរស័ព្ទការិយាល័យ ៖ ០១៥ ៣៨២ ៣៣៣<br>- អាសយដ្ឋាន អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ<br>- មន្ទីរ ស.អ.យ រាជធានី ខេត្ត |
| គោលបំណងនៃការផ្តល់សេវា | កម្មវិធីជំនួយសង្គ្រោះបន្ទាន់ជនរងគ្រោះដោយដាច់ស្បៀង ទីទ័លក្រ គ្រោះធម្មជាតិ និងគ្រោះមហន្តរាយដោយយថាហេតុនៅតាមសហគមន៍ ជាសេវាកម្មសាធារណៈរបស់ក្រសួង ស.អ.យ ត្រូវបានបង្កើតឡើងក្នុងគោលបំណងអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការជួយសម្រាលទុក្ខលំបាកក្នុងជីវភាពរស់នៅ និងកាត់បន្ថយភាពរងគ្រោះ និងងាយរងគ្រោះរបស់ប្រជាជនក្រីក្រនៅក្នុងសហគមន៍ |
| មូលដ្ឋានគតិយុត្ត | សារាចរណែនាំលេខ ០០២ ស.អ.យ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ ស្តីពីកម្មវិធីជំនួយសង្គ្រោះប្រជាជនរងគ្រោះដោយដាច់ស្បៀង ទីទ័លក្រ គ្រោះធម្មជាតិ គ្រោះមហន្តរាយជាយថាហេតុចំណាកស្រុក អនាថា និងវិកលចរិត នៅតាមសហគមន៍ ដោយមានភ្ជាប់គំរូឧបសម្ព័ន្ធលេខ ០១ ដល់លេខ ០៧ |
| អតិថិជនដែលមានសិទ្ធិទទួលសេវា | - ប្រជាជនជាជនរងគ្រោះដោយដាច់ស្បៀង ទីទ័លក្រ គ្រោះធម្មជាតិ និងគ្រោះមហន្តរាយដោយយថាហេតុនៅតាមសហគមន៍<br>- ជនចំណាកស្រុក ជនអនាថា និងជនវិកលចរិត |
| ស្តង់ដារសេវា | ប្រជាជនជាជនងាយរងគ្រោះដោយដាច់ស្បៀង ទីទ័លក្រ គ្រោះដោយធម្មជាតិ គ្រោះមហន្តរាយដោយយថាហេតុត្រូវបានជួយសង្គ្រោះតាមប្រភេទ និងកម្រិត ដូចខាងក្រោម ៖<br>**ប្រភេទ១ ៖ កម្រិតធ្ងន់**<br>- ប្រជាជនរងគ្រោះទីទ័លក្រដាច់ស្បៀងៈគ្មានមុខរបរគ្មានដីធ្លីដាំដុះ គ្មានជម្រកស្នាក់នៅឬមេគ្រួសារជាស្ត្រីមេម៉ាយមានកូនច្រើនក្នុងបន្ទុកពុំមានលទ្ធភាពឱ្យកូនទៅសិក្សាឬមេគ្រួសារជាជនពិការ ជនចាស់ជរា ជនមានជំងឺរ៉ាំរ៉ៃហើយមានក្មេងក្នុងបន្ទុកពុំមានលទ្ធភាពឱ្យក្មេងទៅសិក្សា។ ត្រូវពិនិត្យលទ្ធភាពផ្តល់ជំនួយគាំទ្រដោយគិតចំនួនសមាជិកគ្រួសារតាមជំហានដូចខាងក្រោម ៖<br>- ជំហានទី ១ ៖ ត្រូវផ្តល់ជំនួយសង្គ្រោះបន្ទាន់ ជាសម្ភារៈប្រើប្រាស់ ស្បៀងអាហារ និង |

| | |
|---|---|
| | ថវិកាមួយចំនួនដោយមិនលើសពីចំនួន ៥០០.០០០៛ក្នុងមួយគ្រួសារ និងផ្តល់ថវិកាមួយចំនួនតាមលទ្ធភាពជាក់ស្តែងសម្រាប់ទិញស្បៀងអាហារ និងសម្ភារ ដូចជា អង្ករ អំបិល មី មុង ភួយ ទឹកត្រី ទឹកស៊ីអ៊ីវ និងកៅស៊ូតង់។<br>- ជំហានទី ២ ៖ ត្រូវផ្តល់ជំនួយគាំទ្រសម្រាប់ការស្តារនីតិសម្បទា ដើម្បីជនរងគ្រោះមានស្ថិរភាពស្បៀងសម្រាប់ជីវភាពប្រចាំថ្ងៃក្នុងរយៈពេល ៣០ថ្ងៃ និងផ្តល់សម្ភារសម្រាប់ជួសជុលផ្ទះ ឬសាងសង់ជម្រកស្នាក់នៅបណ្តោះអាសន្នដោយគិតជាថវិកាមិនលើសពីចំនួន ១.៥០០.០០០៛ ក្នុងមួយគ្រួសារ។<br>**ប្រភេទ២ ៖ កម្រិតមធ្យម**<br>ជនរងគ្រោះទីទ័លក្រ ដាច់ស្បៀង ខូចខាតបាត់បង់ទ្រព្យសម្បត្តិផ្ទះសម្បែងប៉ះពាល់មុខរបរ ឬសុខភាព និងខូចខាតផលដំណាំ។ល។ ត្រូវពិនិត្យលទ្ធភាពគិតទៅតាមចំនួនសមាជិកគ្រួសារផ្តល់ជំនួយសង្គ្រោះបន្ទាន់ម្តងគត់ជាសម្ភារប្រើប្រាស់ ស្បៀងអាហារ និងថវិកាមួយចំនួនដោយមិនលើសពីចំនួន ៣០០.០០០៛ ក្នុងមួយគ្រួសារ និងផ្តល់ថវិកាមួយចំនួនតាមលទ្ធភាពជាក់ស្តែងសម្រាប់ទិញស្បៀងអាហារ និងសម្ភារ រួមមាន ៖ អង្ករ អំបិល មុង កន្ទេល ភួយ ទឹកត្រី ទឹកស៊ីអ៊ីវ និងកៅស៊ូតង់។<br>**ប្រភេទ៣ ៖ កម្រិតស្រាល**<br>ជនរងគ្រោះដែលទទួលនូវការខូចខាតបាត់បង់ទ្រព្យសម្បត្តិ ឬផលដំណាំតិចតួច។ល។ ត្រូវពិនិត្យលទ្ធភាពគិតទៅតាមចំនួនសមាជិកគ្រួសារ ផ្តល់ជំនួយសង្គ្រោះបន្ទាន់ម្តងគត់ ជាសម្ភារៈប្រើប្រាស់ ស្បៀងអាហារ និងថវិកាមួយចំនួនដោយមិនលើសពីចំនួន ២០០.០០០៛ ក្នុងមួយគ្រួសារ និងផ្តល់ថវិកាមួយចំនួនតាមលទ្ធភាពជាក់ស្តែងសម្រាប់ទិញស្បៀងអាហារ និងសម្ភារ រួមមាន ៖ អង្ករ អំបិល មី មុង កន្ទេល ភួយ ទឹកត្រី ទឹកស៊ីអ៊ីវ និងកៅស៊ូតង់។ |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | - សំណើរបស់ប្រធានមន្ទីរ ស.អ.យ រាជធានី ខេត្ត យោងតាមតារាងគំរូឧបសម្ព័ន្ធ<br>- សេចក្តីសម្រេចរបស់ក្រសួង ស.អ.យ |
| យោបល់ | ជំរុញការស្តារនីតិសម្បទា និងសមាហរណកម្មក្នុងសង្គមជាតិចូលរួមក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងទទួលផ្លែផ្កានៃការអភិវឌ្ឍប្រកបដោយសមធម៌។ លើកកម្ពស់សេវាសង្គមកិច្ច ឈានជាជំហានៗពីការផ្តល់ជំនួយសង្គ្រោះទៅជាការរៀបចំឱ្យមានប្រព័ន្ធសន្តិសុខសង្គម ការធានារ៉ាប់រងសង្គម ដើម្បីធានាសុខុមាលភាពសង្គមជូនប្រជាជនតាមលទ្ធភាពសេដ្ឋកិច្ចជាតិដោយចាត់ទុកជាយុទ្ធសាស្ត្រសំខាន់នៃគោលការណ៍បែងចែកភោគផលដោយសមធម៌ ។ |

## ០២. ការផ្តល់សេវាថែទាំ គាំទ្រដល់ជនផ្ទុកមេរោគអេដស៍ ជំងឺអេដស៍ និងរងផលប៉ះពាល់ដោយសារមេរោគអេដស៍ និងជំងឺកាចសាហាវផ្សេងៗនៅតាមសហគមន៍

| | |
|---|---|
| ឈ្មោះសេវា | ការផ្តល់សេវាថែទាំ គាំទ្រដល់ជនផ្ទុកមេរោគអេដស៍ ជំងឺអេដស៍និងរងផលប៉ះពាល់ដោយសារមេរោគអេដស៍ និងជំងឺកាចសាហាវផ្សេងៗ នៅតាមសហគមន៍ |
| ក្រសួង/ស្ថាប័នផ្តល់សេវា | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- អគ្គនាយកដ្ឋានបច្ចេកទេស<br>- នាយកដ្ឋានសុខុមាលភាពសង្គម<br>- ការិយាល័យសេវាការពារជនផ្ទុកមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗ<br>- ទូរស័ព្ទនាយកដ្ឋាន ៖ (៨៥៥) ២៣ ២១២ ៦៧៣<br>- ទូរស័ព្ទការិយាល័យ ៖ (៨៥៥ ១២ ៧៧៦ ៨៦០<br>- អ៊ីមែល ៖ mosvy_me@yahoo.com<br>- អាសយដ្ឋាន អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ<br>- មន្ទីរ ស.អ.យ រាជធានី ខេត្ត |
| គោលបំណងនៃការផ្តល់សេវា | - ដើម្បីទប់ស្កាត់ការរីករាលដាលដោយសារមេរោគអេដស៍ ជំងឺអេដស៍និងរងផលប៉ះពាល់ដោយមេរោគអេដស៍ ជំងឺអេដស៍និងជំងឺកាចសាហាវផ្សេងៗ និងជួយឱ្យជនរងគ្រោះនិងរងផលប៉ះពាល់ដោយសារមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗទទួលបាននូវសេវាថែទាំ និងគាំទ្រប្រកបដោយប្រសិទ្ធភាព។ |
| មូលដ្ឋានគតិយុត្ត | - អនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ឆ្នាំ២០០៦ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅមណ្ឌលរបស់រដ្ឋ<br>- ប្រកាសលេខ ១២២៨ ស.អ.យ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាព និងតួនាទី ភារកិច្ចរបស់ការងារថ្នាក់ជាតិពហុវិស័យស្តីពីកុមារកំព្រា និងកុមារងាយរងគ្រោះ<br>- ប្រកាសលេខ ០១០ ស.អ.យ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ ស្តីពីការចាត់តាំងក្រុមការងារដើម្បីអនុវត្តកម្មវិធីមូលនិធិសកលជុំទី៧<br>- ប្រកាសលេខ ១១៩ ស.អ.យ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- ប្រកាសលេខ ១៦៩១ ស.អ.យ. ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលសមាសភាពគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| អតិថិជនដែលមានសិទ្ធិទទួលសេវា | ជនរងគ្រោះ និងរងផលប៉ះពាល់ដោយសារមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗនៅតាមសហគមន៍ |

| | |
|---|---|
| ស្តង់ដារសេវា | ជនរងគ្រោះ និងរងផលប៉ះពាល់ដោយសារមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗនៅតាមសហគមន៍ត្រូវទទួលសេវាថែទាំ និងគាំទ្រដូចខាងក្រោម ៖<br>១-ទារក កុមារមានផ្ទុកមេរោគអេដស៍ ឬជំងឺអេដស៍ដែលស្នាក់នៅក្នុងមជ្ឈមណ្ឌលត្រូវទទួលរបបឧបត្ថម្ភដូចខាងក្រោមៈ<br>- ទារកអាយុ ២ឆ្នាំចុះ ទទួលរបបថ្លៃទឹកដោះគោ ក្នុង១ខែ ៦០.០០០៛ និងថ្លៃសំលៀកបំពាក់ សម្ភារដំណេក អនាម័យ និងព្យាបាល ១ដងក្នុង ១ឆ្នាំ ១២០.០០០៛ (ទទួលពេលដើមឆ្នាំ )<br>- កុមារអាយុលើសពី ២ឆ្នាំ ទទួលរបបឧបត្ថម្ភថ្លៃម្ហូបអាហារ ១ខែ ៤៥.០០០ ៛ ថ្លៃសំលៀកបំពាក់ សម្ភារសិក្សា កីឡា សម្ភារៈដំណេក ផ្ទះបាយ អនាម័យ និងព្យាបាល ១ដង ក្នុង១ឆ្នាំ ១២០.០០០៛(ទទួលពេលដើមឆ្នាំ)<br>- ទារក កុមារទទួលរបបប៉ប៉នសុខភាពបន្ថែមក្នុង ១ខែ ២០.០០០៛<br>- ទារក កុមារអាយុ ៥ឆ្នាំចុះ ទទួលមរណភាពឧបត្ថម្ភម្តងគត់ សម្រាប់រៀបចំពិធីបុណ្យសព ស្មើប្រាក់ម្ហូបអាហារ៦ខែ (២៧០.០០០៛)<br>- កុមារអាយុលើសពី ៥ឆ្នាំឡើង ទទួលមរណភាពឧបត្ថម្ភម្តងគត់សម្រាប់រៀបចំពិធីបុណ្យសព ស្មើប្រាក់ម្ហូបអាហារ ១២ខែ (៥៤០.០០០៛ )<br>២-កុមាររងផលប៉ះពាល់ដោយមេរោគអេដស៍ និងជំងឺអេដស៍ កុមារកំព្រា កុមារពិការធ្ងន់ធ្ងរមានជំងឺរ៉ាំរ៉ៃ ផ្ទុកមេរោគអេដស៍ ឬមានជំងឺអេដស៍ ជនពិការមានជំងឺអេដស៍ ជនពិការអនាថាមានជំងឺអេដស៍។ កុមារមានអាយុក្រោម ៥ឆ្នាំ គ្រួសារមានសមាជិករស់នៅជាមួយមេរោគអេដស៍ ឬទទួលផលប៉ះពាល់ដោយជំងឺអេដស៍ គ្រួសារដែលមានអាណាព្យាបាលជាមនុស្សចាស់ និងមិនអាចមានសមត្ថភាពធ្វើការងារ ឬគ្រួសារដែលមានកុមារជាមេគ្រួសារត្រូវទទួលកញ្ចប់ស្បៀងអាហារបន្ទាន់មាន ៖<br>○ អង្ករចំនួន ៣០ គីឡូក្រាម<br>○ ប្រេងឆា ចំនួន ១ លីត្រ<br>○ អំបិលអ៊ីយ៉ុត ចំនួន ១/២ គីឡូក្រាម<br>○ ប្រូតេអ៊ីនបន្ថែម (ស៊ុត សៀង សាច់ងៀត ឬត្រីខកំប៉ុង) |
| តម្រូវការឯកសារ<br>ដើម្បីទទួលបានសេវា | - ទម្រង់របាយការណ៍<br>- ទម្រង់ស្ថិតិជនរងគ្រោះ និងរងផលប៉ះពាល់ដោយសារមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗ<br>- ទម្រង់ទិន្នន័យជនរងគ្រោះ និងរងផលប៉ះពាល់ដោយសារមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗដែលទទួលបានសេវាថែទាំ និងគាំទ្រ<br>- សំណើរបស់ប្រធានមន្ទីរ ស.អ.យ រាជធានី ខេត្ត |
| យោបល់ | ដើម្បីឆ្លើយតបនឹងការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ ជំងឺអេដស៍ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ៖ |

| | |
|---|---|
| | - ត្រូវរៀបចំអនុក្រឹត្យ ស្តីពីការផ្តល់របបជំនួយឧបត្ថម្ភដល់ជនរងគ្រោះ និងរងផលប៉ះពាល់ដោយសារមេរោគអេដស៍ ជំងឺអេដស៍ ដែលទីទ័លក្រ គ្មានទីពឹង និងគ្មានជម្រក<br>- បង្កើតក្រុមការងារត្រួតពិនិត្យ តាមដាន និងវាយតម្លៃ<br>- សិក្សា ស្រាវជ្រាវពីបញ្ហាប្រឈម និងរកដំណោះស្រាយដែលសមស្របដល់ជនរងគ្រោះ និងរងផលប៉ះពាល់ដោយសារមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាចសាហាវ ផ្សេងៗ |

## ០៣. កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនដល់ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ

| ឈ្មោះសេវា | កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនដល់ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ |
|---|---|
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- អគ្គនាយកដ្ឋានបច្ចេកទេស<br>- នាយកដ្ឋានសុខុមាលភាពសង្គម<br>- ការិយាល័យកិច្ចការគ្រួសារ<br>- ការិយាល័យសង្គ្រោះសង្គម<br>- ទូរស័ព្ទនាយកដ្ឋាន ៖ (៨៥៥) ២៣ ២១២ ៦៧៣<br>- ទូរស័ព្ទការិយាល័យកិច្ចការគ្រួសារ ៖ (៨៥៥) ៨៩ ២៩០ ៩៨៨<br>- ទូរស័ព្ទការិយាល័យសង្គ្រោះសង្គម ៖ (៨៥៥) ១៥ ៣៨២ ៣៣៣<br>- អ៊ីមែល ៖ cheasomaly@gmail.com<br>- អាសយដ្ឋាន អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ<br>- មន្ទីរ ស.អ.យ រាជធានី ខេត្ត |
| គោលបំណង នៃការផ្តល់សេវា | - គោលបំណងរបស់កម្មវិធី ដើម្បីលើកកម្ពស់សុខុមាលភាពមាតា និងទារក ក្នុងការរួមចំណែកដោះស្រាយបញ្ហាកង្វះអាហារូបត្ថម្ភរបស់កុមារ ក្នុងគ្រួសារក្រីក្រ ចាប់តាំងកូនក្នុងផ្ទៃរហូតដល់អាយុ២ឆ្នាំ និងជំរុញការលូតលាស់ទាំងកាយសម្បទា និងបញ្ញាស្មារតី។<br>- រួមចំណែកកាត់បន្ថយអត្រាមរណភាពមាតា និងទារក |
| មូលដ្ឋានគតិយុត្ត | - អនុក្រឹត្យលេខ ២៤៥ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ |
| អតិថិជនដែលមាន សិទ្ធិទទួលសេវា | ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ដែលមានប័ណ្ណសមធម៌ ឬប័ណ្ណអាទិភាព |
| ស្តង់ដារសេវា | ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ដែលមានប័ណ្ណសមធម៌ ឬប័ណ្ណអាទិភាព បន្ទាប់ពីចុះឈ្មោះចូលកម្មវិធីអ្នកទទួលផលត្រូវអនុវត្តលក្ខខណ្ឌពិនិត្យសុខភាព ដើម្បីទទួលបានការឧបត្ថម្ភសាច់ប្រាក់ តាមដំណាក់កាលដូចខាងក្រោម៖<br>- ដំណាក់កាលទី១៖ ផ្តល់ការឧបត្ថម្ភចំនួន ៤០.០០០រៀល ក្នុង១ដង សម្រាប់ការមកទទួលសេវាពិនិត្យផ្ទៃពោះ ដែលផ្តល់ជាអតិបរមាចំនួន ៤ ដង មុនពេលសម្រាល<br>- ដំណាក់កាលទី២៖ ផ្តល់ការឧបត្ថម្ភចំនួន ២០០.០០០រៀល តែ១ដងគត់នៅពេលសម្រាល<br>- ដំណាក់កាលទី៣៖ ផ្តល់ការឧបត្ថម្ភចំនួន ៤០.០០០រៀល ក្នុង១ដង ដែលផ្តល់ជាអតិបរមា ចំនួន ១០ដង ក្នុងនោះ ៣ដង នៅពេលមកទទួលសេវាពិនិត្យផ្ទៃពោះ ក្រោយពេលសម្រាល និង៧ដងនៅពេល |

| | |
|---|---|
| | យកកូនមកទទួលថ្នាំបង្ការរហូតដល់អាយុ២ឆ្នាំ ។ |
| តម្រូវការឯកសារ ដើម្បីទទួលបានសេវា | - ប័ណ្ណសមធម៌ ឬប័ណ្ណអាទិភាព<br>- សៀវភៅសុខភាពមាតា<br>- ប័ណ្ណសុខភាពកុមារ |
| យោបល់ | - ត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលការអនុវត្តកម្មវិធី និងគ្រប់គ្រងស្ថិតិអ្នកទទួលផល និងបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ជូនរាជរដ្ឋាភិបាល<br>- បង្កើនការផ្សព្វផ្សាយពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនដល់ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ ដល់ប្រជាពលរដ្ឋនៅក្នុងសហគមន៍ ។ |

## ០៤. ការដោះស្រាយបញ្ហា ទប់ស្កាត់ និងការពារជនអនាថា

| | |
|---|---|
| ឈ្មោះសេវា | ការដោះស្រាយបញ្ហា ទប់ស្កាត់ និងការពារជនអនាថា |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- អគ្គនាយកដ្ឋានបច្ចេកទេស<br>- នាយកដ្ឋានសុខុមាលភាពសង្គម<br>- ការិយាល័យសេវាទប់ស្កាត់ និងការពារជនអនាថា<br>- អាសយដ្ឋាន អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ<br>- ទូរស័ព្ទនាយកដ្ឋាន ៖ ០២៣ ២១២ ៦៧៣<br>- ទូរស័ព្ទការិយាល័យ ៖ ០៨៨ ៧៣៨ ៥០០០<br>- អ៊ីមែល ៖ nguon.kosal@gmail.com<br>- មន្ទីរ ស.អ.យ រាជធានីខេត្ត |
| គោលបំណង នៃការផ្តល់សេវា | ផ្តល់ការស្នាក់នៅជាបណ្តោះអាសន្ន ហូបចុក ថែទាំសុខភាព ព្យាបាលជំងឺ អប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ធ្វើការបញ្ជូនបន្តទៅអង្គការដៃគូ និងសមាហរណកម្មទៅសហគមន៍វិញ។ |
| មូលដ្ឋានគតិយុត្ត | - អនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិដោះស្រាយបញ្ហាជនអនាថា<br>- អនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពីរបប គោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ<br>- អនុក្រឹត្យលេខ ៩០ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៧នៃអនុក្រឹត្យលេខ ១១៦ អនក្រ.បកចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពីរបប គោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ<br>- សេចក្តីណែនាំលេខ ០១ សណន.គជអ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០៦ស្តីពីការអនុវត្តផែនការសកម្មភាពដោះស្រាយបញ្ហាជនអនាថា<br>- ផែនការសកម្មភាពស្តីពីការដោះស្រាយបញ្ហាជនអនាថាលេខ ០១ គ.ជ.អ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៩<br>- កិច្ចព្រមព្រៀងលេខ ០០៦ គ.ជ.អ/ស.អ.យ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៥ ស្តីពីកិច្ចសហការប្រតិបត្តិការរវាងអនុគណៈកម្មាធិការដោះស្រាយបញ្ហាជនអនាថា (អ.គ.អ) រាជធានី ខេត្ត<br>- សេចក្តីសម្រេចស្តីពីការបង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍របស់គណៈកម្មាធិការជាតិដោះស្រាយបញ្ហាជនអនាថា<br>- ប្រកាសលេខ ៤៨២ ស.អ.យ ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការកែប្រែមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈពោធិ៍សែនជ័យ ទៅជាមណ្ឌលសំចតសង្គមកិច្ចរាជធានីភ្នំពេញ |

| | |
|---|---|
| | - សារាចរណែនាំលេខ ០០២ ស.អ.យ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ ស្តីពីកម្មវិធីជំនួយសង្គ្រោះបន្ទាន់ដល់ជនរងគ្រោះដោយដាច់ស្បៀង ទីទ័លក្រ គ្រោះធម្មជាតិ គ្រោះមហន្តរាយជាយថាហេតុ ចំណាកស្រុក អនាថា និងវិកលចរិតនៅតាមសហគមន៍ |
| អតិថិជនដែលមានសិទ្ធិទទួលសេវា | ជនរងគ្រោះដែលស្ម័គ្រចិត្តមកទទួលសេវា ៖<br>- ជនចាស់ជរា និងជនពិការគ្មានទីពឹង<br>- ជនអនាថា<br>- ជនវិកលចរិត<br>- ទុរគតជន<br>- ស្ត្រីកុមាររងគ្រោះដោយសារការជួញដូរផ្លូវភេទ និងពលកម្ម<br>- អ្នកប្រើប្រាស់សារធាតុញៀន<br>- ជនរងគ្រោះ និងងាយរងគ្រោះផ្សេងៗទៀត |
| ស្តង់ដារសេវា | ជនអនាថាទទួលបានរបបគោលនយោបាយស្នាក់នៅបណ្តុះបណ្តាលវិជ្ជាជីវៈ និងធ្វើសមាហរណកម្មទៅមូលដ្ឋានមានដូចខាងក្រោម ៖<br>**ប្រភេទ១ ៖**<br>- របបម្ហូបអាហារស្នាក់នៅក្នុងមជ្ឈមណ្ឌល ៥.០០០៛ ក្នុងម្នាក់ក្នុងមួយថ្ងៃ<br>- របបប៉ប៉នសុខភាពចំពោះជនអនាថាស្នាក់នៅក្នុងមជ្ឈមណ្ឌល ២០.០០០៛/ខែ<br>- របបសម្លៀកបំពាក់ចំពោះជនពិការ ជនអនាថា និងជនចាស់ជរាគ្មានទីពឹងស្នាក់នៅក្នុងមជ្ឈមណ្ឌល ១២០.០០០៛/ឆ្នាំ (ទទួលបាននៅដើមឆ្នាំ)<br>- របបបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈចំពោះជនពិការ ជនអនាថាដែលមានជំងឺអេដស៍ ៣៩០.០០០៛ ក្នុងមួយវគ្គ (រយៈពេល៣ខែ)<br>- របបរៀបចំពិធីបុណ្យសពជនអនាថា ជនពិការ និងចាស់ជរាគ្មានទីពឹង ស្នាក់នៅក្នុងមជ្ឈមណ្ឌលទទួលមរណភាព ៥៤០.០០០៛ (១ដងគត់)<br>- របបសមាហរណកម្មវិលទៅសហគមន៍វិញ ដើម្បីធ្វើទុនប្រកបមុខរបរកសាងជីវភាពគ្រួសារដោយខ្លួនឯង ៨១០.០០០៛ (១ដងគត់)<br>**ប្រភេទ២ ៖**<br>ជនរងគ្រោះ និងងាយរងគ្រោះ ចំណាកស្រុកដោយប្រថុយប្រថាន ត្រូវផ្តល់ជំនួយសង្គ្រោះបន្ទាន់ជាសម្ភារប្រើប្រាស់ និងស្បៀងអាហារ ដោយគិតជាថវិកាមិនលើសពីចំនួន ៣០០.០០០៛ក្នុងមួយគ្រួសារ និងផ្តល់ថវិកាមួយចំនួនតាមលទ្ធភាពជាក់ស្តែងសម្រាប់ទិញស្បៀងអាហារ និងសម្ភារ រួមមាន អង្ករ អំបិល មី មុង កន្ទេល ភួយ ទឹកត្រី និងទឹកស៊ីអ៊ីវ។<br>**ប្រភេទ៣ ៖**<br>ជនអនាថា ជាជនទីទ័លក្រ គ្មានទីជម្រក តែលតោលគ្មានទីពឹងស្នាក់នៅតាមទីសាធារណៈ តំបន់ទេសចរណ៍ ឬទីប្រជុំជននានា ក្នុងរាជធានី ខេត្ត ដោយធ្វើសកម្មភាពដើរសុំទានជូតកញ្ចក់រថយន្ត លក់ផ្កា ឬលក់កាសែតតាមស្តុបៗល។ ត្រូវពិនិត្យ ផ្តល់ជំនួយគាំទ្រ |

| | |
|---|---|
| | ពិគ្រោះយោបល់ និងជំនួយសង្គ្រោះបន្ទាន់ជាស្បៀងអាហារ និងមធ្យោបាយដោយគិតជាថវិកាមិនលើសពីចំនួន ៣០០.០០០៛ក្នុងមួយគ្រួសារ (ចំពោះជនអនាថាដែលយល់ព្រមធ្វើសមាហរណកម្មទៅក្នុងសហគមន៍)<br>**ប្រភេទ៤ ៖**<br>ជនវិកលចរិតជាជនដែលមានវិបត្តិផ្នែកអារម្មណ៍ និងការគិតដែលកើតឡើងជាប្រចាំ និងដើរអនាថា (គ្មានសាច់ញាតិថែទាំ) ត្រូវស្វែងរកសេវាគាំទ្រនានារួមទាំងការស្នាក់នៅ ហូបចុក និងសេវាសុខភាពគិតជាថវិកាមិនលើសពី ចំនួន ៣០០.០០០៛ ក្នុងមួយនាក់ និងថវិកាតាមលទ្ធភាពជាក់ស្តែង។ |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | - សំណើរបស់ប្រធានមជ្ឈមណ្ឌល ឬប្រធានមន្ទីរ ស.អ.យ រាជធានី ខេត្ត<br>- សេចក្តីសម្រេចរបស់ក្រសួង |
| យោបល់ | ការអនុវត្តផែនការសកម្មភាពដោះស្រាយបញ្ហាជនអនាថាក្នុងគោលបំណងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន អង្គការនានាដែលពាក់ព័ន្ធ ព្រមទាំងធ្វើការទប់ស្កាត់នូវលំហូរចូលនៃជនអនាថាមកទីក្រុង ឬទីប្រជុំជន និងឆ្លងដែនទៅប្រទេសជិតខាង។ ដូច្នេះក្រសួង ស.អ.យ មានតួនាទីជាសេនាធិការឱ្យរាជរដ្ឋាភិបាល និងមានភារកិច្ចដូចខាងក្រោម ៖<br>- បង្កើតឱ្យមានយុទ្ធសាស្ត្ររួមសម្រាប់ដោះស្រាយបញ្ហាជនអនាថា ដោយរួមបញ្ចូលការស្តារនីតិសម្បទា ការធ្វើសមាហរណកម្មទៅក្នុងសហគមន៍ និងបង្ការទប់ស្កាត់ការវិលត្រឡប់មកសុំទានវិញ<br>- ពង្រឹងពង្រីកបណ្តាញការងារសម្រាប់ជនអនាថានៅគ្រប់លំដាប់ថ្នាក់ ដើម្បីផ្តល់សេវាដល់ជនទាំងនោះឱ្យមានលំនឹងក្នុងការកសាងជីវភាពរស់នៅដោយខ្លួនឯង<br>- ផ្តល់ឱកាសឱ្យជនអនាថាមានជម្រកសុវត្ថិភាព ស្នាក់នៅបណ្តោះអាសន្ន ដើម្បីទទួលបានការផ្គត់ផ្គង់ជីវភាពការថែទាំសុខភាព ការអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈរយៈពេលខ្លី និងធ្វើការដឹកជញ្ជូនជនទាំងនោះឱ្យបានដល់មូលដ្ឋានគោលដៅរស់នៅអចិន្ត្រៃយ៍របស់គេ<br>- កសាងផែនការថវិកាប្រចាំឆ្នាំ សម្រាប់ចំណាយលើការងារសេវាដល់ជនអនាថាដោយបញ្ចូលក្នុងខ្ទង់ចំណាយថវិការបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងទំនាក់ទំនងស្វែងរកថវិកាពីប្រភពផ្សេងៗទៀត<br>- ត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលការអនុវត្តគោលការណ៍ផែនការកម្មវិធី និងគម្រោងនានា ព្រមទាំងគ្រប់គ្រងស្ថិតិ និងបូកសរុបលទ្ធផលការងារដោះស្រាយបញ្ហាជនអនាថាប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល |

## ០៥. ទទួលថែទាំ និងព្យាបាលជនវិបល្លាសស្មារតី

| | |
|---|---|
| ឈ្មោះសេវា | ទទួលថែទាំ និងព្យាបាលជនវិបល្លាសស្មារតី |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- អគ្គនាយកដ្ឋានបច្ចេកទេស<br>- នាយកដ្ឋានសុខុមាលភាពសង្គម<br>- ការិយាល័យសេវាទប់ស្កាត់ និងការពារជនអនាថា<br>- អាសយដ្ឋាន អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ<br>- ទូរស័ព្ទនាយកដ្ឋាន ៖ ០២៣ ២១២ ៦៧៣<br>- ទូរស័ព្ទការិយាល័យ ៖ ០៨៨ ៧៣៨ ៥០០០<br>- អ៊ីមែល ៖ nguon.kosal@gmail.com<br>- មន្ទីរ ស.អ.យ រាជធានី ខេត្ត |
| គោលបំណង នៃការផ្តល់សេវា | ផ្តល់ការស្នាក់នៅ ហូបចុក ថែទាំសុខភាព ព្យាបាលជំងឺ ស្តារនីតិសម្បទា និងធ្វើការសមាហរណកម្មទៅសហគមន៍វិញ។ |
| មូលដ្ឋានគតិយុត្ត | - អនុក្រឹត្យលេខ ៩០ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៧នៃអនុក្រឹត្យលេខ ១១៦ អនក្រ.បកចុះថ្ងៃទី២៦ តុលា ឆ្នាំ២០០៦ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ<br>- សំណើសុំគោលការណ៍បង្កើតមជ្ឈមណ្ឌលទទួលថែទាំ និងព្យាបាលជនវិបល្លាសស្មារតី |
| អតិថិជនដែលមាន សិទ្ធិទទួលសេវា | ជនរងគ្រោះដែលស្ម័គ្រចិត្តមកទទួលសេវា ៖<br>- ជនវិបល្លាសស្មារតី<br>- ជនអនាថាគ្មានទីពឹង |
| ស្តង់ដារសេវា | - ជនវិបល្លាសស្មារតីទទួលបានរបបគោលនយោបាយស្នាក់នៅ ព្យាបាល ស្តារនីតិសម្បទា និងធ្វើសមាហរណកម្មទៅសហគមន៍។<br>- ទទួលបានរបបគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការហូបចុកប្រចាំថ្ងៃ ៥,០០០ រៀល ក្នុងមួយនាក់ ក្នុងថ្ងៃ<br>- ការព្យាបាលដោយក្រុមគ្រូសារពេទ្យឯកទេសប្រចាំថ្ងៃ និងការពិនិត្យវាយតម្លៃ២ដងក្នុង១សប្តាហ៍ ការស្តារនីតិសម្បទាជាប្រចាំថ្ងៃតាមបែបបច្ចេកទេសវេជ្ជសាស្ត្រ និងសហគមន៍ |
| តម្រូវការឯកសារ ដើម្បីទទួលបានសេវា | - ឯកសារពិនិត្យបញ្ជាក់ និងបញ្ជូនពីអាជ្ញាធរ<br>- លិខិតវាយតម្លៃពីក្រុមគ្រូពេទ្យឯកទេសពីផ្នែកវិកលវិទ្យា<br>- ទម្រង់វាយតម្លៃរបស់មណ្ឌល |
| យោបល់ | ការអនុវត្តផែនការសកម្មភាពដោះស្រាយបញ្ហាជនអនាថាក្នុងគោលបំណងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន អង្គការនានាដែលពាក់ព័ន្ធ ព្រមទាំងធ្វើការទប់ស្កាត់នូវលំហូរចូលនៃជនអនាថាមកទីក្រុង ឬទីប្រជុំជន និងឆ្លងដែនទៅប្រទេសជិតខាង។ ដូច្នេះក្រសួង ស.អ.យ |

| | |
|---|---|
| | មានតួនាទីជាសេនាធិការឱ្យរាជរដ្ឋាភិបាល និងមានភារកិច្ចដូចខាងក្រោម ៖<br>- បង្កើតឱ្យមានយុទ្ធសាស្ត្ររួមសម្រាប់ដោះស្រាយបញ្ហាជនអនាថា ដោយរួមបញ្ចូលការស្តារនីតិសម្បទា ការធ្វើសមាហរណកម្មទៅក្នុងសហគមន៍ និងបង្ការទប់ស្កាត់ការវិលត្រឡប់មកសុំទានវិញ<br>- ពង្រឹងពង្រីកបណ្តាញការងារសម្រាប់ជនអនាថានៅគ្រប់លំដាប់ថ្នាក់ ដើម្បីផ្តល់សេវាដល់ជនទាំងនោះឱ្យមានលំនឹងក្នុងការកសាងជីវភាពរស់នៅដោយខ្លួនឯង<br>- ផ្តល់ឱកាសឱ្យជនអនាថាមានជម្រកសុវត្ថិភាព ស្នាក់នៅបណ្តោះអាសន្ន ដើម្បីទទួលបានការផ្គត់ផ្គង់ជីវភាពការថែទាំសុខភាព ការអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈរយៈពេលខ្លី និងធ្វើការដឹកជញ្ជូនជនទាំងនោះឱ្យបានដល់មូលដ្ឋានគោលដៅរស់នៅអចិន្ត្រៃយ៍របស់គេ<br>- កសាងផែនការថវិកាប្រចាំឆ្នាំសម្រាប់ចំណាយលើការងារសេវាដល់ជនអនាថាដោយបញ្ចូលក្នុងខ្ទង់ចំណាយថវិការបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងទំនាក់ទំនងស្វែងរកថវិកាពីប្រភពផ្សេងៗទៀត<br>- ត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលការអនុវត្តគោលការណ៍ផែនការកម្មវិធី និងគម្រោងនានាព្រមទាំងគ្រប់គ្រងស្ថិតិ និងបូកសរុបលទ្ធផលការងារដោះស្រាយបញ្ហាជនអនាថាប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល |

## ០៦. សេវាស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ

| | |
|---|---|
| ឈ្មោះសេវា | សេវាស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | - ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- អគ្គនាយកដ្ឋានបច្ចេកទេស<br>- នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ<br>- អាសយដ្ឋាន អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ<br>- ទូរស័ព្ទ ៖ ០២៣ ២១៣ ០៤៤<br>៖ ០១២ ៨០៤ ៧៤៨<br>- មជ្ឈមណ្ឌលសំចតប៉ោយប៉ែត<br>○ អាសយដ្ឋាន ផ្លូវ សុខភាព ផ្ទះលេខ ១២ ភូមិ បាលិលេយ្យ២ សង្កាត់/ក្រុង ប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ<br>○ ទូរស័ព្ទ ៖ ០៥៤ ៩៦៧១៤១<br>៖ ០១២ ៧២៥០៥៧<br>○ អ៊ីមែល ៖ chramanith@gmail.com<br>- មន្ទីរ ស.អ.យ រាជធានី ខេត្ត |
| គោលបំណង នៃការផ្តល់សេវា | ជួយសង្គ្រោះដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សឱ្យទទួលបាននូវការស្នាក់នៅ ការអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងធ្វើសមាហរណកម្មទៅសហគមន៍ |
| មូលដ្ឋានគតិយុត្ត | - អនុក្រឹត្យលេខ ៩០ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា ៧ នៃអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពីបេបគោលនយោបាយចំពោះជនរងគ្រោះថ្នាក់នៅក្នុងមណ្ឌលរដ្ឋ<br>- អនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពីបេបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ<br>- ប្រកាសលេខ ២១៧៨ ស.អ.យ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥ ស្តីពីការដាក់ឱ្យអនុវត្តឧបករណ៍ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ និងបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស<br>- ប្រកាសលេខ ១២៧៤ ស.អ.យ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៤ ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើសមាហរណកម្មផ្លូវភេទដែលស្នាក់នៅក្នុងមជ្ឈមណ្ឌល<br>- នីតិវិធីប្រតិបត្តិបទដ្ឋានស្តីពីការផ្តល់ការគាំទ្រផ្នែកសមាហរណកម្មដល់ជនរងគ្រោះជាបុរសដោយអំពើជួញដូរមនុស្ស ខែឧសភា ឆ្នាំ២០១២<br>- ឯកសារណែនាំស្តីពីនីតិវិធីប្រគល់ និងទទួលជនរងគ្រោះដោយសារការជួញដូរមនុស្សរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណៈរដ្ឋសង្គមនិយមវៀតណាម ខែធ្នូ ឆ្នាំ២០១០ |

| | |
|---|---|
| | - សារាចរណែនាំលេខ ០០៩ ស.អ.យ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការងារសមាហរណកម្ម និងតាមដានក្រុមជនរងគ្រោះដែលបានស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ និងអង្គការដែលមិនមែនរដ្ឋាភិបាល<br>- ប្រកាសលេខ ៨៥២ ស.អ.យ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩ លើគោលនយោបាយ និងបទដ្ឋាអប្បបរមា ស្តីពីកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស<br>- សៀវភៅបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទដែលស្នាក់នៅក្នុងមជ្ឈមណ្ឌល ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៤ ដោយរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- អនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- ប្រកាសលេខ ២០៨១ស.អ.យ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យស្ថិតក្រោមនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ<br>- ប្រកាសលេខ ១២៨ ស.អ.យ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតមជ្ឈមណ្ឌលសំចតប៉ោយប៉ែត |
| អតិថិជនដែលមានសិទ្ធិទទួលសេវា | ជនរងគ្រោះដោយសារការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ |
| ស្តង់ដារសេវា | ជនរងគ្រោះដោយអំពើជួញដូរមនុស្សបានទទួលការថែទាំ របបស្នាក់នៅ វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ និងធ្វើសមាហរណកម្មទៅសហគមន៍ដូចខាងក្រោម ៖<br>- របបម្ហូបអាហារ ស្នាក់នៅក្នុងមជ្ឈមណ្ឌល ១៥០.០០០៛/ខែ (រយៈពេល ០៣ខែ)<br>- របបសម្លៀកបំពាក់ សម្ភារៈសិក្សា កីឡា សម្ភារៈដំណេក ផ្ទះបាយ អនាម័យ និងព្យាបាល ១២០.០០០៛ (ទទួលពេលដើមឆ្នាំ)<br>- របប១វគ្គបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈ សម្រាប់រយៈពេលខ្លី ៣ខែ ទទួលបាន ៣៩០.០០០៛ ក្នុងមួយវគ្គ<br>- របបសមាហរណកម្មវិលទៅសហគមន៍វិញ ដើម្បីធ្វើទុនប្រកបមុខរបរ កសាងជីវភាពគ្រួសារដោយខ្លួនឯង ៨១០.០០០៛ (១ដងគត់) |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | - សំណើរបស់ប្រធានមជ្ឈមណ្ឌល ឬប្រធានមន្ទីរ ស.អ.យ រាជធានី ខេត្ត<br>- សេចក្តីសម្រេចរបស់ក្រសួង ស.អ.យ |
| យោបល់ | ការអនុវត្តផែនការសកម្មភាពប្រយុទ្ធប្រឆាំងនិងអំពើជួញដូរមនុស្សក្នុងគោលបំណងការពារស្តារនីតិសម្បទា និងសមាហរណកម្មជនរងគ្រោះត្រឡប់ទៅសហគមន៍វិញដូច្នេះក្រសួង ស.អ.យ ជាសេនាធិការឱ្យរាជរដ្ឋាភិបាល និងមានភារកិច្ចដូចខាងក្រោម ៖<br>- បង្កើតផែនការសកម្មភាពសម្រាប់ប្រយុទ្ធប្រឆាំងនិងអំពើជួញដូរមនុស្សដោយក្នុងនោះរួមបញ្ចូលទាំងការផ្តល់ជម្រក ការស្តារនីតិសម្បទា ការធ្វើសមាហរណកម្ម និងមាតុភូមិ |

| | |
|---|---|
| | និវត្តន៍ និងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស<br>- កសាងផែនការថវិកាប្រចាំឆ្នាំសម្រាប់ការចំណាយលើការផ្តល់សេវាដល់ជនរងគ្រោះ ដោយបញ្ចូលក្នុងខ្ទង់ចំណាយថវិការបស់ក្រសួង ស.អ.យ និងទំនាក់ទំនងស្វែងរកថវិកាពីប្រភពផ្សេងៗ<br>- ត្រួតពិនិត្យ និងវាយតម្លៃលើលទ្ធផលការអនុវត្តផែនការកម្មវិធី និងគម្រោងនានា គ្រប់គ្រងទិន្នន័យ និងបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល |

## ០៧. មាតុភូមិនិវត្ត ស្តារនីតិសម្បទា និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ច និងទម្រង់ផ្សេងៗទៀតនៃការរំលោភបំពាន

| | |
|---|---|
| ឈ្មោះសេវា | មាតុភូមិនិវត្ត ស្តារនីតិសម្បទា និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ច និងទម្រង់ផ្សេងៗទៀតនៃការរំលោភបំពាន |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | - ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ<br>o អាសយដ្ឋាន អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ<br>o ទូរស័ព្ទ ៖ (៨៥៥) ២៣ ៧២ ៦០ ៨៦ |
| គោលបំណង នៃការផ្តល់សេវា | ➢ **ការធ្វើមាតុភូមិនិវត្ត(ការទទួល និងបញ្ជូន)ដោយអំពើជួញដូរមនុស្សអំពើធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ច និងទម្រង់ផ្សេងៗទៀតនៃការរំលោភបំពាន**<br>– ប្រសិទ្ធភាពក្នុងការទទួលជនរងគ្រោះ ក្រោយពីអន្តរាគមន៍រិបត្តិ<br>– ប្រសិទ្ធភាពក្នុងការធ្វើមាតុភូមិនិវត្តជនរងគ្រោះ ទៅប្រទេសកំណើតវិញ<br>➢ **ស្តារនីតិសម្បទាដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ច និងទម្រង់ផ្សេងៗទៀតនៃការរំលោភបំពាន**<br>– ប្រសិទ្ធភាពក្នុងការផ្តល់សេវាផ្នែកវេជ្ជសាស្ត្រ<br>– ប្រសិទ្ធភាពក្នុងការប្រឹក្សាយោបល់ និងព្យាបាលផ្លូវចិត្តដល់ជនរងគ្រោះ<br>– ប្រសិទ្ធភាពក្នុងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ<br>– ប្រសិទ្ធភាពក្នុងការផ្តល់សេវាផ្នែកច្បាប់<br>– ប្រសិទ្ធភាពក្នុងការពង្រឹងសេដ្ឋកិច្ច<br>➢ **សមាហរណកម្មជនរងគ្រោះទៅសហគមន៍ដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ច និងទម្រង់ផ្សេងៗទៀតនៃការរំលោភបំពាន**<br>– ប្រសិទ្ធភាពក្នុងការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះ<br>– ប្រសិទ្ធភាពក្នុងការជួយដល់ជនរងគ្រោះមិនឱ្យធ្លាក់ខ្លួនសារជាថ្មី<br>– ប្រសិទ្ធភាពក្នុងការផ្តល់នូវសេចក្តីសង្ឃឹម និងបំណិនជីវិតដល់ជនរងគ្រោះ<br>– ប្រសិទ្ធភាពក្នុងការជួយដល់ជនរងគ្រោះ ឱ្យក្លាយជាសមាជិកថ្មី រស់នៅក្នុងសហគមន៍<br>– ប្រសិទ្ធភាពក្នុងការជួយបង្កើនភាពនឹងនរផ្លូវកាយ ផ្លូវចិត្ត ផ្លូវអារម្មណ៍<br>–ប្រសិទ្ធភាពក្នុងការជួយដល់ជនរងគ្រោះ ដើម្បីទំនាក់ទំនងជាមួយគ្រួសារ និងសហគមន៍សារជាថ្មី |
| មូលដ្ឋានគតិយុត្ត | - ច្បាប់ស្តីពីការបង្ក្រាប អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ<br>- ឯកសារណែនាំស្តីពីនីតិវិធីប្រគល់ និងទទួល ជនរងគ្រោះដោយសារការជួញដូរមនុស្ស រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណៈរដ្ឋសង្គមនិយមវៀតណាម ខែធ្នូ ឆ្នាំ២០១០<br>- នីតិវិធីប្រតិបត្តិបទដ្ឋានស្តីពីការគ្រប់គ្រងករណីនៃការធ្វើមាតុភូមិនិវត្ត និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ |

| | |
|---|---|
| | ឆ្នាំ២០១៩<br>- គោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ឆ្នាំ២០០៩<br>- បទដ្ឋានអប្បបរមាសម្រាប់ការថែទាំជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលស្នាក់នៅក្នុងមជ្ឈមណ្ឌល ឆ្នាំ២០១៤<br>- សារាចរណែនាំលេខ ០០៩ ស.អ.យ ស្តីពីការងារសមាហរណកម្ម និងតាមដានក្រុមជនរងគ្រោះដែលបានស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាល ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០៧<br>- សេចក្តីសម្រេចលេខ១០៧ ស្តីពីគោលការណ៍ការពារសិទ្ធិជនរងគ្រោះដោយសារការជួញដូរនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៧<br>- គោលការណ៍ណែនាំស្តីពីការអនុវត្តច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨<br>- សេចក្តីណែនាំស្តីពីការអនុវត្តកិច្ចប្រតិបត្តិការសង្គ្រោះជនរងគ្រោះដោយអំពើជួញដូរមនុស្ស និង/ឬការធ្វើអាជីវកម្មផ្លូវភេទ នៅតាមបណ្តាទីតាំងដែលបានកំណត់ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ ២០១០<br>- គោលការណ៍ណែនាំស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប |
| អតិថិជនដែលមានសិទ្ធិទទួលសេវា | រូបវន្តបុគ្គល (ជនរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ច និងទម្រង់ផ្សេងៗទៀតនៃការរំលោភបំពាន) |
| ស្តង់ដារសេវា | - ការស្នាក់នៅក្នុងមជ្ឈមណ្ឌលរយៈពេលខ្លីសមាហរណកម្មទៅគ្រួសារ សហគមន៍ និងមណ្ឌល<br>- ការស្នាក់នៅក្នុងមជ្ឈមណ្ឌលរយៈពេលវែង(ស្តារនីតិសម្បទា) |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | ❖ រូបវន្តបុគ្គល(ជនរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ច និងទម្រង់ផ្សេងៗទៀតនៃការរំលោភបំពាន)<br>- ទម្រង់សម្ភាសន៍ និងកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស<br>- លិខិតបញ្ជូន<br>- ទម្រង់ទទួលនិងស្វែងរកគ្រួសារ<br>- ទម្រង់ផែនការករណី<br>- ទម្រង់ប៉ាន់ប្រមាណ<br>- ទម្រង់សមាហរណកម្ម<br>- ទម្រង់ព័ត៌មានត្រឡប់<br>- ទម្រង់តាមដាន និង<br>- ទម្រង់បិទករណី |
| យោបល់ | |

## ០៨. សេវាថែទាំជំនួសចំពោះកុមារ

| | |
|---|---|
| ឈ្មោះសេវា | សេវាថែទាំជំនួសចំពោះកុមារ |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- អគ្គនាយកដ្ឋានបច្ចេកទេស<br>- នាយកដ្ឋានសុខុមាលភាពកុមារ<br>- អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ សង្កាត់បឹងត្របែក ខណ្ឌចំការមន |
| គោលបំណង នៃការផ្តល់សេវា | ផ្តល់កិច្ចការពារ និងផ្តល់សេវាចំពោះកុមារដែលរស់ក្នុងស្ថានភាពងាយរងគ្រោះមួយ ឬច្រើនប្រភេទដែលត្រូវចាត់ទុកជាប្រភេទកុមារកិច្ចការពារពិសេស ឬកុមារប្រឈមនឹងគ្រោះថ្នាក់ |
| មូលដ្ឋានគតិយុត្ត | - គោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ<br>- បទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារ<br>- នីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ<br>- សៀវភៅបទដ្ឋាន និងគោលការណ៍ណែនាំសម្រាប់ការថែទាំ ការគាំទ្រសម្រាប់កុមារកំព្រា និងកុមារងាយរងគ្រោះដទៃទៀត<br>- អនុក្រឹត្យលេខ១១៩អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ<br>- អនុក្រឹត្យលេខ ៣៤ អនក្រ.បក ស្តីពីការប្រគល់មុខងារការប្រគល់គ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ការប្រគល់មុខងារការត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាលទៅឱ្យរដ្ឋបាលរាជធានី ក្រុង ស្រុក និងការប្រគល់មុខងារការគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងសហគមន៍ទៅឱ្យរដ្ឋបាលរាជធានី ក្រុង និងឃុំ<br>- អនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅមជ្ឈមណ្ឌលរបស់រដ្ឋ<br>- អនុក្រឹត្យលេខ ៩០ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៧នៃអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ<br>- គោលការណ៍ណែនាំស្តីពីសមត្ថភាពមូលដ្ឋានសម្រាប់កម្លាំងសេវាសង្គមនៅកម្ពុជា |
| អតិថិជនដែលមាន សិទ្ធិទទួលសេវា | កុមារដែលរស់នៅក្នុងមណ្ឌលរបស់រដ្ឋ និងកុមារដែលបានធ្វើសមាហរណកម្មទៅរស់នៅក្នុងគ្រួសារ និងសហគមន៍មានដូចជា ៖ ១. កុមារកំព្រា ២. កុមារដែលត្រូវបានបោះបង់ចោលតាមមន្ទីរពេទ្យ និងទីសាធារណៈ ៣. កុមារដែលទទួលផលប៉ះពាល់ ឬផ្ទុកមេរោគអេដស៍ និងមានជំងឺអេដស៍ ៤. កុមារដែលទទួលរងរំលោភផ្លូវភេទ រូបរាងកាយ ផ្លូវចិត្ត ៥.កុមារអនាថាតាមចិញ្ចើមថ្នល់ ៦. កុមារមានទំនាស់ជាមួយច្បាប់ ៧. កុមារដែលរងគ្រោះដោយអំពើកេងប្រវ័ញ្ចផ្លូវភេទ ឬទម្រង់ពលកម្មប្រកបដោយគ្រោះថ្នាក់ ៨. កុមារដែលមានពិការភាព ៩. កុមារញៀន |

| | |
|---|---|
| | សារជាតុញៀន ១០. កុមារដែលមិនបានទទួលនូវតម្រូវការផ្នែករូបវន្តជាមូលដ្ឋាន ១១. កុមាររងអំពើហិង្សាក្នុងគ្រួសារ ១២. ការថែទាំកុមារនៅតាមគ្រួសារ គ្រួសារសាច់ញាតិ គ្រួសារធម៌ និងផែនការអចិន្ត្រៃយ៍ ១៣. ការថែទាំនៅតាមវត្តអារាមព្រះពុទ្ធសាសនា និងទីកន្លែងសាសនានានា ១៤.ការថែទាំកុមារតាមមណ្ឌលថែទាំកុមារ ១៦. ការថែទាំកុមារនៅតាមផ្ទះជាក្រុម |
| ស្តង់ដារសេវា | - កុមារកំព្រាដែលស្នាក់នៅមណ្ឌលថែទាំរបស់រដ្ឋ ក្នុងមួយនាក់ទទួលបានរបបគោលនយោបាយ (ប្រាំពាន់រៀល) ក្នុងមួយថ្ងៃ ស្មើនឹង (ដប់ប្រាំម៉ឺនរៀល) ក្នុងមួយខែ<br>- កុមារកំព្រាដែលស្នាក់នៅក្នុងមណ្ឌលថែទាំរបស់រដ្ឋ មានអាយុ១៨ឆ្នាំ ត្រូវធ្វើសមាហរណកម្មទៅរស់នៅក្នុងគ្រួសារ និងសហគមន៍ ក្នុងម្នាក់ទទួលបានរបបគោលនយោបាយ ១.០៨០.០០០ រៀល<br>- កុមារកំព្រាដែលស្នាក់នៅក្នុងមណ្ឌលថែទាំរបស់រដ្ឋទទួលបានប្រាក់ឧបត្ថម្ភសម្រាប់សម្លៀកបំពាក់ សម្ភារជំណេក អនាម័យ និងព្យាបាល ក្នុងមួយនាក់ទទួលបាន ១២០.០០០ រៀល ១ដង ក្នុង១ឆ្នាំ<br>- ទារក កុមារពិការធ្ងន់ធ្ងរ មានជំងឺរ៉ាំរ៉ៃ ផ្ទុកមេរោគអេដស៍ ឬមានជំងឺអេដស៍ (HIV/DIDS) ដែលស្នាក់នៅមណ្ឌលថែទាំរបស់រដ្ឋ ក្នុងមួយនាក់ទទួលបានប្រាក់ឧបត្ថម្ភ ២០.០០០ រៀល ក្នុងមួយខែ សម្រាប់បំប៉នសុខភាព<br>- ទារក កុមារអាយុ៥ឆ្នាំចុះទទួលមរណភាព ទទួលបានប្រាក់ឧបត្ថម្ភ រៀបចំបុណ្យសព ចំនួន ២៧០.០០០ រៀល ១ដងគត់<br>- កុមារអាយុ៥ឆ្នាំឡើងទទួលមរណភាព ទទួលបានប្រាក់ឧបត្ថម្ភ រៀបចំបុណ្យសព ចំនួន ៥៤០.០០០ រៀល ១ដងគត់ |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | - ទម្រង់គ្រប់គ្រងករណីរបស់កុមារ មានការចុះហត្ថលេខាពីអាជ្ញាធរមូលដ្ឋាន<br>- សេចក្តីប្រកាសជូនដំណឹងជាសាធារណៈពីការស្វែងរកឪពុកម្តាយរបស់កុមារ<br>- ពាក្យស្នើសុំបញ្ចូលរបស់អ្នកនាំកុមារ ឬអ្នកកាន់ករណី / ពាក្យស្នើសុំបញ្ចូលកុមាររបស់មន្ទីរស.អ.យ រាជធានី ខេត្ត<br>- ប្រវត្តិរូបសង្ខេបរបស់កុមារ<br>- លិខិតស្នើសុំបញ្ចូលកុមាររបស់បុរីទារក និងកុមារជាតិ<br>- គោលការណ៍ស្នើសុំបញ្ចូលកុមារពីនាយកដ្ឋានសុខុមាលភាពកុមារ ដើម្បីទទួលរបបគោលនយោបាយរបស់រដ្ឋ ពីឯកឧត្តមរដ្ឋមន្ត្រី<br>- ប្រកាសស្តីពីការបញ្ចូលកុមារទៅក្នុងមណ្ឌលបុរីទារក និងកុមារជាតិ<br>- តាមដានត្រួតពិនិត្យវាយតម្លៃ និងធ្វើរបាយការណ៍ពីស្ថានភាពកុមារ |
| យោបល់ | |

## ០៩. ការផ្តល់អាជ្ញាប័ណ្ណដល់ទីភ្នាក់ងារសុំកូនអន្តរប្រទេស

| | |
|---|---|
| ឈ្មោះសេវា | ការផ្តល់អាជ្ញាប័ណ្ណដល់ទីភ្នាក់ងារសុំកូនអន្តរប្រទេស |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស<br>➢ រដ្ឋបាលសុំកូនអន្តរប្រទេស<br>○ អាសយដ្ឋានៈ អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ<br>○ ទូរស័ព្ទៈ ០២៣ ២១១ ៨៤៨<br>○ អ៊ីម៉ែលៈ info@icca-cambodia.com.kh<br>○ គេហទំព័រៈ www.icaa-cambodia.com.kh |
| គោលបំណងនៃការ ផ្តល់សេវា | ទីភ្នាក់ងារដែលទទួលបានការអនុញ្ញាតឱ្យផ្តល់សេវាសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលអាចស្វែងរកគ្រួសារចិញ្ចឹមមួយដ៏ល្អក្នុងន័យជានាឧត្តមប្រយោជន៍របស់កុមារជាចម្បង |
| មូលដ្ឋានគតិយុត្ត | - អនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិកុមារដែលកម្ពុជាជាសមាជិកប្រកាសដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជានៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩២ និងបានផ្តល់សច្ចាប័ន នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២<br>- ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៣ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស<br>- ព្រះរាជក្រមលេខ នស/រកម/១២០៩/០២៤ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសុំកូនអន្តរប្រទេស<br>- ប្រកាសរួមលេខ ១០០៧ សហវ.ប្រក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- ប្រកាសលេខ១៩៨០ស.អ.យ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ ស្តីពីនីតិវិធីផ្តល់ការអនុញ្ញាតដល់ទីភ្នាក់ងារសុំកូនអន្តរប្រទេស |
| អតិថិជនដែលមាន សិទ្ធិទទួលសេវា | - ទីភ្នាក់ងារដែលមានការបញ្ជាក់ទទួលស្គាល់គុណវុឌ្ឍិពីអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស នៃប្រទេសរបស់ទីភ្នាក់ងារ<br>- ទីភ្នាក់ងារមានការអនុញ្ញាតពីអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស នៃប្រទេសរបស់ទីភ្នាក់ងារ ឲ្យធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា<br>- ទីភ្នាក់ងារនីមួយៗ ត្រូវចុះបញ្ជីតាមបទប្បញ្ញត្តិច្បាប់ជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជាទាក់ទងនឹងនីតិបុគ្គលមិនយកចំណេញ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល។ ទីភ្នាក់ងារមិនមានបើកមណ្ឌលកុមារកំព្រា ឬប្រើប្រាស់មណ្ឌលកុមារកំព្រាដើម្បីជាប្រភពផ្តល់ទារក និងកុមារកំព្រាសម្រាប់សុំកូនអន្តរប្រទេស |

<table>
<tr><td></td><td>- ប្រទេសរបស់ទីភ្នាក់ងារជាប្រទេសដែលមានទំនាក់ទំនងការទូតជាមួយព្រះរាជាណាចក្រកម្ពុជា។</td></tr>
<tr><td>ស្តង់ដាសេវា</td><td>- ទីភ្នាក់ងារត្រូវបានអនុញ្ញាតឱ្យផ្តល់សេវាស្មុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលប្រកបដោយសុច្ចរិតភាព ជំនឿទុកចិត្ត អភិបាលកិច្ចល្អ សមត្ថភាពវិជ្ជាជីវៈ គណនេយ្យភាព និងក្រមសីលធម៌<br>- តម្លៃសេវាសម្រាប់ការផ្តល់ ឬបន្តសុពលភាពអាជ្ញាប័ណ្ណស្មុំកូនអន្តរប្រទេស រយៈពេលផ្តល់ និងសុពលភាពអាជ្ញាប័ណ្ណត្រូវកំណត់ ដូចខាងក្រោម៖
<table>
<tr><th>ល.រ.</th><th>បរិយាយ</th><th>តម្លៃសេវា(៛)</th><th>សុពលភាព</th></tr>
<tr><td>១</td><td>ការផ្តល់អាជ្ញាប័ណ្ណ</td><td>១២.០០០.០០០</td><td>២ ឆ្នាំ</td></tr>
<tr><td></td><td>សេវារដ្ឋបាលពិនិត្យសំណុំឯកសារ</td><td>២.០០០.០០០</td><td></td></tr>
<tr><td></td><td>សេវាផ្តល់អាជ្ញាប័ណ្ណ</td><td>១០.០០០.០០០</td><td></td></tr>
<tr><td>២</td><td>បន្តសុពលភាពអាជ្ញាប័ណ្ណ</td><td>២.០០០.០០០</td><td>២ ឆ្នាំ</td></tr>
</table>
</td></tr>
<tr><td>តម្រូវការឯកសារ ដើម្បីទទួលបានសេវា</td><td>- សំណុំឯកសាររបស់ទីភ្នាក់ងារស្មុំកូនអន្តរប្រទេសមានដូចខាងក្រោម៖<br>1. ពាក្យស្នើសុំត្រូវចុះហត្ថលេខាដោយប្រធានទីភ្នាក់ងារ និងមានបិទតែមសារពើពន្ធ តម្លៃ ៥.០០០៛<br>2. ច្បាប់ចម្លងលិខិតបញ្ជាក់ទទួលស្គាល់គុណវុឌ្ឍិរបស់ទីភ្នាក់ងារ (នៅមានសុពលភាព) ចេញដោយអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់ទីភ្នាក់ងារ<br>3. ច្បាប់ចម្លងឯកសារអនុញ្ញាតឲ្យបើកទីភ្នាក់ងារដែលមានទិសដៅមិនស្វែងរកផលចំណេញដោយមានការបញ្ជាក់ត្រឹមត្រូវពីអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់ទីភ្នាក់ងារ<br>4. លិខិតរបស់អាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់ទីភ្នាក់ងារដែលអនុញ្ញាតឲ្យទីភ្នាក់ងារធ្វើប្រតិបត្តិការស្មុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា។<br>5. លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ទីភ្នាក់ងារ<br>6. ឯកសាសង្ខេបអំពីប្រវត្តិ សកម្មភាព កម្មវិធី និងសេវារបស់ទីភ្នាក់ងារ បញ្ជីរាយនាមបុគ្គលិក និងលក្ខណសម្បត្តិរបស់បុគ្គលិកទាំងនោះ រួមទាំងភស្តុតាងដែលបង្ហាញអំពីបទពិសោធន៍ក្នុងវិស័យស្មុំកូនអន្តរប្រទេសយ៉ាងតិច ៥ឆ្នាំ<br>7. របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំចុងក្រោយដែលមានធ្វើសវនកម្មដោយសវនករឯករាជ្យ រួមមាន ប្រភពមូលនិធិ សោហ៊ុយស្មុំកូន និងថ្លៃចំណាយនានា ទាក់ទងនឹងស្មុំកូនអន្តរប្រទេស</td></tr>
</table>

8. ប្រវត្តិរូបសង្ខេបមានបិទរូបថតទំហំ ៤សម x ៦សម របស់សមាជិកក្រុមប្រឹក្សាភិបាល ឬគណៈគ្រប់គ្រងទីភ្នាក់ងារ
9. ប្រវត្តិរូបសង្ខេបមានបិទរូបថតទំហំ ៤សម x ៦សម របស់បុគ្គលិកមួយនាក់ ឬពីរនាក់ ដែលបានទទួលការអនុញ្ញាតឲ្យធ្វើជាអ្នកតំណាងទីភ្នាក់ងារលើការងារសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា
10. ឯកសារភស្តុតាងនានាដែលបញ្ជាក់ថា អ្នកតំណាងដូចមានចែងក្នុងចំណុច ៩ ខាងលើ គ្មានជាប់ឈ្មោះក្នុងបញ្ជីថ្កោលទោសនៅប្រទេសដើមរបស់ខ្លួន និងនៅប្រទេសចុងក្រោយដែលខ្លួនកំពុងរស់នៅ ប្រសិនបើប្រទេសខុសគ្នា
11. ច្បាប់ចម្លងឯកសារចុះបញ្ជីតាមបទប្បញ្ញត្តិច្បាប់ជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា ទាក់ទងនឹងនីតិបុគ្គលមិនយកចំណេញ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ដោយមានការបញ្ជាក់ត្រឹមត្រូវពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា
12. ច្បាប់ចម្លងឯកសារកិច្ចព្រមព្រៀងពីអតីតកាល ឬបច្ចុប្បន្នកាលជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការផ្តល់ជំនួយមនុស្សធម៌ ឬការជួយឧបត្ថម្ភដល់កុមារកំព្រានានា នៅក្នុងព្រះរាជាណាចក្រកម្ពុជា
13. ច្បាប់ចម្លងកិច្ចព្រមព្រៀងទ្វេភាគី ស្តីពីកិច្ចសហប្រតិបត្តិការសុំកូនអន្តរប្រទេស រវាងព្រះរាជាណាចក្រកម្ពុជា (ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ) និងប្រទេសរបស់ទីភ្នាក់ងារ ប្រសិនបើប្រទេសនេះមិនមែនជាប្រទេសភាគីអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងការសុំកូនអន្តរប្រទេស
14. ឯកសារផ្សេងៗទៀតដែលក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា យល់ថាចាំបាច់ដើម្បីឧត្តមប្រយោជន៍កុមារ និងដើម្បីមានមូលដ្ឋានវាយតម្លៃពាក្យសុំឲ្យបានសមស្រប

- នីតិវិធីក្នុងការផ្ញើពាក្យសុំ និងសំណុំឯកសារទាំងអស់របស់ទីភ្នាក់ងារសុំកូនអន្តរប្រទេស ត្រូវបញ្ជូនតាមរយៈអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់ទីភ្នាក់ងារ ទៅស្ថានទូត ឬស្ថាប័នតំណាងនៃប្រទេសរបស់ទីភ្នាក់ងារប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ពិនិត្យ និងបញ្ជូនបន្តទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។
- សំណុំឯកសារទាំងអស់របស់ទីភ្នាក់ងារសុំកូនអន្តរប្រទេស ត្រូវមានជាភាសាអង់គ្លេស ឬភាសាបារាំង ហើយត្រូវបកប្រែជាភាសាខ្មែរ។

## ១០. ការទុកដាក់កុមារជាមួយគ្រួសារអចិន្ត្រៃយ៍នៅប្រទេសទទួល

| | |
|---|---|
| ឈ្មោះសេវា | ការទុកដាក់កុមារជាមួយគ្រួសារអចិន្ត្រៃយ៍នៅប្រទេសទទួល |
| ក្រសួង/ស្ថាប័នផ្តល់សេវា | - ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស<br>➢ រដ្ឋបាលសុំកូនអន្តរប្រទេស<br>○ អាសយដ្ឋានៈ អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ<br>○ ទូរស័ព្ទៈ ០២៣ ២១១ ៨៤៨<br>○ អ៊ីម៉ែលៈ info@icca-cambodia.com.kh<br>○ គេហទំព័រៈ www.icaa-cambodia.com.kh |
| គោលបំណងនៃការផ្តល់សេវា | ការផ្តល់សេវាដល់កុមារឱ្យទទួលបាននូវឋានៈ សិទ្ធិ និងកាតព្វកិច្ច ដូចជាកូនបង្កើត អាចបង្កើតនូវទំនាក់ទំនងអចិន្ត្រៃយ៍រវាងកូនសុំ និងឪពុកម្តាយចិញ្ចឹមស្របច្បាប់នៃប្រទេសទទួល |
| មូលដ្ឋានគតិយុត្ត | - អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារដែលកម្ពុជាជាសមាជិក ប្រកាសដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជានៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩២ និងបានផ្តល់សច្ចាប័ន នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២<br>- ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៣ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអនុម័តឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស<br>- ព្រះរាជក្រមលេខ នស/រកម/១២០៩/០២៤ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសុំកូនអន្តរប្រទេស<br>- អនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមណ្ឌលរបស់រដ្ឋ<br>- ប្រកាសលេខ ០៣៨ ស.អ.យ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការប្រឹក្សាការថែទាំជំនួសចំពោះកុមារ<br>- ប្រកាសលេខ ២១៧ ស.អ.យ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៦ ពីការដាក់ឱ្យអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ<br>- ប្រកាសលេខ ៦១៦ ស.អ.យ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជំនួសចំពោះកុមារក្នុងមណ្ឌល<br>- ប្រកាសលេខ ១៩៨ ស.អ.យ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជំនួស ចំពោះកុមាររនៅតាមសហគមន៍<br>- ប្រកាសលេខ ១៤៩ ស.អ.យ ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០០៧ ស្តីពីការកែសម្រួលសមាសភាព និងភារកិច្ចរបស់គណៈកម្មាធិការប្រឹក្សាការថែទាំជំនួសចំពោះកុមារ<br>- ប្រកាសរួមលេខ ១០០៧ សហវ-ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ រវាងក្រសួង |

| | |
|---|---|
| | សេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- ប្រកាសរួម ៤៤៨ សហវ-ប្រក ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៣ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការកំណត់ចំនួនប្រាក់ចំណាយសោហុយ និងវិភាគទាននានាសម្រាប់សុំកូនអន្តរប្រទេស<br>- ប្រកាសលេខ ១៩៤ ស.អ.យ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស នៃព្រះរាជាណាចក្រកម្ពុជា<br>- ប្រកាសលេខ ១៩៩ ស.អ.យ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការ អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស<br>- ប្រកាសលេខ ០០២ ស.អ.យ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៤ ស្តីពីការប្រើប្រាស់អក្សរកាត់ រូបសញ្ញា និងគំរូក្បាលលិខិតរបស់អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស<br>- ប្រកាសលេខ ០០៣ ស.អ.យ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការគ្រប់គ្រង និងចាត់ចែងប្រាក់វិភាគទានមនុស្សធម៌<br>- ប្រកាសលេខ ១៣៨ ស.អ.យ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ ស្តីពីការណែនាំអនុវត្តនីតិវិធីសុំកូនអន្តរប្រទេសដោយសាច់ញាតិ<br>- ប្រកាសលេខ ១៣៩ ស.អ.យ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ ស្តីពីការណែនាំអនុវត្តនីតិវិធីសុំកូនអន្តរប្រទេសចំពោះកុមារដែលត្រូវការនូវការថែទាំពិសេស និងកុមារមានតម្រូវការពិសេស<br>- ប្រកាសលេខ ១២៣០ ស.អ.យ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលសុំកូនអន្តរប្រទេស<br>- ប្រកាសលេខ ១៩៨០ ស.អ.យ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ ស្តីពីនីតិវិធីផ្តល់ការអនុញ្ញាតដល់ទីភ្នាក់ងារសុំកូនអន្តរប្រទេស |
| អតិថិជនដែលមានសិទ្ធិទទួលសេវា | **១. កូនសុំ**<br>- កុមារសញ្ជាតិខ្មែរដែលមានលំនៅឋានជាអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជាមានអាយុក្រោម៨ឆ្នាំ គិតត្រឹមថ្ងៃទទួលពាក្យសុំ លើកលែងតែករណីកុមារត្រូវការនូវការថែទាំពិសេស ដែលអនុញ្ញាតបានដល់អាយុក្រោម១៨ឆ្នាំ។ ក្នុងករណីកុមារមានបងប្អូនបង្កើតច្រើននាក់ ហើយម្នាក់មានអាយុក្រោម៨ឆ្នាំ អាចអនុញ្ញាតឲ្យសុំកុមារនោះរួមជាមួយនឹងបងប្អូនបង្កើតដែលមានអាយុក្រោម១៨ឆ្នាំ<br>- កុមារកំពុងរស់នៅក្នុងមណ្ឌលកុមារកំព្រា ឬរស់នៅក្រោមការទុកដាក់សមស្របផ្សេងទៀតដែលត្រួតពិនិត្យដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- កុមារទាំងនោះស្ថិតក្រោមអាណាព្យាបាលសម្រាប់អនីតិជន ឬកុមារដែលស្ថិតក្រោមអំណាចមេបាដែលមានស្ថានភាពលំបាកបំផុត<br>- ក្នុងករណីសុំកូនដោយសាច់ញាតិសុំកូនអាចអនុញ្ញាត ឲ្យបានចំពោះកុមារមានអាយុក្រោម១៨ ឆ្នាំដែលរស់នៅក្នុង ឬក្រៅមណ្ឌលកុមារកំព្រា។ |

| | |
|---|---|
| | **២ .អ្នកសុំ**<br>- អ្នកសុំ (ឪពុកម្តាយចិញ្ចឹម) ជាសហព័ទ្ធដែលមានបំណងសុំកូននៅកម្ពុជា (ទាក់ទងការដាក់ពាក្យសុំកូនតាមរយៈទីភ្នាក់ងារ ឬអាជ្ញាធរកណ្តាលនៃប្រទេសទទួល) ដែលមានលំនៅឋានអចិន្ត្រៃយ៍នៅក្នុងប្រទេសណាមួយផ្សេងទៀតដែលមានទំនាក់ទំនងការទូតជាមួយព្រះរាជាណាចក្រកម្ពុជា<br>- អ្នកសុំត្រូវមានលក្ខណសម្បត្តិ និងលក្ខខណ្ឌជាសារវន្តនានាសម្រាប់ស្មុំកូនស្របតាមច្បាប់ប្រទេសទទួល និងប្រទេសដើម<br>- អ្នកសុំមានអាយុចាប់ពី ៣០(សាមសិប)ឆ្នាំ និងមានអាយុលើសកូនសុំយ៉ាងតិច ២២(ម្ភៃពីរ)ឆ្នាំ និងយ៉ាងច្រើនបំផុត ៤៥(សែសិបប្រាំ )ឆ្នាំ គិតត្រឹមកាលបរិច្ឆេទដាក់ពាក្យសុំ<br>- អ្នកសុំត្រូវបានអនុញ្ញាតឱ្យសុំកូនបានលុះត្រាតែ អ្នកសុំកូនគ្មានកូន ឬមានកូនតែម្នាក់នៅក្នុងបន្ទុក។ អ្នកសុំអាចសុំកូនបានតែម្នាក់ប៉ុណ្ណោះ លើកលែងតែកុមារដែលមានបងប្អូនបង្កើតអាចអនុញ្ញាតឱ្យសុំច្រើននាក់បាន។ |
| ស្តង់ដាសេវា | កុមារដែលស្ថិតក្នុងករណីស្មុំកូនអន្តរប្រទេស ជាស្មុំកូនពេញលេញដែលត្រូវចម្រើនធំធាត់នៅក្នុងបរិយាកាសគ្រួសារ បរិយាកាសសុភមង្គល សេចក្តីស្រឡាញ់ និងការយោគយល់ដើម្បីឲ្យមានការអភិវឌ្ឍពេញលេញ និងយ៉ាងសុខដុមនូវបុគ្គលិកលក្ខណៈរបស់កុមារ ហើយបង្កើតនូវទំនាក់ទំនងរវាងអ្នកសុំនិងកូនសុំជាអចិន្ត្រៃយ៍ដែលផ្តល់ដល់កុមារនូវឋានៈ សិទ្ធិ និងកាតព្វកិច្ច ដូចជាកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹមនោះ។ កុមារដែលអាចអនុញ្ញាតដាក់ឲ្យស្មុំកូនអន្តរប្រទេសបាន លុះត្រាតែអស់លទ្ធភាពផ្តល់ការឧបត្ថម្ភដើម្បីឲ្យកុមាររស់នៅកុមាររស់នៅក្នុងគ្រួសារកំណើត និងក្រោយពីបានធ្វើការពិចារណាអំពីស្មុំកូននៅក្នុងព្រះរាជាណាចក្រកម្ពុជាអស់លទ្ធភាព និងស្របតាមគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារដែលចាត់ទុកស្មុំកូនអន្តរប្រទេស គឺជាដំណោះស្រាយចុងក្រោយនៃការទុកដាក់កុមារ។<br>**I. ប្រាក់ចំណាយសោហ៊ុយ វិភាគទាននានាសម្រាប់ស្មុំកូនអន្តរប្រទេស**<br>អ្នកសុំត្រូវបង់ប្រាក់ចំណាយសោហ៊ុយ និងវិភាគទាននានាចំនួន ៥.០០០ដុល្លារអាមេរិក ក្នុងការសុំកូនម្នាក់តាមរយៈទីភ្នាក់ងារ ឬអាជ្ញាធរកណ្តាលស្មុំកូនអន្តរប្រទេសនៃប្រទេសទទួល។ ការបង់ប្រាក់នេះ ត្រូវចែកជាពីរដំណាក់កាល៖<br>- **ដំណាក់កាលទី១៖** អ្នកសុំត្រូវបង់ប្រាក់ចំនួន ១.៥០០ដុល្លារអាមេរិក នៅពេលសំណុំឯកសារស្មុំកូនត្រូវបានបញ្ជូនមកដល់រដ្ឋបាលស្មុំកូនអន្តរប្រទេសនៃអាជ្ញាធរកណ្តាលស្មុំកូនអន្តរប្រទេស។ ចំនួនទឹកប្រាក់នេះមិនអាចបង្វិលជូនវិញបានទេ។<br>- **ដំណាក់កាលទី២៖** អ្នកសុំត្រូវបង់ប្រាក់ចំនួន ៣.៥០០ដុល្លារអាមេរិក នៅមុនពេលធ្វើពិធីប្រគល់កុមារជាផ្លូវការ។<br>ក្រៅពីការបង់ប្រាក់ចំណាយសោហ៊ុយ និងវិភាគទាននានាខាងលើនេះអ្នកសុំត្រូវបង់ប្រាក់សរុបចំនួន ១.០០០.០០០៛ តាមរយៈទីភ្នាក់ងារ ឬអាជ្ញាធរកណ្តាលស្មុំកូនអន្តរប្រទេសនៃប្រទេសទទួល ដើម្បីទ្រទ្រង់សោហ៊ុយដាក់ពាក្យសុំការពិនិត្យភ័ស្តុតាង |

| | |
|---|---|
| | ការចេញដីកាសម្រេច ការបញ្ជូនឯកសារ ការផ្សព្វផ្សាយសេចក្តីជូនដំណឹង ការស្រាវជ្រាវអង្គហេតុ និងសកម្មភាពខាងនីតិវិធីផ្សេងៗទៀតដែលទាក់ទងនឹងកិច្ចការសុំកូនអន្តរប្រទេស។ តុលាការត្រូវបង្គាប់ឲ្យអ្នកសុំបង់ចំនួនទឹកប្រាក់នោះជាមុន។ ក្នុងករណីដែលសោហ៊ុយចាំបាច់ដែលបានកំណត់ខាងលើនេះលើសពី ១.០០០.០០០៛ តុលាការអាចកំណត់ចំនួនសោហ៊ុយបន្ថែម និងបង្គាប់ឲ្យអ្នកសុំបង់សោហ៊ុយបន្ថែមនោះជាមុន។ ចំនួនទឹកប្រាក់នេះមិនអាចបង្វិលជូនវិញទេ។ |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | I. **សំណុំឯកសាររបស់កុមារដែលជាកម្មវត្ថុសុំកូនអន្តរប្រទេស**<br>- ទម្រង់ឆ្លើយតបដំបូង<br>- ទម្រង់របាយការណ៍អំពីកុមារដែលត្រូវបោះបង់ចោល<br>- ទម្រង់ទុកដាក់កុមារតាមការថែទាំជំនួស<br>- ទម្រង់នៃការទទួលកុមារឲ្យស្នាក់នៅក្នុងមណ្ឌល<br>- សំបុត្រកំណើតរបស់កុមារ<br>- ប្រវត្តិរូបសង្ខេបរបស់កុមារ<br>- រូបថតកុមារ(ពេលរើសបាន/ បច្ចុប្បន្នភាព)<br>- ប្រវត្តិសុខភាពកុមារ និងគ្រួសារ<br>- ការសិក្សាអំពីកុមារ (បុគ្គលិកសង្គមកិច្ច/មណ្ឌល/មន្ទីរស.អ.យ/នាយកដ្ឋានសុខុមាលភាពកុមារ)<br>- លិខិតជូនដំណឹងទៅមន្ទីរ ស.អ.យ អំពីវត្តមានរបស់កុមារក្នុងមណ្ឌល<br>- លិខិតបញ្ជាក់សុខភាព(ការពិពណ៌នាពីសុខភាពផ្លូវកាយនិងផ្លូវចិត្ត ពិការភាព ជំងឺរ៉ាំរ៉ៃ តម្រូវការពិសេស) និងប្រវត្តិនៃកុមារដែលបង្ហាញពីតម្រូវការពិសេស<br>- ឯកសារបញ្ជាក់ថាមានបងប្អូនអាយុក្រោម ០៨ឆ្នាំ<br>- រូបថតកុមារ ប្រសិនបើបងប្អូនបង្កើត<br>- ប្រកាសស្តីពីការបញ្ចូលកុមារក្នុងមណ្ឌល<br>- សេចក្តីប្រកាសស្វែងរកឪពុកម្តាយ ឬអាណាព្យាបាលកុមារ<br>- ឯកសារចម្លង ៖ ការសម្ភាសន៍ ខិត្តប័ណ្ណផ្សព្វផ្សាយ សេចក្តីប្រកាស តាមរយៈវិទ្យុ ទូរទស្សន៍។ល។ ដើម្បីបញ្ជាក់ថាបានស្វែងរកករណីរកឪពុកម្តាយ<br>- របាយការណ៍អំពីការស្វែងរកឪពុកម្តាយបង្កើត ឬអ្នកអាណាព្យាបាល ទម្រង់រកមិនឃើញ<br>- ទម្រង់បញ្ជាក់ពីការពិគ្រោះយោបល់ជាមួយកុមារស្តីពីសុំកូន និងមានមេឃុំ ចៅសង្កាត់ជាសាក្សី<br>- ទម្រង់បញ្ជាក់ពីការយល់ព្រមរបស់កុមារអំពីសុំកូនដោយមានមេឃុំ ចៅសង្កាត់ជាសាក្សី<br>- សេចក្តីសម្រេច ឬដីការបស់តុលាការពីភាពជាអាណាព្យាបាលសម្រាប់អនីតិជន (នាយកដ្ឋានសុខុមាលភាពកុមារ ឬមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា)<br>- សេចក្តីប្រកាសស្វែងរកគ្រួសារអេចិន្ត្រៃយ៍ ថ្នាក់ខេត្ត |

- ឯកសារចម្លង ៖ ការសម្ភាសន៍ ខិត្តប័ណ្ណផ្សព្វផ្សាយ សេចក្តីប្រកាស តាម រយៈវិទ្យុ ទូរទស្សន៍។ល។ ដើម្បីបញ្ជាក់ថាបានស្វែងរកករណីរកគ្រួសារអចិន្ត្រៃយ៍ថ្នាក់ខេត្ត
- របាយការណ៍អំពីការខិតខំក្នុងការទុកដាក់កុមារជា អចិន្ត្រៃយ៍ក្នុងខេត្ត
- ទម្រង់បញ្ជាក់ពីការយល់ព្រមរបស់ឪពុកម្តាយបង្កើត ឬអ្នកអាណាព្យាបាលអំពីសុំកូន ដោយមានមេឃុំ ចៅ សង្កាត់ជាសាក្សី
- សេចក្តីប្រកាសស្វែងរកគ្រួសារអចិន្ត្រៃយ៍ ថ្នាក់ជាតិ
- ឯកសារចម្លង ការសម្ភាសន៍ ខិត្តប័ណ្ណផ្សព្វផ្សាយ សេចក្តីប្រកាស តាមរយៈ វិទ្យុ ទូរទស្សន៍។ល។ ដើម្បីបញ្ជាក់ថាបានស្វែងរកនៅក្នុងប្រទេស
- របាយការណ៍អំពីការខិតខំក្នុងការទុកដាក់កុមារជា អចិន្ត្រៃយ៍ ក្នុងប្រទេស
- លិខិតស្នើសុំចុះឈ្មោះកុមារក្នុងបញ្ជីកុមារដែលមានលក្ខណសម្បត្តិសមស្របសម្រាប់ សុំកូនអន្តរប្រទេស

**II. ឯកសារអ្នកសុំ**

- ពាក្យសុំកូន (ដោយបញ្ជាក់ពីបំណង និងហេតុផលដែលចង់សុំកុមារទៅចិញ្ចឹម)
- លិខិតអនុញ្ញាតឲ្យសុំកូនចិញ្ចឹមចេញដោយអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ច ទទួលបន្ទុកសុំកូនអន្តរប្រទេសនៃប្រទេសរបស់អ្នកសុំ ដោយមានបញ្ជាក់ថាកូនសុំត្រូវ បានអនុញ្ញាតឲ្យចូលទៅរស់នៅជាអចិន្ត្រៃយ៍ក្នុងប្រទេសរបស់អ្នកសុំ នៅពេលដែល ដំណើរការសុំកូនបានសម្រេចជាផ្លូវការ
- របាយការណ៍ស្តីពីស្ថានភាពគ្រួសារ ដែលធ្វើឡើងដោយភ្នាក់ងារជំនាញលើការងារ នេះ ហើយមានការបញ្ជាក់ទទួលស្គាល់ពីអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់ អ្នកសុំដោយមានបញ្ជាក់អំពីសមត្ថភាពរបស់អ្នកសុំផ្នែកធនធានថវិកា សមត្ថភាព ផ្លូវចិត្ត និងប្រព័ន្ធគាំទ្រកុមារដែលអាចឆ្លើយតបទៅនឹងតម្រូវការរបស់កុមារ
- សេចក្តីចម្លងសំបុត្រកំណើត ឬលិខិតបញ្ជាក់កំណើត
- សេចក្តីចម្លងលិខិតអាពាហ៍ពិពាហ៍
- លិខិតបញ្ជាក់សុខភាពរបស់អ្នកសុំ
- របាយការណ៍អំពីចិត្តវិទ្យាធ្វើឡើងដោយគ្រូពេទ្យចិត្តវិទ្យា ដែលមានការទទួលស្គាល់ពី អាជ្ញាធរមានសមត្ថកិច្ច
- លិខិតបញ្ជាក់ថាអ្នកសុំបានទទួលព័ត៌មានគ្រប់គ្រាន់ និងបានទទួលការប្រឹក្សាយោបល់ អំពីការសុំកុមារដែលត្រូវការនូវការថែទាំពិសេស ឬកុមារដែលមានតម្រូវការពិសេស មុនពេលសុំកូន
- លិខិតបញ្ជាក់ថាគ្មានទោស ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចក្នុងប្រទេស កំណើត ឬកន្លែងដែលអ្នកសុំរស់នៅចុងក្រោយ ឬលិខិតថ្កោលទោសចេញដោយ តុលាការ ឬដោយអាជ្ញាធរមានសមត្ថកិច្ច ហើយនៅមានសុពលភាពសម្រាប់ប្រើប្រាស់
- លិខិតបញ្ជាក់ពីកិរិយាមាយាទ នៅកន្លែងប្រកបការងារ និងនៅក្នុងសង្គមរស់នៅរបស់ អ្នកសុំចេញដោយអាជ្ញាធរមានសមត្ថកិច្ច

- លិខិតបញ្ជាក់ពីស្ថានភាពហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់អ្នកសុំដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច
- កិច្ចសន្យាគោរពសិទ្ធិជាកូន ផ្តល់ការសិក្សា ព្រមទាំងសិទ្ធិផ្តល់កេរ្តិ៍មរតកដូចកូនបង្កើតរបស់ខ្លួន
- កិច្ចសន្យាស្តីពីការផ្តល់របាយការណ៍ជាលាយលក្ខណ៍អក្សរអំពីការវិវឌ្ឍរបស់កូនសុំទៅកាន់រដ្ឋបាលសុំកូនអន្តរប្រទេសដោយផ្ទាល់ ឬតាមរយៈអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬតាមរយៈទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសរបស់អ្នកសុំរៀងរាល់ ០៦ (ប្រាំមួយ) ខែម្តង ក្នុងរយៈពេល ០៣ឆ្នាំ បន្ទាប់មកត្រូវផ្តល់របាយការណ៍ ០១ឆ្នាំម្តង រហូតដល់កូនសុំមានអាយុ ១៨ឆ្នាំ
- ផែនការក្នុងការចិញ្ចឹមកុមារនៅពេលកុមារទៅដល់ប្រទេសទទួល (ដូចជារយៈពេលដែលអ្នកសុំអាចមានលទ្ធភាពឈប់សម្រាកថែទាំកុមារ)។ ផែនការក្នុងការមានអាណាព្យាបាលមើលថែទាំកុមារក្នុងករណីអ្នកសុំបាត់បង់សមត្ថភាព ឬស្លាប់ជាយថាហេតុ
- លិខិតបញ្ជាក់ពីមនោសញ្ចេតនា និងការអភិវឌ្ឍសង្គមក្នុងកិច្ចការពារថែទាំកុមារដែលត្រូវការនូវការថែទាំពិសេស ឬកុមារមានតម្រូវការពិសេស
- ច្បាប់ថតចម្លងលិខិតឆ្លងដែនរបស់អ្នកសុំ
- រូបថតរបស់អ្នកសុំ ៦សម x ៨សម ដែលថតក្នុងអំឡុង ០៣ខែចុងក្រោយ
- ឯកសារទាំងអស់ ត្រូវបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំ
- ឯកសារច្បាប់ដើមទាំងអស់ត្រូវភ្ជាប់មកជាមួយនូវការបកប្រែជាភាសាអង់គ្លេសដែលមានការបញ្ជាក់ត្រឹមត្រូវ។

**III.ឯកសារសម្រាប់កុមារអាចទទួលបានការអនុញ្ញាតរស់នៅស្របច្បាប់ក្នុងគ្រួសារអចិន្ត្រៃយ៍នៅប្រទេសទទួល**

- ដីកាសម្រេចពីសុំកូនអន្តរប្រទេស
- លិខិតបញ្ជាក់សុំកូនអន្តរប្រទេស ដែលចេញដោយអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជា

**IV.នីតិវិធី**

- សំណុំឯកសារអ្នកសុំនឹងត្រូវផ្ញើតាមរយៈអាជ្ញាធរកណ្តាលនៃប្រទេសទីភ្នាក់ងារ ស្ថានទូត ឬស្ថានតំណាងនៃប្រទេសទីភ្នាក់ងារប្រចាំនៅព្រះរាជាណាចក្រកម្ពុជា មកក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជាត្រូវបញ្ជូនពាក្យសុំមកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បន្ទាប់ពីបានការសម្រេចអនុញ្ញាតពីអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសរួចហើយ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវសហការជាមួយអ្នកសុំក្នុងការរៀបចំសំណុំឯកសារសុំកូនអន្តរប្រទេសទៅសាលាដំបូងរាជធានីភ្នំពេញ

| | |
|---|---|
| | - បន្ទាប់ពីបានដីកាសម្រេចរបស់តុលាការសាលាដំបូងរាជធានីភ្នំពេញរួចមក អាជ្ញាធរកណ្ដាលសុំកូនអន្តរប្រទេសត្រូវរៀបចំចេញនូវលិខិតបញ្ជាក់សុំកូនអន្តរប្រទេសដល់គ្រួសារអ្នកសុំ ហើយអ្នកសុំត្រូវមកកម្ពុជាដើម្បីទទួលកូននៅរដ្ឋបាលសុំកូនអន្តរប្រទេសក្នុងពិធីប្រគល់កូនជាផ្លូវការ<br>- ករណីមានបណ្ដឹងជំទាស់ទៅតុលាការសាលាឧទ្ធរណ៍ បន្ទាប់ពីបានដីកាសម្រេចរបស់តុលាការសាលាឧទ្ធរណ៍ អាជ្ញាធរកណ្ដាលសុំកូនអន្តរប្រទេសត្រូវរៀបចំចេញនូវលិខិតបញ្ជាក់សុំកូនអន្តរប្រទេសដល់គ្រួសារអ្នកសុំ ហើយអ្នកសុំត្រូវមកកម្ពុជាដើម្បីទទួលកូននៅរដ្ឋបាលសុំកូនអន្តរប្រទេស ក្នុងពិធីប្រគល់កូនជាផ្លូវការ។ |
| យោបល់ | ពាក់ព័ន្ធនឹងការផ្ដល់សេវាលើការផ្ដល់អាជ្ញាប័ណ្ណដល់ទីភ្នាក់ងារសុំកូនអន្តរប្រទេសក្នុងការទទួលបានការអនុញ្ញាតឲ្យផ្ដល់សេវាសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក៏ដូចជាអាជ្ញាធរកណ្ដាលសុំកូនអន្តរប្រទេស បានខិតខំរៀបចំកសាងច្បាប់លិខិតបទដ្ឋានគតិយុត្តនានា ស្របតាមបទដ្ឋានជាតិ អន្តរជាតិដែលការងារទាំងអស់នេះពិតជាបានចូលរួមចំណែកយ៉ាងសំខាន់ដើម្បីរកគ្រួសារល្អឱ្យកុមារ និងជានាឧត្តមប្រយោជន៍របស់កុមារ ទប់ស្កាត់ការកេងប្រវ័ញ្ច និងជួញដូរតាមរូបភាពសុំកូនអន្តរប្រទេស។ |

## ១១. ការផ្តល់សេវាស្តារនីតិសម្បទាជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន

| ឈ្មោះសេវា | ការផ្តល់សេវាស្តារនីតិសម្បទាជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន |
|---|---|
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | ក្រសួងសង្គមកិច្ចនិងអតីតយុទ្ធជន និងយុវនីតិសម្បទា<br>- អគ្គនាយកដ្ឋានបច្ចេកទេស<br>- នាយកដ្ឋានយុវនីតិសម្បទា<br>• អាសយដ្ឋាន អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ<br>• លេខទូរស័ព្ទ ០៧៧ ២២២ ៣២៥<br>- មជ្ឈមណ្ឌលព្យាបាល បន្សាប និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ<br>- មជ្ឈមណ្ឌលឱកាសខ្ញុំរាជធានីភ្នំពេញ ទីតាំងស្ថិតនៅភូមិសំរោង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ<br>- មជ្ឈមណ្ឌលស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ទីតាំងស្ថិតនៅភូមិជ្រៃ សង្កាត់ទឹកវិល ក្រុងសៀមរាប ខេត្តសៀមរាប<br>- មជ្ឈមណ្ឌលជីវិតថ្មីភ្នំបាក់ ទីតាំងស្ថិតនៅភូមិភ្នំបាក់ សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ<br>- មជ្ឈមណ្ឌលបញ្ជាការដ្ឋានកងរាជអាវុធហត្ថ ទីតាំងស្ថិតនៅភូមិគរដ្ឋាន សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ<br>- មជ្ឈមណ្ឌលពិភពនៃក្តីសង្ឃឹម ទីតាំងស្ថិតនៅភូមិដំណាក់ដង្កោ ឃុំក្តុលតាហែន ស្រុកបវេល ខេត្តបាត់ដំបង<br>- មជ្ឈមណ្ឌលបញ្ជាការដ្ឋានកងរាជអាវុធហត្ថ ទីតាំងស្ថិតនៅភូមិកម្មករ សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង<br>- មជ្ឈមណ្ឌលបញ្ជាការដ្ឋានកងរាជអាវុធហត្ថ ទីតាំងស្ថិតនៅភូមិ១ សង្កាត់១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ |
| គោលបំណង នៃការផ្តល់សេវា | ផ្តល់ការស្នាក់បណ្តោះអាសន្នជូនជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន នៅក្នុងមជ្ឈមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋ ដើម្បីបន្សាប ថែទាំសុខភាព អប់រំ កីឡា ព្យាបាល បណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈ ស្តារនីតិសម្បទា សមាហរណកម្មនៅសហគមន៍ និងតាមដានបន្ត |
| មូលដ្ឋានគតិយុត្ត | - ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១២<br>- អនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- អនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ |

| | |
|---|---|
| | - អនុក្រឹត្យលេខ ៤៩ អនក្រ.បក ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន<br>- អនុក្រឹត្យលេខ ៩០ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៧នៃអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាកនៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ<br>- ប្រកាសអន្តរក្រសួងលេខ៩៦៥ ស.អ.យ.ប្រក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៧ រវាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងសុខាភិបាល ស្តីពីលក្ខខណ្ឌ និងទម្រង់បែបបទនៃការស្នើសុំបង្កើតមជ្ឈមណ្ឌលសម្រាប់ការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននិងគោលការណ៍ណែនាំស្តីពីការព្យាបាល ស្តារនីតិសម្បទា និង សមាហរណកម្មអ្នកញៀនគ្រឿងញៀន<br>- ប្រកាសលេខ ២៥៣ ស.អ.យ. ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១២ ស្តីពីការអនុវត្តរបបឧបត្ថម្ភគោលនយោបាយជូនជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនដែលស្នាក់នៅក្នុងមជ្ឈមណ្ឌលអប់រំ បន្សាយ ព្យាបាល និងស្តារនីតិសម្បទា<br>- សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៨៨ ស.ស.រ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន |
| អតិថិជនដែលមានសិទ្ធិទទួលសេវា | - ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនដែលមានប្រភពមកពី៖<br>    ○ ការស្ម័គ្រចិត្ត<br>    ○ ឪពុកម្តាយ ឬអាណាព្យាបាល ឬអាជ្ញាធរមានសមត្ថកិច្ច<br>    ○ តុលាការ<br>- ទទួលបានសេវាអប់រំ បន្សាប ព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាល ជំនាញវិជ្ជាជីវៈ<br>- ក្រោយពីបញ្ចប់កម្មវិធីស្តារនីតិសម្បទាត្រូវបានបញ្ជូន ឬសមាហរណកម្មទៅក្រុមគ្រួសារ ឬសហគមន៍វិញ |
| ស្តង់ដាសេវា | ដំណាក់កាលនៃការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនមានដូចខាងក្រោម ៖<br>១. រយៈពេល៣ខែ<br>- វាយតម្លៃ និងធ្វើរោគវិនិច្ឆ័យ<br>- ព្យាបាលបន្សាប និងព្យាបាលជំងឺរួមផ្សំ<br>- ថែទាំបន្ត ផ្តល់ប្រឹក្សា អប់រំផ្លូវចិត្ត (ធ្វើផែនការស្តារនីតិសម្បទា)<br>២. រយៈពេល៦ខែ<br>- ថែទាំបន្ត ផ្តល់ប្រឹក្សា អប់រំផ្លូវចិត្ត (ចាប់ផ្តើមស្តារនីតិសម្បទា)<br>៣. រយៈពេល៩ខែ ឬ១២ខែ<br>- ថែទាំបន្ត ផ្តល់ប្រឹក្សា អប់រំផ្លូវចិត្ត ស្តារនីតិសម្បទា (ធ្វើផែនការសមាហរណកម្ម និង |

| | |
|---|---|
| | សមាហរណកម្ម)<br>- ក្នុងករណីជនរងគ្រោះមានសភាពធ្ងន់ធ្ងរ ការព្យាបាល និងស្តារនីតិសម្បទានឹងត្រូវអនុវត្តបន្តរហូតដល់រយៈពេល ២ឆ្នាំ។ (យោងគោលការណ៍ណែនាំស្តីពីការព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្មអ្នកញៀនគ្រឿងញៀន តាមរយៈប្រកាសអន្តរក្រសួងលេខ៩៦៥ ស.អ.យ ប្រក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៧ រវាងក្រសួង ស.អ.យ និងក្រសួងសុខាភិបាល) |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | មជ្ឈមណ្ឌលអប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាទាំងអស់ អនុវត្តដូចខាងក្រោម ៖<br>**ក.ការបញ្ចូលជនរងគ្រោះដើម្បីទទួលសេវា**<br>1. ពាក្យស្នើសុំបញ្ចូលជនរងគ្រោះក្នុងមជ្ឈមណ្ឌល<br>2. បញ្ជីឈ្មោះជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនដែលត្រូវស្នើសុំបញ្ចូលក្នុងមជ្ឈមណ្ឌល<br>3. កំណត់ហេតុ ឬលិខិតប្រគល់ ទទួលជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន<br>4. កិច្ចសន្យារបស់ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន<br>5. កិច្ចសន្យាអាណាព្យាបាល<br>6. ប្រវត្តិរូបសង្ខេបរបស់ជនរងគ្រោះ<br>7. ប្រកាសបញ្ចូលជនរងគ្រោះ<br>**ខ.ការបញ្ចេញជនរងគ្រោះ ឬសមាហរណកម្មជនរងគ្រោះ**<br>1. ពាក្យស្នើសុំបញ្ចេញជនរងគ្រោះពីមជ្ឈមណ្ឌល<br>2. បញ្ជីឈ្មោះជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនដែលត្រូវស្នើសុំបញ្ចេញពីមជ្ឈមណ្ឌល<br>3. សេចក្តីចម្លងប្រកាសបញ្ចូលជនរងគ្រោះ<br>4. សំបុត្រមរណភាព (ប្រសិនបើមាន)<br>5. លិខិតយល់ព្រមទទួលរបស់គ្រួសារ សាច់ញាតិ ឬអាជ្ញាធរមូលដ្ឋាន<br>6. ប្រកាសបញ្ចេញជនរងគ្រោះ |
| នីតិវិធីនៃការផ្តល់សេវា | ការស្តារនីតិសម្បទាអាចចាប់ផ្តើមបន្ទាប់ពីបញ្ចប់ការវាយតម្លៃរបស់គ្រូពេទ្យហើយដំណាក់កាលការចាប់ផ្តើមការស្តារនីតិសម្បទាមានដូចខាងក្រោម ៖<br>- ការពិគ្រោះយោបល់ អប់រំផ្លូវចិត្ត បំណិនជីវិត(សកម្មភាពមានរយៈពេល៦សប្តាហ៍)<br>- ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ រយៈពេលខ្លីពី៣ខែ ឬរយៈពេលវែងពី៦ខែទៅ១២ខែ<br>- ការធ្វើសមាហរណកម្ម បន្ទាប់ពីការស្តារនីតិសម្បទា និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈបានបញ្ចប់<br>- តាមដាន និងថែទាំបន្ត មានរយៈពេល១ខែដំបូង ៣ខែ ៦ខែ និង១២ខែ ក្រោយពីសមាហរណកម្ម<br>- បិទករណីចំពោះអតិថិជនអាចទុកចិត្តមិនត្រឡប់ទៅប្រើប្រាស់គ្រឿងញៀនវិញ ឬអតិថិជន |

| | |
|---|---|
| | ផ្លាស់ប្តូរទីលំនៅដោយមិនបានផ្តល់ព័ត៌មាន (ក្នុងគ្រប់ដំណាក់កាល បើរកឃើញថាអតិថិជនបានត្រឡប់ប្រើប្រាស់គ្រឿងញៀនវិញ មន្ត្រីសង្គមកិច្ចត្រូវសហការជាមួយក្រុមគ្រួសារ អាជ្ញាធរមូលដ្ឋាន ដើម្បីរៀបចំផែនការឱ្យអតិថិជនទៅទទួលសេវាព្យាបាល និងស្តារនីតិសម្បទាឡើងវិញ)<br>- ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនត្រូវទទួលរបបតាមអនុក្រឹត្យលេខ៩០ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ សម្រាប់តែមជ្ឈមណ្ឌលរបស់រដ្ឋ។ |
| យោបល់ | ជំរុញលើកទឹកចិត្តដល់អាជ្ញាធរមូលដ្ឋាន ឪពុកម្តាយ អាណាព្យាបាល ទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀននៅក្នុងមូលដ្ឋានរបស់ខ្លួន និងបញ្ជូនជនរងគ្រោះដោយសារប្រើប្រាស់គ្រឿងញៀនមកទទួលសេវាអប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាតាមមជ្ឈមណ្ឌល និងនៅតាមសហគមន៍។ |

## ១២. ការផ្តល់សេវាស្តារនីតិសម្បទាអនីតិជនទំនាស់នឹងច្បាប់

| | |
|---|---|
| ឈ្មោះសេវា | ការផ្តល់សេវាស្តារនីតិសម្បទាអនីតិជនទំនាស់នឹងច្បាប់ |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | ក្រសួងសង្គមកិច្ចនិងអតីតយុទ្ធជន និងយុវនីតិសម្បទា<br>- អគ្គនាយកដ្ឋានបច្ចេកទេស<br>- នាយកដ្ឋានយុវនីតិសម្បទា<br>• អាសយដ្ឋាន អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ<br>• លេខទូរស័ព្ទ ០៧៧ ២២២ ៣២៥<br>- មណ្ឌលយុវនីតិសម្បទា ទីតាំងស្ថិតនៅភូមិបាគូ ឃុំបាគូ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល (កំពុងសាងសង់) |
| គោលបំណង នៃការផ្តល់សេវា | - ធានាការពារសិទ្ធិ សុវត្ថិភាព និងលើកស្ទួយសុខុមាលភាពរាងកាយ និងស្មារតីរបស់អនីតិជន<br>- ផ្តល់សេវាពិគ្រោះយោបល់ អប់រំ ការពារសិទ្ធិតាមផ្លូវច្បាប់ បណ្តុះបណ្តាលវិជ្ជាជីវៈ ស្តារនីតិសម្បទា និងសមាហរណកម្មទៅក្នុងគ្រួសារ និងសហគមន៍<br>- ស្តារនីតិសម្បទាទណ្ឌិត និងធ្វើសមាហរណកម្មទណ្ឌិតដែលបានអនុវត្តទោសរួចទៅក្នុងសង្គម និងសហគមន៍ |
| មូលដ្ឋានគតិយុត្ត | - ច្បាប់ស្តីពីយុត្តិធម៌អនីតិជនឆ្នាំ២០១៦<br>- អនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- អនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ<br>- អនុក្រឹត្យលេខ ៩០ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៧នៃអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ<br>- អនុក្រឹត្យលេខ១៥៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មណ្ឌលយុវនីតិសម្បទា<br>- ប្រកាសលេខ១០១ អនក្រ.បក ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩ ស្តីពីការតែងតាំងនិងទទួលស្គាល់ភ្នាក់ងារសង្គមកិច្ច<br>- ផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិដើម្បីអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន ២០១៨-២០២០<br>- កូនតាមម្តាយដែលមានអាយុចាប់ពី០៣ឆ្នាំឡើង បើគ្មានអាណាព្យាបាលទទួលខុសត្រូវការចិញ្ចឹមបីបាច់ថែរក្សាបន្តនៅខាងក្រៅជាបន្ទុករបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (យោងតាមច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ២០១២) |

| | |
|---|---|
| អតិថិជនដែលមានសិទ្ធិទទួលសេវា | អនីតិជនទំនាស់នឹងច្បាប់ដែលបញ្ជូនដោយអាជ្ញាធរតុលាការ |
| ស្តង់ដាសេវា | អនីតិជនទំនាស់នឹងច្បាប់ទទួលបានការផ្តល់សេវាតាមដីកា និងសាលក្រមរបស់អាជ្ញាធរតុលាការ រហូតដល់អាយុក្រោម ២៤ឆ្នាំ ៖<br>**១. ការគ្រប់គ្រងអនីតិជនក្នុងមណ្ឌលយុវនីតិសម្បទា**<br>- ផ្នែកឃុំខ្លួនអនីតិជនបណ្តោះអាសន្ន<br>- ផ្នែកឃុំខ្លួនទណ្ឌិតជាអនីតិជនដើម្បីទទួលកម្មវិធីស្តារនីតិសម្បទា<br>- ផ្នែកសម្រាប់ត្រៀមដោះលែងអនីតិជនដើម្បីទទួលកម្មវិធីសមាហរណកម្ម<br>**២. ការរក្សាទុកអនីតិជន**<br>- អនីតិជនត្រូវដាក់ដោយឡែក (តាមសាលក្រមតុលាការ)<br>- តាមភេទ តាមប្រភេទនិងស្ថានភាពនៃបទល្មើស អាយុ អត្តចរិក សុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់អនីតិជន<br>- អនីតិជនភេទស្រីត្រូវស្ថិតនៅក្រោមការថែទាំរបស់បុគ្គលិកភេទស្រីដូចគ្នា<br>- នៅក្នុងអគារដាច់ដោយឡែក និងដឹកជញ្ជូនតាមមធ្យោបាយដាច់ដោយឡែក សម្រាប់អនីតិជនដែលមានជំងឺឆ្លង |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | ក. ឯកសារគតិយុត្តចេញដោយអាជ្ញាធរតុលាការ<br>- ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន<br>- សាលក្រមស្ថាពររបស់តុលាការ<br>- ឯកសារពាក់ព័ន្ធនឹងសំណុំរឿង<br>ខ. ទម្រង់គ្រប់គ្រងករណីអនីតិជនទំនាស់នឹងច្បាប់មាន<br>- សំណុំឯកសារផ្ទាល់ខ្លួនរបស់អនីតិជន<br>- ទម្រង់ស្វែងរកគ្រួសារ<br>- ទម្រង់ប៉ាន់ប្រមាណគ្រួសារ<br>- ទម្រង់គាំទ្រសង្គម និងផែនការករណី<br>- ទម្រង់ប៉ាន់ប្រមាណតម្រូវការអនីតិជនក្នុងមណ្ឌល<br>- ទម្រង់បញ្ជូនទៅរកសេវា<br>- ទម្រង់សមាហរណកម្ម<br>- ទម្រង់សួរសុខទុក្ខ និងព័ត៌មានត្រឡប់<br>- ទម្រង់បិទករណី<br>គ. ទម្រង់របាយការណ៍ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ( អនីតិជនដែលត្រូវទទួលកម្មវិធីបង្វែរ) |
| នីតិវិធីនៃការផ្តល់សេវា | សេវាផ្តល់ឱ្យអនីតិជនដែលកំពុងស្នាក់នៅក្នុងមណ្ឌល៖<br>- ពិនិត្យវាយតម្លៃសុខភាពផ្លូវកាយ ផ្លូវចិត្តដោយគ្រូពេទ្យ |

| | |
|---|---|
| | - ពិគ្រោះយោបល់ អប់រំផ្លូវចិត្ត<br>- សិក្សាអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ សិល្បៈ កំសាន្ត កីឡា<br>- ផ្តល់កម្មវិធីសមាហរណកម្ម<br>- សេវាកម្មផ្សេងៗទៀត<br>- ជួយរកសេវាថែទាំជំនួសដល់កុមារនៅតាមមណ្ឌលរដ្ឋ ឬអង្គការដៃគូ ដោយភ្ជាប់ជាមួយឯកសារគតិយុត្តត្រឹមត្រូវ<br>អនីតិជនទំនាស់នឹងច្បាប់ត្រូវទទួលបានរបបតាមអនុក្រឹត្យលេខ៩០ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ |
| យោបល់ | ក្រសួងស្ថាប័នដែលពាក់ព័ន្ធត្រូវផ្តល់សេវាជំនាញពេញលេញរបស់ខ្លួនដើម្បីធ្វើយ៉ាងណាឱ្យសេវាទាំងនោះអាចឱ្យអនីតិជនប្រកបរបរវិជ្ជាជីវៈបាន បន្ទាប់ពីបានដោះលែង ឬសមាហរកម្មវិលត្រលប់ទៅក្នុងក្រុមគ្រួសារ ឬសហគមន៍វិញ។<br>អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធត្រូវលើកស្ទួយការផ្សព្វផ្សាយច្បាប់ បទដ្ឋានគតិយុត្តផ្សេងៗពិសេសច្បាប់ស្តីពីយុត្តិធម៌អនីតិជនដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋានរបស់ខ្លួន និងចូលរួមអនុវត្តកម្មវិធីបង្វែរដើម្បីកាត់បន្ថយការអនុវត្តនីតិវិធីតុលាការនិងទប់ស្កាត់ការប្រព្រឹត្តបទល្មើសសារជាថ្មីរបស់អនីតិជន។ |

## ១៣. របបឧបត្ថម្ភគោលនយោបាយចំពោះជនពិការនៅតាមសហគមន៍

| ឈ្មោះសេវា | របបគោលនយោបាយឧបត្ថម្ភចំពោះជនពិការក្រីក្រនៅតាមសហគមន៍ |
|---|---|
| ក្រសួង/ស្ថាប័នផ្តល់សេវា | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- គណៈកម្មការសម្របសម្រួល និងជំរុញការអនុវត្តរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍ និងអនុគណៈកម្មការ<br>- អគ្គនាយកដ្ឋានបច្ចេកទេស<br>- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ<br>- នាយកដ្ឋានសុខុមាលភាពជនពិការ<br>- នាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់<br>- មូលនិធិជនពិការ៖ អាសយដ្ឋាន ផ្លូវជាតិលេខ ៦អា សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ<br>- ការិយាល័យបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការ<br>- គណៈកម្មការគ្រប់គ្រងរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍ រាជធានី ខេត្ត (លេខាធិការដ្ឋានមន្ទីរ ស.អ.យ រាជធានី ខេត្ត)<br>- អនុគណៈកម្មការគ្រប់គ្រងរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍ក្រុង ស្រុក ខណ្ឌ<br>- ក្រុមការងារឃុំ សង្កាត់ |
| គោលបំណងនៃការផ្តល់សេវា | - អនុវត្តច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ<br>- រួមចំណែកអនុវត្តយុទ្ធសាស្ត្រជាតិ និងគោលនយោបាយជាតិនានាដែលទាក់ទងនឹងការកាត់បន្ថយភាពក្រីក្រ<br>- ផ្តល់ជំនួយសង្គ្រោះបន្ទាន់ដល់ជនពិការក្រីក្រនៅតាមសហគមន៍<br>- ស្តារលទ្ធភាពពលកម្ម និងកសាងជីវភាពរស់នៅឡើងវិញដល់ជនពិការក្រីក្រនៅតាមសហគមន៍<br>- ទប់ស្កាត់ កាត់បន្ថយការធ្វើចំណាកស្រុកដោយប្រថុយប្រថានរបស់ជនពិការក្រីក្រនៅតាមសហគមន៍<br>- ផ្តល់សេវាសង្គមកិច្ចដល់ជនពិការក្រីក្រនៅតាមសហគមន៍ឱ្យមានប្រសិទ្ធភាព |
| មូលដ្ឋានគតិយុត្ត | - អនុសញ្ញា ស្តីពីសិទ្ធិជនពិការ<br>- ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ<br>- អនុក្រឹត្យលេខ ១៣៧ អនក្រ.បក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១ |
| អតិថិជនដែលមានសិទ្ធិទទួលសេវា | - ជនពិការមានពិការភាពធ្ងន់ធ្ងរ ក្រីក្របំផុតនិងគ្មានទីពឹង<br>- ជនពិការចាស់ជរា ក្រីក្របំផុតនិងគ្មានទីពឹង<br>- ជនពិការមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ក្រីក្របំផុតគ្មានទីពឹង |

| | |
|---|---|
| ស្តង់ដារសេវា | - ប្រាក់ឧបត្ថម្ភជីវភាពរស់នៅប្រចាំខែ (២០០០០៛/ខែ សម្រាប់រយៈពេល ០៣ខែ ០៦ ខែ និង ១២ខែ តាមរយៈការពិនិត្យ និងវាយតម្លៃពីគណៈកម្មការគ្រប់គ្រងរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍រាជធានី ខេត្ត<br>- ទទួលសេវាពីមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម រួមមាន ៖<br>• សេវាស្តារលទ្ធភាពពលកម្ម<br>• ប្រាក់សម្រាប់អាហារក្នុងអំឡុងពេលទទួលសេវាស្តារលទ្ធភាពពលកម្ម ៣០០០៛/ថ្ងៃ<br>• ប្រាក់សោហ៊ុយធ្វើដំណើរមកទទួលសេវាស្តារលទ្ធភាពពលកម្មទៅមក ១០០០០៛<br>• ប្រាក់ឧបត្ថម្ភទៅពិនិត្យ ព្យាបាល ថែទាំសុខភាព នៅតាមមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក ៣០០០០៛/ម្នាក់ (មួយលើក/ឆ្នាំ) |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | - ប័ណ្ណសមធម៌កម្រិតភាពក្រីក្រដែលចេញដោយក្រសួងផែនការ<br>- មានលំនៅដ្ឋាន ឬកន្លែងស្នាក់នៅដែលទទួលស្គាល់ដោយអាជ្ញាធរមូលដ្ឋាន<br>- ការវាយតម្លៃប្រភេទ និងកម្រិតពិការភាព តាមប្រកាសអន្តរក្រសួងលេខ ២៤៩២ សអយ/បក ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ រវាងក្រសួង សអយ និងក្រសួងសុខាភិបាល<br>- ប្រកាសទទួលស្គាល់ជនពិការដើម្បីទទួលបានរបបគោលនយោបាយជនពិការក្រីក្រនៅតាមសហគមន៍ចេញដោយក្រសួង ស.អ.យ<br>- ប័ណ្ណសង្គមកិច្ច ដែលចេញដោយគណៈកម្មការគ្រប់គ្រងរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍រាជធានី ខេត្ត តាមរយៈប្រកាសរបស់ក្រសួង ស.អ.យ<br>- គណនីផ្ទាល់ខ្លួនរបស់ជនពិការនៅធនាគារអេស៊ីលីដា ដើម្បីផ្ទេរថវិការបបគោលនយោបាយពីមូលនិធិជនពិការជូនជនពិការ |
| យោបល់ | ការផ្តល់សេវានេះអាចដំណើរការទៅបាន និងមានប្រសិទ្ធភាព លុះត្រាមានការចូលរួមពីស្ថាប័នដែលមានសមត្ថកិច្ចពាក់ព័ន្ធទាំងថ្នាក់ក្រសួង ស.អ.យ មូលនិធិជនពិការ គណៈកម្មការគ្រប់គ្រងរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍ រាជធានី ខេត្ត មន្ទីរ សអយ រាជធានី ខេត្ត អនុគណៈកម្មការគ្រប់គ្រងរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍ក្រុង ស្រុក ខណ្ឌ ក្រុមការងារឃុំ សង្កាត់ តាមរយៈការរៀបចំផែនការសកម្មភាព ថវិកាសម្រាប់ចំណាយលើកិច្ចរដ្ឋបាលថ្នាក់កណ្តាល និងថ្នាក់ក្រោមជាតិ និងថវិការបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍ និងការអនុវត្តផ្ទាល់។ |

# ១៤. សេវាបណ្តុះបណ្តាលវិជ្ជាជីវៈជូនជនពិការ

| | |
|---|---|
| ឈ្មោះសេវា | សេវាបណ្តុះបណ្តាលវិជ្ជាជីវៈជូនជនពិការ |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- អគ្គនាយកដ្ឋានបច្ចេកទេស<br>- នាយកដ្ឋានសុខុមាលភាពជនពិការ<br>• ទូរស័ព្ទ ៖ ០២៣ ២១៨ ៤៣៧<br>- ការិយាល័យបណ្តុះបណ្តាលវិជ្ជាជីវៈមុខរបរ និងដោះស្រាយការងារធ្វើជូនជនពិការ<br>• ទូរស័ព្ទ ៖ ០៩២ ៨៣១ ៣១៧<br>• អ៊ីមែល ៖ bun_chanrasmey@yahoo.com<br>• អាសយដ្ឋាន អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ<br>- សាលា JSCភូមិត្រពាំងវែង ឃុំធក់ឈើនាង ស្រុកអង្គស្នួល ខេត្តកណ្តាល<br>• ទូរស័ព្ទ ៖ ០១៧ ៤៥១ ៧៤៦<br>- សាលា JCIA ភូមិឆ្លូក សង្កាត់គោករកា ខ័ណ្ឌព្រែកព្នៅរាជធានីភ្នំពេញ<br>• ទូរស័ព្ទ ៖ ០១៦ ៦៦៨ ៣៤៩ |
| គោលបំណង នៃការផ្តល់សេវា | កសាងសមត្ថភាពជនពិការតាមរយៈការបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយផ្អែកលើបទដ្ឋានរួមមួយសម្រាប់មជ្ឈមណ្ឌលនិងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការទាំងអស់ដែលជាបទដ្ឋានពង្រឹងគុណភាពការងារបណ្តុះបណ្តាលវិជ្ជាជីវៈជូនជនពិការ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ និងមុខរបរ |
| មូលដ្ឋានគតិយុត្ត | សារាចរណែនាំលេខ ០០១ ស.អ.យ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការពង្រឹងគុណភាពការងារបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការ |
| អតិថិជនដែលមាន សិទ្ធិទទួលសេវា | ជនពិការដែលមកទទួលសេវាបណ្តុះបណ្តាលវិជ្ជាជីវៈនៅតាមមជ្ឈមណ្ឌល និងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈរបស់រដ្ឋ |
| ស្តង់ដារសេវា | **គ្រប់មជ្ឈមណ្ឌល និងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការ៖**<br>កម្រិតបទដ្ឋានអប្បបរមា ១៤ចំណុច ដើម្បីធានាគុណភាពការងារបណ្តុះបណ្តាលវិជ្ជាជីវៈជូនជនពិការ៖<br>១ មានអនុស្សរណៈនៃកិច្ចព្រមព្រៀងជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា<br>២ អនុវត្តនូវបទដ្ឋានគុណភាពការងារបណ្តុះបណ្តាលវិជ្ជាជីវៈជូនជនពិការ<br>៣ សិក្សាពីទីផ្សារកម្លាំងពលកម្ម ដើម្បីកំណត់មុខជំនាញសម្រាប់បណ្តុះបណ្តាល<br>៤ ផ្តល់សេវាកម្មប្រឹក្សាយោបល់ជាមួយសិក្ខាកាមលើការណែនាំតម្រង់ទិសសម្រាប់ជំនួយក្នុងការជ្រើសរើសមុខជំនាញ និងការងារសមស្រប<br>៥ ផ្តល់ការបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈសមស្របទៅនឹងតម្រូវការទីផ្សារការងារ |

និងមុខរបរ

៦ គ្រូបណ្ដុះបណ្ដាលត្រូវមានសមត្ថភាព និងគុរុកោសល្យគ្រប់គ្រាន់ក្នុងការអនុវត្តកម្មវិធីសិក្សា

៧ ត្រូវធ្វើបច្ចុប្បន្នភាពលើកម្មវិធីសិក្សាឱ្យស្របនឹងតម្រូវការទីផ្សារ

៨ ផ្ដល់ការគាំទ្រផ្នែកបច្ចេកទេស និងស្មារតីចំពោះសិក្ខាកាមទាំងពេលសិក្សា និងប្រកបការងារ

៩ ផ្ដល់ការបំប៉នជំនាញបន្ថែមដើម្បីអភិវឌ្ឍសមត្ថភាព និងឱកាសថ្មីៗសម្រាប់សិស្សដែលកំពុងប្រកបការងារ

១០ ត្រូវមានបទបញ្ជាផ្ទៃក្នុងដែលធានាដល់ការអនុវត្តកម្មវិធីសិក្សា ដើម្បីទទួលបានជោគជ័យ

១១ ត្រូវមានកម្មវិធីបណ្ដុះបណ្ដាលបន្ថែមនូវជំនាញគួបផ្សំ និងបង្កឱកាសឱ្យសិក្ខាកាមបានចូលរួមក្នុងសកម្មភាពនានារបស់សង្គម

១២ ផ្ដល់ និងសម្របសម្រួលដើម្បីទទួលបានកម្ចីគ្មានការប្រាក់ ឬមានការប្រាក់ទាបផ្ដល់ជាជំនួយ និងឧបករណ៍ផ្សេងៗដើម្បីជួយដល់ជនពិការមានលទ្ធភាពបង្កើតមុខរបរផ្ទាល់ខ្លួន និងជួយសម្របសម្រួលក្នុងការស្វែងរកការងារ

១៣ ត្រូវមានកម្មវិធីការងារតាមដានសិស្សបញ្ចប់វគ្គ ដើម្បីគាំទ្រឱ្យមាននិរន្តរភាពមុខរបរ

១៤ ហេដ្ឋារចនាសម្ព័ន្ធមជ្ឈមណ្ឌលត្រូវសម្រួលដល់លទ្ធភាពចល័តចេញចូលរបស់ជនពិការគ្រប់ប្រភេទ

<u>**លក្ខណវិនិច្ឆ័យ ៧ ចំណុច៖**</u>

១ រយៈពេលសមស្របសម្រាប់ការបណ្ដុះបណ្ដាល

២ គ្រូបណ្ដុះបណ្ដាលត្រូវមានលក្ខណសម្បត្តិ

ក.មានការទទួលស្គាល់សមត្ថភាពពីវិទ្យាស្ថាន ឬស្ថាប័នបណ្ដុះបណ្ដាលបច្ចេកទេសជាផ្លូវការ

ខ.មានជំនាញ និងបទពិសោធន៍គ្រប់គ្រាន់ក្នុងការបង្រៀន

គ.មានគរុកោសល្យ ឬភាពប៉ិនប្រសប់ក្នុងការផ្ទេរចំណេះដឹងនិងជំនាញ

៣ កម្មវិធីបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈ និងមុខវិជ្ជាចម្រុះបន្ថែម (អក្ខរកម្ម លេខនព្វន្តជំនួញ ចំណេះដឹងផ្នែកទីផ្សារ និងគោលការណ៍គ្រប់គ្រង....)

៤ ត្រូវធ្វើបច្ចុប្បន្នភាពលើកម្មវិធីបណ្ដុះបណ្ដាលទៅតាមតម្រូវការទីផ្សារ

៥ សម្ភារបណ្ដុះបណ្ដាលត្រូវផ្គត់ផ្គង់ទៅតាមតម្រូវការនៃវគ្គជំនាញនីមួយៗ

៦ ការងារបណ្ដុះបណ្ដាលត្រូវមានទ្រឹស្ដីផ្សាភ្ជាប់ទៅនឹងការអនុវត្តជាក់ស្ដែង (៣០:៧០)

៧ ត្រូវផ្ដល់សេវាគាំពារសុខភាពនិងសម្របសម្រួលដល់ការប្រើប្រាស់ ឧបករណ៍ជំនួយ (ក្នុងកំឡុងពេល សិក្សា)

**លក្ខណៈនៃបទដ្ឋានវិញ្ញាបនបត្រ ២២ ចំណុច ៖**

១ ចំពោះប្រភេទទីមួយ គឺប្រើសម្រាប់វគ្គបណ្តុះបណ្តាលដែលមានរយៈពេលចាប់ពី០៦ខែឡើងទៅហើយចុះហត្ថលេខាបញ្ជាក់នៅលើវិញ្ញាបនបត្រដោយរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

២ ប្រភេទទីពីរ គឺប្រើសម្រាប់វគ្គបណ្តុះបណ្តាលដែលមានរយៈពេលតិចជាង ០៦ខែ ហើយចុះហត្ថលេខាបញ្ជាក់នៅលើវិញ្ញាបនបត្រដោយប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត

៣ ទម្រង់បទដ្ឋានវិញ្ញាបនបត្របណ្តុះបណ្តាលវិជ្ជាជីវៈត្រូវមានព្រះរាជសង្ហានៃព្រះរាជាណាចក្រកម្ពុជាពណ៌មាស មានទីតាំងខ្ពស់ជាងគេនៅចន្លោះក្បាលរចនា

៤ គំរូវិញ្ញាបនបត្រទាំងពីរត្រូវមានពណ៌ទឹកមាសជុំវិញក្រដាសជាក្បាច់រចនាបទខ្មែរ

៥ ទីតាំងនៃស្លាកសញ្ញារបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការសាមីត្រូវមានទីតាំងកម្ពស់ស្មើគ្នា

៦ វិញ្ញាបនបត្របញ្ជាក់ការសិក្សាត្រូវចុះហត្ថលេខាដោយនាយកប្រធានអង្គការសាមី

៧ ចំពោះវិញ្ញាបនបត្រដែលមានរយៈពេលបណ្តុះបណ្តាលវិជ្ជាជីវៈតិចជាង០៦ខែត្រូវបោះពុម្ពលើផ្ទៃក្រដាសពណ៌ស

៨ ចំពោះវិញ្ញាបនបត្រដែលមានរយៈពេលបណ្តុះបណ្តាលវិជ្ជាជីវៈដែលចាប់ពី ០៦ខែឡើងទៅត្រូវបោះពុម្ពលើផ្ទៃក្រដាសពណ៌ពងមាន់

៩ គ្រប់វិញ្ញាបនបត្របណ្តុះបណ្តាលវិជ្ជាជីវៈត្រូវមានកម្មវិធីបណ្តុះបណ្តាលនៅផ្នែកខាងខ្នងនៃវិញ្ញាបនបត្រ ដោយមានការចុះហត្ថលេខាបញ្ជាក់ពីនាយកសាលាបានឃើញ និងឯកភាពដោយប្រធានមណ្ឌល

១០ តួអក្សរខ្មែរស្តីពី ព្រះរាជាណាចក្រកម្ពុជាត្រូវប្រើពណ៌ខ្មៅ Limon R4 ទំហំ៣២ ជាតិ សាសនា ព្រះមហាក្សត្រ ត្រូវប្រើពណ៌ខ្មៅ Limon R4 ទំហំ៣១

១១ តួអក្សរខ្មែរស្តីពីវិញ្ញាបនបត្របណ្តុះបណ្តាលវិជ្ជាជីវៈត្រូវប្រើពណ៌ខ្មៅ Limon R5ទំហំ ៣៤

១២ តួអក្សរអង់គ្លេសស្តីពីវិញ្ញាបនបត្របណ្តុះបណ្តាលវិជ្ជាជីវៈត្រូវប្រើពណ៌ខ្មៅ Arial ទំហំ ១០

១៣ តួអក្សរអង់គ្លេសស្តីពីអង្គការស្ថាប័នបណ្តុះបណ្តាលត្រូវដាក់ពីក្រោមស្លាកសញ្ញា ហើយមានទំហំសមរម្យ

១៤ តួអក្សរខ្មែរស្តីពីលេខត្រូវប្រើអក្សរពណ៌ខ្មៅ Limon S4 ទំហំ ២២

១៥ តួអក្សរអង់គ្លេសស្តីពីលេខត្រូវប្រើអក្សរពណ៌ខ្មៅ Arial ទំហំ១០

១៦ ចំពោះវិញ្ញាបនបត្រដែលត្រូវបញ្ជាក់ទទួលស្គាល់ពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាប្រើ Limon R4 ទំហំ ២៤

១៧ ចំពោះវិញ្ញាបនបត្រដែលត្រូវបញ្ជាក់ទទួលស្គាល់ត្រឹមថ្នាក់ខេត្ត តួអក្សរខ្មែរស្តីពីក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា មន្ទីរសង្គមកិច្ចអតីតយុទ្ធជននិង

| | |
|---|---|
| | យុវនីតិសម្បទារាជធានីខេត្តត្រូវប្រើ Limon R4 ទំហំ ២៤<br>១៨ ចំពោះរូបថតរបស់សិក្ខាកាមត្រូវមានទំហំ ៤ x ៦ដាក់ចំកណ្តាលផ្នែកខាងក្រោម<br>១៩ តួអក្សរខ្មែរស្តីពីទម្រង់ខ្លឹមសារនៃវិញ្ញាបនបត្រត្រូវប្រើអក្សរពណ៌ខ្មៅ Limon S4 ទំហំ ២៤ ចំណែកឯតួអក្សរខ្មែរស្តីពីការបញ្ជាក់ភិនភាគ និងលទ្ធផលសិក្សារបស់សិក្ខាកាមត្រូវប្រើអក្សរពណ៌ខ្មៅ Limon R4 ទំហំ ២៤<br>២០ តួអក្សរអង់គ្លេសស្តីពីទម្រង់ខ្លឹមសារនៃវិញ្ញាបនបត្រត្រូវប្រើអក្សរពណ៌ខ្មៅArial ទំហំ ១០ចំណែកឯតួអក្សរខ្មែរស្តីពីការបញ្ជាក់ភិនភាគ និងលទ្ធផលសិក្សារបស់សិក្ខាកាមត្រូវប្រើអក្សរពណ៌ខ្មៅដិត Times New Roman ទំហំ ១២<br>២១ ចំពោះវិញ្ញាបនបត្រទាំងពីរប្រភេទតួអក្សរស្តីពី ថ្ងៃខែឆ្នាំ បានឃើញ និងឯកភាពដែលត្រូវបញ្ជាក់លើវិញ្ញាបនបត្រត្រូវប្រើអក្សរពណ៌ខ្មៅ Limon S4 ទំហំ ២៤<br>២២ ចំពោះវិញ្ញាបនបត្រទាំងពីរប្រភេទតួអក្សរស្តីពី ឋានៈ តួនាទី នៃអ្នកដែលត្រូវបញ្ជាក់លើវិញ្ញាបនបត្រត្រូវប្រើអក្សរពណ៌ខ្មៅ Limon R4 ទំហំ ២៤ |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | - សំណើរបស់សាមីខ្លួនជនពិការ<br>- សំណើរបស់ស្ថាប័ន និងអង្គការនានា<br>- ការសម្រេចរបស់ប្រធានមជ្ឈមណ្ឌល និងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការ |
| យោបល់ | កម្រិតបទដ្ឋានរួមបានផ្តល់ឱ្យមជ្ឈមណ្ឌល និងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការបំពេញបាននូវ ៖<br>- តម្រូវការជាមូលដ្ឋានរបស់ជនពិការ និងគ្រួសារមានភាពប្រសើរឡើងតាមរយៈកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈសំដៅបង្កើនប្រាក់ចំណូលដោះស្រាយមុខរបរ និងរកការងារឱ្យជនពិការធ្វើ<br>- បង្កើនប្រភពចំណូលរបស់ជនពិការតាមរយៈកិច្ចប្រកបមុខរបរ និងបម្រើការងារ<br>- បង្កើនសមត្ថភាពជំនាញ និងចំណេះដឹងរបស់ជនពិការ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារនិងក្នុងសកម្មភាពរស់នៅប្រចាំថ្ងៃរបស់ជនពិការ<br>- ការកែលម្អគុណភាពវគ្គបណ្តុះបណ្តាលឱ្យឆ្លើយតបទៅនឹងទីផ្សារការងារ<br>- បង្កើត និងជំរុញយន្តការអនុវត្តបទដ្ឋានឱ្យមានផែនការច្បាស់លាស់ |

## ១៥. សេវាចុះបញ្ជិកាលើការអនុវត្តច្បាប់ពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ

| | |
|---|---|
| ឈ្មោះសេវា | សេវាចុះបញ្ជិកាលើការអនុវត្តច្បាប់ពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- នាយកដ្ឋានសុខុមាលភាពជនពិការ<br>- រដ្ឋបាលសិទ្ធិជនពិការ<br>• ទូរស័ព្ទ ៖ ០២៣ ២១៨ ៤៣៧ /០២៣ ៧២៦ ០៨៦<br>• អ៊ីម៉ែល ៖ panhamosvy@gmail.com<br>• អាសយដ្ឋាន ៖ អាគារលេខ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ |
| គោលបំណង នៃការផ្តល់សេវា | - ការពារសិទ្ធិ និងសេរីភាពរបស់ជនពិការ<br>- ការពារផលប្រយោជន៍ជនពិការ<br>- ទប់ស្កាត់ កាត់បន្ថយ និងលុបបំបាត់ការរើសអើងជនពិការ |
| មូលដ្ឋានគតិយុត្ត | - ព្រះរាជក្រមលេខ នស/រកម/០៧០៩/០១០ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ<br>- អនុក្រឹត្យលេខ ១០៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការកំណត់អត្រា និងបែបបទនៃការជ្រើសរើសជនពិការចូលបម្រើការងារ<br>- ប្រកាសលេខ ០៥៦ ស.អ.យ. ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១០ ស្តីពីការបង្កើតរដ្ឋបាលសិទ្ធិជនពិការ<br>- សារាចរណែនាំលេខ០០៥ ស.អ.យ/សរណន ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១២ ស្តីពីការសម្របសម្រួលសមស្របសម្រាប់ការងាររបស់ជនពិការ<br>- ប្រកាសអន្តរក្រសួងលេខ ២៤៨ ស.អ.យ.ប្រក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីការដាក់ឱ្យអនុវត្តនូវបទដ្ឋានបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត បង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព |
| អតិថិជនដែលមាន សិទ្ធិទទួលសេវា | ក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គល ដែលជាប្រធានអង្គភាព ម្ចាស់អាជីវកម្ម អង្គការនិង នាយកក្រុមហ៊ុន ព្រមទាំងជនពិការ |
| ស្តង់ដារសេវា | - មានរយៈពេល៖ ៣០ថ្ងៃ<br>- តម្លៃសេវា៖ ឥតគិតថ្លៃ<br>- សុពលភាព៖ ១ឆ្នាំ |
| តម្រូវការឯកសារ ដើម្បីទទួលបានសេវា | ១.សេវាចុះបញ្ជិកា<br>- លិខិតស្នើមកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- ពាក្យស្នើសុំចុះបញ្ជិកា<br>- ផែនការអនុវត្តនៃការជ្រើសរើសជនពិការចូលបម្រើការងារ<br>- សេចក្តីប្រកាសជូនដំណឹងស្តីពីចំនួនកម្មករនិយោជិតពិការ |

| | |
|---|---|
| | - ចលនាបុគ្គលិកចេញចូល (មានត្រាទទួលស្គាល់ពីមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ) |
| យោបល់ | |

## ១៦. អន្តរាគមន៍សេវាយុត្តិធម៌សម្រាប់ជនពិការ

| | |
|---|---|
| ឈ្មោះសេវា | អន្តរាគមន៍សេវាយុត្តិធម៌សម្រាប់ជនពិការ |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | - ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- អគ្គនាយកដ្ឋានបច្ចេកទេស<br>- រដ្ឋបាលសិទ្ធិជនពិការ នៃនាយកដ្ឋានសុខុមាលភាពជនពិការ<br>• អាគារលេខ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ<br>• លេខទូរស័ព្ទ ០២៣ ៧២៦ ០៨៦ |
| គោលបំណង នៃការផ្តល់សេវា | - ទទួលពាក្យបណ្តឹងពីជនពិការ និងអង្គភាព<br>- ចុះអន្តរាគមន៍ភ្លាមៗ<br>- ប្រតិកម្មឆាប់រហ័សឆ្លើយតបនឹងបណ្តាញទំនាក់ទំនងសង្គមនានា រឿងរំលោភសិទ្ធិជនពិការ<br>- ចុះប្រមូលព័ត៌មានទាក់ទងនឹងករណីរំលោភសិទ្ធិជនពិការ<br>- ធ្វើអធិការកិច្ចចំពោះក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គល ស្របតាមច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ<br>- ផ្តល់ការពិគ្រោះយោបល់ផ្នែកច្បាប់ដល់ជនពិការ ក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈ ផ្នែកឯកជន ព្រមទាំងអង្គការពាក់ព័ន្ធនានា<br>- ផ្តល់សេវាសម្របសម្រួល ផ្សះផ្សា ជួយដោះស្រាយនូវវិវាទផ្សេងៗ ដែលកើតឡើងក្នុងក្របខណ្ឌនៃច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ<br>- កសាងសំណុំរឿងប្តឹងទៅតុលាការ ចំពោះអ្នកប្រព្រឹត្តល្មើស និងបទបញ្ញត្តិនៃច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ |
| មូលដ្ឋានគតិយុត្ត | - ព្រះរាជក្រមលេខ នស/រកម/០៧០៩/០១០ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ<br>- អនុក្រឹត្យលេខ ១០៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការកំណត់អត្រា និងបែបបទនៃការជ្រើសរើសជនពិការចូលបម្រើការងារ<br>- ប្រកាសលេខ ០៥៦ ស.អ.យ. ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១០ ស្តីពីការបង្កើតរដ្ឋបាលសិទ្ធិជនពិការ<br>- សារាចរណែនាំលេខ០០៥ ស.អ.យ/សរណន ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១២ ស្តីពីការសម្របសម្រួលសមស្របសម្រាប់ការងាររបស់ជនពិការ<br>- ប្រកាសអន្តរក្រសួងលេខ ២៤៨ ស.អ.យ.ប្រក ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីការដាក់ឱ្យអនុវត្តនូវបទដ្ឋានបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធរូបវន្ត បង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព |
| អតិថិជនដែលមាន | ក្រសួងស្ថាប័នរដ្ឋ និងនីតិបុគ្គល ដែលជាប្រធានអង្គភាព ម្ចាស់អាជីវកម្ម អង្គការនិងនាយក |

| | |
|---|---|
| សិទ្ធិទទួលសេវា | ក្រុមហ៊ុន ព្រមទាំងជនពិការ |
| ស្តង់ដារសេវា | - មានរយៈពេលៈ ជាក់ស្តែងតាមករណី<br>- តម្លៃសេវាៈ ឥតគិតថ្លៃ<br>- សុពលភាពៈ ពុំមានកាលបរិច្ឆេទទេ |
| តម្រូវការឯកសារ ដើម្បីទទួលបានសេវា | - ប្រវត្តិរូបសង្ខេបអតិថិជន<br>- ទឡ្ហីករណ៍ដែលអតិថិជនមាន<br>- តម្រូវការឯកសារពាក់ព័ន្ធមួយចំនួន |
| យោបល់ | |

## ១៧. ការផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជូនជនពិការ

| | |
|---|---|
| ឈ្មោះសេវា | ការផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទា |
| ក្រសួង/ស្ថាប័នផ្តល់សេវា | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- មូលនិធិជនពិការ<br>- អាសយដ្ឋាន ៖ ផ្លូវលេខ៦ ភូមិគៀនឃ្លាំង សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ |
| គោលបំណងនៃការផ្តល់សេវា | - ដើម្បីផ្តល់សេវាស្តារលទ្ធភាពពលកម្ម (ការផ្តល់អវយវៈសិប្បនិម្មិត និងរណប ឧបករណ៍ជំនួយរាងកាយ រទេះរុញ ការជួសជុល និងការព្យាបាលដោយចលនាជូនជនពិការ)<br>- ដើម្បីឱ្យជនពិការមានលទ្ធភាពទទួលបានការចូលរួម និងដាក់បញ្ចូលដោយពេញលេញក្នុងគ្រប់ទិដ្ឋភាពនៃឆាកជីវិត |
| មូលដ្ឋានគតិយុត្ត | - អនុក្រឹត្យលេខ ១៣៧ អនក្រ.បក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១ ស្តីពីរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍<br>- ប្រកាសលេខ ១៦១៥ ស.អ.យ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការអនុវត្តរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍ ដែលមកទទួលសេវានៅមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មរបស់រដ្ឋ |
| អតិថិជនដែលមានសិទ្ធិទទួលសេវា | ជនពិការ |
| ស្តង់ដារសេវា | - ជនពិការទទួលសេវាដោយមិនគិតថ្លៃ<br>- ជនពិការ ដែលមកទទួលសេវានៅក្នុងមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទារបស់រដ្ឋត្រូវទទួលបានថ្លៃអាហារ ៣.០០០៛/ថ្ងៃ និងថ្លៃធ្វើដំណើរទៅមក ១០.០០០៛ |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | សំណុំឯកសារដែលជនពិការត្រូវបំពេញ ៖<br>- ពាក្យសុំមានបិទរូបថត ៤x៦ ២សន្លឹក<br>- អត្តសញ្ញាណប័ណ្ណ ឬសៀវភៅគ្រួសារ ឬលិខិតបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន<br>- ប័ណ្ណសមធម៌ ប័ណ្ណសង្គមកិច្ច។ |
| យោបល់ | |

## ១៨. សេវាស្តារលទ្ធភាពពលកម្ម និងរបបគោលនយោបាយផ្នែកពិនិត្យ ព្យាបាល និងថែទាំសុខភាពចំពោះជនពិការក្រីក្រតាមសហគមន៍

| | |
|---|---|
| ឈ្មោះសេវា | សេវាស្តារលទ្ធភាពពលកម្ម និងរបបគោលនយោបាយផ្នែកពិនិត្យ ព្យាបាល និងថែទាំសុខភាពចំពោះជនពិការក្រីក្រតាមសហគមន៍ |
| ក្រសួង/ស្ថាប័នផ្តល់សេវា | - មូលនិធិជនពិការ<br>- អាសយដ្ឋាន ៖ ផ្លូវលេខ៦ ភូមិគៀនឃ្លាំង សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ |
| គោលបំណងនៃការផ្តល់សេវា | - ជួយឱ្យជនពិការ ឬបុគ្គលដែលប្រឈមមុខនឹងពិការភាព មានភាពប្រសើរឡើងនៃរាងកាយដែលអាចពួកគាត់មានលទ្ធភាពក្នុងការចូលរួមក្នុងសកម្មភាពនានារបស់សង្គម។<br>- ជួយសម្រួលជាធនធានថវិកាដល់ជនពិការ ក្នុងការទៅទទួលសេវាសុខាភិបាលនៅមន្ទីរពេទ្យរដ្ឋ។ |
| មូលដ្ឋានគតិយុត្ត | - ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ<br>- អនុក្រឹត្យលេខ១១៨អនក្របក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិជនពិការ<br>- អនុក្រឹត្យលេខ១៣៧ អនក្របក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១ ស្តីពីរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍<br>- ប្រកាសអន្តរក្រសួងលេខ២៤៩២សអយ/បក ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ស្តីពីការកំណត់លក្ខណៈវិនិច្ឆ័យប្រភេទ និងកម្រិតពិការភាព<br>- ប្រកាសលេខ១៨៥៥សអយ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១១ ស្តីពីរចនាសម្ព័ន្ធរបស់អង្គការប្រតិបត្តិនៃមូលនិធិជនពិការ<br>- ប្រកាសអន្តរក្រសួងលេខ៧៦៦អបស/មត ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំសមាសភាពក្រុមប្រឹក្សាវាយតម្លៃប្រភេទ និងកម្រិតពិការភាពថ្នាក់រាជធានី/ខេត្ត<br>- ប្រកាសលេខ១៦១៥សអយ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការអនុវត្តរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍ដែលមកទទួលសេវានៅមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មរបស់រដ្ឋ<br>- ប្រកាសលេខ១៦៤សអយ ចុះថ្ងៃទី២៤ ខែកុម្ភៈឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទារាជធានី/ខេត្ត<br>- ប្រកាសលេខ៦៩៤ សអយ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៩ ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មអ្នកជំងឺរបួសខួរឆ្អឹងខ្នង<br>- គោលការណ៍ណែនាំស្តីពីការងារស្តារលទ្ធភាពពលកម្មកាយសម្បទានៅក្នុងប្រទេសកម្ពុជា។ |
| អតិថិជនដែលមាន | - ជនពិការក្រីក្រគ្រប់ប្រភេទ |

| | |
|---|---|
| សិទ្ធិទទួលសេវា | - ជនដែលកំពុងប្រឈមនឹងពិការភាព (ជំងឺ គ្រោះថ្នាក់ផ្សេងៗ ពីកំណើត) |
| ស្តង់ដារសេវា | - ផ្តល់សេវាស្តារលទ្ធភាពពលកម្មជូនជនពិការគ្រប់ប្រភេទទាំងនៅក្នុងមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម និងនៅតាមសហគមន៍<br>- ផ្តល់របបគោលនយោបាយថ្លៃអាហារ ៣.០០០រៀល/ថ្ងៃ និងថ្លៃធ្វើដំណើរទៅមក ១០.០០០រៀល អំឡុងពេលមកទទួលសេវា<br>- ផ្តល់របបគោលនយោបាយ ៣០.០០០រៀល/ឆ្នាំ ចំពោះជនពិការក្រីក្រនៅតាមសហគមន៍ក្នុងការទៅពិនិត្យ ព្យាបាល និងថែទាំសុខភាព |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | - អត្តសញ្ញាណប័ណ្ណ ឬសៀវភៅគ្រួសារ ឬលិខិតបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន<br>- ប័ណ្ណសមធម៌ ប័ណ្ណសង្គមកិច្ច។ |
| យោបល់ | |

## ១៩. ការផ្តល់របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុក

| | |
|---|---|
| ឈ្មោះសេវា | ការផ្តល់របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុក |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | - បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល (បជស)<br>• អាសយដ្ឋាន ៖ នៅក្នុងទីស្តីការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្សរាជធានីភ្នំពេញ<br>• ទូរស័ព្ទ ៖ (៨៥៥)២៣ ៩៨៧ ៥១២<br>• ទូរសារ ៖ (៨៥៥)២៣ ៩៨៧ ៥២៣<br>• អ៊ីមែល ៖ info@nssfc.gov.kh<br>• គេហទំព័រ ៖ www.nssfc.gov.kh |
| គោលបំណង នៃការផ្តល់សេវា | ការផ្តល់របបសន្តិសុខសង្គមជូនមន្ត្រីរាជការស៊ីវិល និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុកតាមគោលការណ៍អភិបាលកិច្ចល្អ មានតម្លាភាព ប្រសិទ្ធភាព និងមានការទទួលខុសត្រូវខ្ពស់។ |
| មូលដ្ឋានគតិយុត្ត | - ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃ ព្រះរាជាណាចក្រកម្ពុជា<br>- ព្រះរាជក្រឹត្យលេខ នស/រកត/០១១៣/១២០ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៣ ស្តីពីការកែសម្រួលឋានន្តរស័ក្តិថ្នាក់សន្ទស្សន៍បៀវត្សមូលដ្ឋាន និងប្រាក់បំណាច់មុខងាររបស់ក្របខណ្ឌភ្នាក់ងាររដ្ឋបាលក្រសួងមហាផ្ទៃ និងភ្នាក់ងារបច្ចេកទេសរបស់មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា<br>- ព្រះរាជក្រឹត្យលេខ នស/រកត/០១០៨/០៣៩ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៨ ស្តីពីរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល<br>- ព្រះរាជក្រឹត្យលេខ នស/រកត/០៩១២/៨៤៨ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១២ ស្តីពីការកែសម្រួលអាយុចូលនិវត្តន៍របស់មន្ត្រីរាជការស៊ីវិលជាស្ត្រី<br>- ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១២ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈ របស់រដ្ឋ<br>- ព្រះរាជក្រឹត្យលេខ នស/រកត/០១១៤/០១៧ ចុះថ្ងៃទី៤ ខែមករា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា២៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សមន្ត្រីរាជការស៊ីវិល<br>- អនុក្រឹត្យលេខ ៧៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ស្តីពីការកំណត់អត្រាភាគទានសម្រាប់ទ្រទ្រង់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល<br>- អនុក្រឹត្យលេខ ៨០ អនក្រ.បក ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០២ ស្តីពីការដំណើរការនៃការ |

| | |
|---|---|
| | ដាក់មន្ត្រីរាជការស៊ីវិលឲ្យចូលនិវត្តន៍តាមអាយុ តាមប្រព័ន្ធព័ត៌មានវិទ្យា<br>- អនុក្រឹត្យលេខ ៣២ អនក្រ.បក ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការកំណត់ប្រាក់ឧបត្ថម្ភលើកដំបូង និងប្រាក់សោធនជូនចៅក្រម និងព្រះរាជអាជ្ញាដែលត្រូវចូលនិវត្តន៍ ឬចូលបាត់បង់សម្បទាវិជ្ជាជីវៈ<br>- អនុក្រឹត្យលេខ ២១៤ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការកែសម្រួលការកំណត់ប្រាក់ឧបត្ថម្ភចំពោះ សមាជិកក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ<br>- អនុក្រឹត្យលេខ ២០១ អនក្រ.បក ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការកែសម្រួលការកំណត់ប្រាក់ឧបត្ថម្ភម្តងគត់ ជូនមន្ត្រីរាជការស៊ីវិល ចៅក្រម និងព្រះរាជអាជ្ញាដែលចូលនិវត្តន៍ ចូលបាត់បង់សម្បទាវិជ្ជាជីវៈ មរណភាព សុំលាឈប់ពីការងារ សុំចូលនិវត្តន៍មុនកាលកំណត់ និងមិនគ្រប់លក្ខខណ្ឌចូលនិវត្តន៍ ឬចូលបាត់បង់សម្បទាវិជ្ជាជីវៈ<br>- អនុក្រឹត្យលេខ ២២១ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការកំណត់កាលបរិច្ឆេទនៃការដាក់មន្ត្រីរាជការស៊ីវិល ឲ្យចូលនិវត្តន៍<br>- អនុក្រឹត្យលេខ ២៤១ អនក្រ.បក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១២ ស្តីពីការកែសម្រួលតម្លៃឯកតាសន្ទស្សន៍បៀវត្សមូលដ្ឋាន និងការ បង្កើនបៀវត្សសុទ្ធសាធរបស់មន្ត្រីរាជការស៊ីវិល<br>- អនុក្រឹត្យលេខ ៤៦៨ អនក្រ.បក ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៣ ស្តីពីការបង្កើនបៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការ នៃក្របខណ្ឌឃ ក្របខណ្ឌគ ឋានន្តរស័ក្តិទី៣ និងឋានន្តរស័ក្តិទី២ ក្រោមច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា<br>- អនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពី ការបង្កើតបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល<br>- អនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០០៩ ស្តីពី ការផ្តល់ប្រាក់បំណាច់ជីវភាពជូនមន្ត្រីរាជការស៊ីវិល កងយោធពល ខេមរភូមិន្ទ កងនគរបាលជាតិ និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ យុទ្ធជនពិការ និងអតីតយុទ្ធជន<br>- អនុក្រឹត្យ ១១៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០២ ស្តីពី ការកែសម្រួលការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់ សម្បទាវិជ្ជាជីវៈ ជូនមន្ត្រីរាជការស៊ីវិលតាមប្រព័ន្ធបៀវត្សថ្មី<br>- អនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃ៦ ខែតុលា ឆ្នាំ១៩៩៧ ស្តីពី ការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា<br>- អនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ ស្តីពីការកែប្រែ និងការដំឡើងរបបសន្តិសុខសង្គមសម្រាប់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន<br>- អនុក្រឹត្យលេខ ១៩៤ អនក្រ.បក ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការកែប្រែ និងដំឡើងប្រាក់ឧបត្ថម្ភមាតុភាពជូនមន្ត្រីរាជការ មន្ត្រីកម្មសិក្សា និងមន្ត្រីជាប់កិច្ចសន្យាជាស្ត្រីដែលសម្រាលកូន និងប្រាក់ឧបត្ថម្ភបុណ្យសពជូនគ្រួសារសពមន្ត្រីរាជការ |

| | |
|---|---|
| | មន្ត្រីកម្មសិក្សា និងមន្ត្រីជាប់កិច្ចសន្យា ដែលទទួលមរណភាព<br>- អនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៩ ស្តីពី ការបន្ថែមរបបសន្តិសុខសង្គមសម្រាប់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន<br>- សេចក្តីសម្រេចលេខ ២៤៥ សសរ ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ១៩៨៨ ស្តីពីរបបគោលនយោបាយធានារ៉ាប់រងសង្គមសម្រាប់កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ និវត្តជន និងជនបាត់បង់សមត្ថភាពពលកម្ម<br>- សារាចរណែនាំលេខ ០១១ ស.អ.យ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១០ ស្តីពីការបើកប្រាក់សោធនចំពោះមន្ត្រីរាជការដែលជានិវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ ជនបាត់បង់សមត្ថភាពការងារជនពិការ និងគ្រួសារជនពលី គ្រួសារជនមរណៈដែលទទួលមុខតំណែងជាអ្នកនយោបាយ<br>- សារាចរលេខ ០០៦ ស.អ.យ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១០ ស្តីពីការផ្តល់ប្រាក់បំណាច់ជីវភាពជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ<br>- សារាចរណែនាំលេខ ០០៨ ស.អ.យ ចុះថ្ងៃទី៤ វិច្ឆិកា ឆ្នាំ២០០៤ ស្តីពី ការអនុវត្តអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា<br>- សារាចរណែនាំលេខ ០០៦ ស.អ.យ ចុះថ្ងៃទី១ ខែសីហា ឆ្នាំ២០១៤ ស្តីពីការបន្ថែមប្រាក់សោធន ជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិល<br>- សារាចរលេខ ០៤ សរ ចុះថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការកំណត់នីតិវិធីសម្រាប់ការបើកផ្តល់របបសន្តិសុខសង្គម ជូនសិទ្ធិវន្ត និងជូនអតីតយុទ្ធជន និងគ្រួសារ<br>- សេចក្តីណែនាំលេខ ០០៣ ស.អ.យ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ ស្តីពីការពង្រឹងការអនុវត្តរបបសោធនជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ<br>- សេចក្តីណែនាំលេខ ០០៤ សរណន.ស.អ.យ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការតម្លើងប្រាក់ឧបត្ថម្ភប្រចាំខែជូនប្រពន្ធ ប្តី និងកូនកំព្រារបស់និវត្តជនជនបាត់បង់សម្បទាវិជ្ជាជីវៈ សពនិវត្តជន សពជន បាត់បង់សម្បទាវិជ្ជាជីវៈ និងសពមន្ត្រីរាជការស៊ីវិល<br>- សារាចរណែនាំលេខ ០០២ សរណន.ស.អ.យ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលប្រាក់ឧបត្ថម្ភគោលនយោបាយធានារ៉ាប់រងសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល<br>- សារាចរណែនាំអនុវត្តលេខ ៣៣ យ.ស.សណេន ចុះថ្ងៃទី១១ ខែ មករា ឆ្នាំ១៩៨៩ របស់ក្រសួងយុទ្ធពិការ សង្គមកិច្ច លើសេចក្តីសម្រេចលេខ ២៤៥ សសរ ចុះថ្ងៃ៥ ខែវិច្ឆិកា ឆ្នាំ១៩៨៨ ស្តីពីរបបគោលនយោបាយធានារ៉ាប់រងសង្គមសម្រាប់កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ និវត្តជន និងជនបាត់បង់ សមត្ថភាពពលកម្ម |
| អតិថិជនដែលមាន | មន្ត្រីរាជការស៊ីវិល (រួមមានចៅក្រម និងព្រះរាជអាជ្ញា )និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ |

| | |
|---|---|
| សិទ្ធិទទួលសេវា | (រួមមានអ្នកចូលនិវត្តន៍ដែលកំពុងទទួលមុខតំណែងជាអ្នកនយោបាយ) និងអ្នកនៅក្នុងបន្ទុកនៃជនទាំងនេះ |
| ស្តង់ដារសេវា | **មន្ត្រីរាជការស៊ីវិល និងអ្នកនៅក្នុងបន្ទុក**<br>- មន្ត្រីរាជការទទួលមរណភាពដោយជំងឺ ប្រាក់ឧបត្ថម្ភជូនគ្រួសារសពចំនួន ៦ខែ និងប្រាក់បូជាសពចំនួន ១.២០០.០០០៛ ព្រមទាំងផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែជូនកូនម្នាក់ ១០.០០០៛ហូតដល់អាយុ ២១ឆ្នាំ ( ប.ជ.ស ជាអ្នកគ្រប់គ្រង និងបើកផ្តល់បន្ត )<br>- មន្ត្រីរាជការស៊ីវិលទទួលមរណភាពដោយគ្រោះថ្នាក់ការងារ ឬបេសកកម្ម ប្រាក់ឧបត្ថម្ភជូនគ្រួសារសពចំនួន ៨ខែ និងប្រាក់បូជាសពចំនួន ១.៥០០.០០០៛ ព្រមទាំងផ្តល់ប្រាក់ឧបត្ថម្ភជូនក្នុងម្នាក់ ១០.០០០៛/១ខែ ហូតដល់អាយុ ២១ឆ្នាំ ( ប.ជ.ស ជាអ្នកគ្រប់គ្រង និងបើកផ្តល់បន្ត )<br>- លំហែមាតុភាពទទួលប្រាក់ឧបត្ថម្ភចំនួន ៦០០.០០០៛ ( ក្រសួង ស្ថាប័នសាមីទទួលបន្ទុកដោះស្រាយ )<br>- គ្រោះថ្នាក់ការងារ( ក្រសួង ស្ថាប័នសាម៉ីទទួលបន្ទុកដោះស្រាយ)<br>- ការផ្តល់ប្រាក់ឧបត្ថម្ភមួយលើកដំបូងម្តងគត់ជូន មន្ត្រីរាជការស៊ីវិល ដែលចូលនិវត្តន៍ ឬចូលបាត់បង់សម្បទាវិជ្ជាជីវៈ គឺជាបន្ទុកដោះ- ស្រាយដោយក្រសួង ស្ថាប័នសាមី<br>**មន្ត្រីរាជការដែលចូលនិវត្តន៍**<br>- ប្រាក់ឧបត្ថម្ភមួយលើកដំបូង = បៀវត្សមូលដ្ឋាន X ៨ខែ<br>- ប្រាក់សោធនប្រចាំខែ = បៀវត្សមូលដ្ឋាន X អតីតភាពការងារ (៨០% អតីតភាពការងារអតិបរមា ៣០ឆ្នាំ និង ៦០% អតីតភាព ការងារអប្បបរមា ២០ឆ្នាំ)<br>**មន្ត្រីរាជការដែលចូលបាត់បង់សម្បទាវិជ្ជាជីវៈ**<br>- ប្រាក់ឧបត្ថម្ភមួយលើកដំបូង = បៀវត្សមូលដ្ឋាន X ៧ខែ<br>- ប្រាក់សោធនប្រចាំខែ = បៀវត្សមូលដ្ឋាន X អតីតភាពការងារ (៦៥% អតីតភាពការងារអតិបរមា ២៩ឆ្នាំ និង ៥០% អតីតភាព ការងារអប្បបរមា ២០ឆ្នាំ)<br>**និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុក**<br>- និវត្តជនប្រាក់សោធនអតិបរមា ១.២១៥.៦៤០៛/១ខែ អប្បបរមា ៥៦០.០០០៛/១ខែ ជនបាត់បង់សម្បទាវិជ្ជាជីវៈប្រាក់សោធនអតិបរមា ៧៣៣.៧៤០៛/១ខែ អប្បបរមា ៥៦០.០០០៛/១ខែ<br>- និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈទទួលមរណភាព ប្រាក់សោធន សរុបចំនួន ១២ខែ ប្រាក់ឧបត្ថម្ភសហព័ទ្ធ ១៥.០០០៛/១ខែ ហូតដល់ទទួលមរណភាព ឬ មានសហព័ទ្ធថ្មី និងកូនម្នាក់ ១០.០០០៛/១ខែ ហូតដល់អាយុ ២១ឆ្នាំ មិនត្រូវមានភ្ជាប់លិខិតបញ្ជាក់ការសិក្សាទេ |
| តម្រូវការឯកសារដើម្បីទទួលបានសេវា | **ការទទួលបានប្រាក់ឧត្ថម្ភដល់គ្រួសារសពមន្ត្រីរាជការស៊ីវិល ដែលទទួលមរណភាពដោយជំងឺ**<br>- លិខិតស្នើសុំឧបត្ថម្ភរបបសន្តិសុខសង្គមជូនគ្រួសារសព និងស្នើសុំបន្តឧបត្ថម្ភប្រាក់ |

គោលនយោបាយប្រចាំខែ ជូនកូនកំព្រាសពមន្ត្រីរាជការស៊ីវិល (បើមានអ្នកនៅក្នុងបន្ទុក) ០២ច្បាប់

- លិខិតបញ្ជាក់សំបុត្រកំណើតកូន ០១ច្បាប់
- ប្រកាសលុបឈ្មោះសពមន្ត្រីរាជការស៊ីវិល ០១ច្បាប់
- សេចក្តីចម្លងសំបុត្របញ្ជាក់មរណភាពពីអាជ្ញាធរមូលដ្ឋាន ០១ច្បាប់
- តារាងរៀបរាប់ស្ថានភាពគ្រួសារសព ០១ច្បាប់
- វិញ្ញាបនបត្រផ្តាច់ប្រាក់បៀវត្សរបស់សព ០២ច្បាប់
- តារាងទូទាត់ប្រាក់ធានារ៉ាប់រងសង្គម ០២ច្បាប់

**ការទទួលបានប្រាក់ឧត្តម្ភដល់គ្រួសារសពមន្ត្រីរាជការស៊ីវិល ដែលទទួលមរណភាពដោយគ្រោះថ្នាក់ការងារ និងបេសកកម្ម**

- លិខិតស្នើសុំឧបត្ថម្ភរបបសន្តិសុខសង្គមជូនគ្រួសារសព និងស្នើ សុំបន្តឧបត្ថម្ភប្រាក់គោលនយោបាយប្រចាំខែ ជូនកូនកំព្រាសពមន្ត្រី រាជការស៊ីវិល (បើមានអ្នកនៅក្នុងបន្ទុក) ០២ច្បាប់
- លិខិតបញ្ជាក់សំបុត្រកំណើតកូន ០១ច្បាប់
- ប្រកាសលុបឈ្មោះសពមន្ត្រីរាជការស៊ីវិល ០១ច្បាប់
- លិខិតមរណភាព ០១ច្បាប់
- លិខិតបញ្ជាបេសកកម្ម ឬលិខិតឧទ្ទេសនាម ០១ច្បាប់
- កំណត់ហេតុគ្រោះថ្នាក់ការងារ ឬពេលបំពេញបេសកកម្មរបស់អង្គភាពមានសមត្ថកិច្ច ០១ច្បាប់
- តារាងរៀបរាប់ស្ថានភាពគ្រួសារសព ០១ច្បាប់
- វិញ្ញាបនបត្រផ្តាច់ប្រាក់បៀវត្សរបស់សព ០២ច្បាប់
- តារាងទូទាត់ប្រាក់ធានារ៉ាប់រងសង្គម ០២ច្បាប់

**ការឧបត្ថម្ភរបបសន្តិសុខសង្គម ជូនគ្រួសារសពមន្ត្រីរាជការស៊ីវិល និងលំហែមាតុភាពទទួលបន្ទុកដោះស្រាយដោយក្រសួង ស្ថាប័នសាមី បន្ទាប់ពីមានការឯកភាពជាគោលការណ៍ពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ការទទួលបានប្រាក់ឧបត្ថម្ភរបស់មន្ត្រីរាជការស៊ីវិលពេលលំហែមាតុភាព (បច្ចុប្បន្នក្រសួង ស្ថាប័នសាមី ជាអ្នកអនុវត្ត)**

- លិខិតស្នើសុំប្រាក់ឧបត្ថម្ភគោលនយោបាយធានារ៉ាប់រងសង្គម ០១ច្បាប់
- លិខិតបញ្ជាក់ថាបានសម្រាលកូនចេញពីមន្ទីរពេទ្យ ឬពីអង្គភាព ដែលគ្រប់គ្រងសាមីជន ០១ច្បាប់
- សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតកូនពីអាជ្ញាធរមូលដ្ឋាន ០១ច្បាប់

**ការចូលនិវត្តន៍ ឬបាត់បង់សម្បទាវិជ្ជាជីវៈរបស់មន្ត្រីរាជការស៊ីវិល**

- ពាក្យស្នើសុំឧបត្ថម្ភរបបសន្តិសុខសង្គមប្រចាំខែជូននិវត្តជន និងជនបាត់បង់សម្បទា

| | |
|---|---|
| | វិជ្ជាជីវៈ ០១ច្បាប់<br>- ប្រកាសដាក់ឲ្យចូលនិវត្តន៍ ឬចូលបាត់បង់សម្បទាវិជ្ជាជីវៈ (ច្បាប់ ដើម១) ០២ច្បាប់<br>- សាលាកបត្រមន្ត្រីរាជការស៊ីវិលចូលនិវត្តន៍០១ច្បាប់<br>- ពាក្យសុំចូលនិវត្តន៍របស់អ្នករាជការដែលមានអតីតភាពការងារ ៣០ឆ្នាំ ឡើងទៅ មិនទាន់គ្រប់អាយុ ហើយស្ម័គ្រចិត្តចូលនិវត្តន៍ ០១ច្បាប់<br>- វិញ្ញាបនបត្របញ្ជាក់ការបាត់បង់សម្បទាវិជ្ជាជីវៈ ចេញដោយគណៈកម្មការវាយតម្លៃសុខភាព បើអ្នករាជការនោះបាត់បង់សម្បទាវិជ្ជាជីវៈ ០១ច្បាប់<br>- កំណត់ហេតុស្តីពីគ្រោះថ្នាក់ការងារ ឬបេសកកម្ម បើអ្នករាជការនោះទទួលរងគ្រោះថ្នាក់ដោយបំពេញការងារ ០១ច្បាប់<br>- រូបថត ៦សម គុណ ៤សម ០៣សន្លឹក<br>**ការទទួលបានប្រាក់ឧបត្ថម្ភដល់គ្រួសារសពនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ និងបន្តការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនអ្នកនៅក្នុងបន្ទុក**<br>- សំណើសុំលុបឈ្មោះនិវត្តជន ឬជនបាត់បង់សម្បទាវិជ្ជាជីវៈ<br>- សំណើសុំឧបត្ថម្ភរបបសន្តិសុខសង្គមជូនគ្រួសារសព<br>- តារាងរៀបរាប់ស្ថានភាពគ្រួសារសព<br>- សេចក្តីចម្លងសំបុត្រមរណភាព<br>- សៀវភៅនិវត្តជន ឬជនបាត់បង់សម្បទាវិជ្ជាជីវៈ<br>- វិញ្ញាបនបត្រផ្តាច់ប្រាក់សោធននិវត្តន៍ ឬសោធបាត់បង់សម្បទាវិជ្ជាជីវៈ |
| យោបល់ | ក្រោយពីអ្នកស្នើសុំបានបំពេញលក្ខខណ្ឌដែលបានកំណត់តាមគោលការណ៍ដូចមានចែងក្នុងចំណុច "តម្រូវការឯកសារដើម្បីទទួលបានសេវា" រួចហើយ បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលនឹងផ្តល់សេវា ជូនតាមគោលការណ៍អភិបាលកិច្ចល្អ មានតម្លាភាព ប្រសិទ្ធភាព និងមានការទទួលខុសត្រូវខ្ពស់។ នាពេលអនាគត បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលនឹងពង្រីកសេវាបន្ថែមទៀត ដើម្បីជួយកាត់បន្ថយការលំបាករបស់មុខសញ្ញា។ |

## ២០. ការបើកផ្តល់របបសន្តិសុខសង្គមជូនអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន

| | |
|---|---|
| ឈ្មោះសេវា | ការបើកផ្តល់របបសន្តិសុខសង្គម ជូនអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- បេឡាជាតិអតីតយុទ្ធជន "ប.ជ.អ."<br>• ទូរស័ព្ទ ៖ ០២៣ ២១៣ ៥៨០<br>• អ៊ីមែល ៖ nfv.info@gmail.com or nfv_gov@yahoo.com<br>• គេហទំព័រ ៖ www.nfv.gov.kh<br>• អាសយដ្ឋានលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ (អាគារថ្មីជាន់ទី ១.២.៣) |
| គោលបំណង នៃការផ្តល់សេវា | បង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងបើកផ្តល់របបសន្តិសុខសង្គម ជូនអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជនឱ្យបានឆាប់រហ័ស និងមានតម្លាភាព |
| មូលដ្ឋានគតិយុត្ត | - អនុក្រឹត្យច្បាប់លេខ ១០ ក្រ.ច ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ របស់ក្រុមប្រឹក្សារដ្ឋនៃរដ្ឋកម្ពុជាដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពពលកម្មចំពោះនគរបាលប្រជាជនកម្ពុជា<br>- ព្រះរាជក្រមលេខ០៧ នស/៩៤ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ<br>- ព្រះរាជក្រមលេខ នស/រកម/០៤០៦/០០៨ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៦ វិសោធនកម្មច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ<br>- ព្រះរាជក្រឹត្យលេខ នស/រកត/០៧១០/៥៩៥ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១០ ស្តីពីរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន<br>- ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា<br>- ព្រះរាជក្រឹត្យលេខ នស/រកត/០៦១០/៤៦៤ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា<br>- ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹស្ថានសាធារណៈរដ្ឋបាល<br>- សេចក្តីសម្រេចលេខ ២០ ស.ស.រ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ១៩៩១ ស្តីពីរបបគោលនយោបាយចំពោះជនពលី ពិការ និងលិខិតលេខ ៥១៥ ស.ជ.ណ<br>- អនុក្រឹត្យលេខ ១១៥ អនក្របក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ស្តីពីការអនុវត្តរបបសោធននិវត្តន៍ និងបាត់បង់សមត្ថភាពការងារ<br>- អនុក្រឹត្យលេខ ០៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៧ ស្តីពីរបបឧបត្ថម្ភចំពោះយោធិនពលីមរណៈ បង្គស្លាប់ បាត់ខ្លួន និងជនពិការ |

| | |
|---|---|
| | - អនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៩ ស្តីពីរបបឧបត្ថម្ភគោលនយោបាយចំពោះមន្ត្រីនគរបាលពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងជនពិការ<br>- អនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១០ ស្តីពីការបង្កើតបេឡាជាតិអតីតយុទ្ធជន<br>- អនុក្រឹត្យលេខ ១០១ អនក្រ.បក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០ ស្តីពីការកែសម្រួលការកំណត់របបឧបត្ថម្ភ និងរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារជូនកងយោធពលខេមរភូមិន្ទ និងកងកម្លាំងនគរបាលជាតិ ដែលចូលនិវត្តន៍ បាត់បង់សមត្ថភាពការងារ ពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ<br>- សេចក្តីជូនដំណឹងលេខ ១៦១៥ សជណ.អវ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការអនុញ្ញាតិបន្ថែមថវិកាលើការកែសម្រួលរបបសន្តិសុខសង្គម ជូនអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន មុននិងក្រោយឆ្នាំ២០០៧ ឱ្យតុល្យភាពគ្នា<br>- អនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥ ស្តីពីបន្ថែមរបបសន្តិសុខសង្គមសម្រាប់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន<br>- អនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការកែសម្រួលបៀវត្សរ៍មូលដ្ឋាន និងការបើកផ្តល់បៀវត្សរ៍ដល់យោធិននៃកងយោធពលខេមរភូមិន្ទ<br>- អនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការកែសម្រួលបៀវត្សរ៍មូលដ្ឋាន និងការបើកផ្តល់បៀវត្សរ៍ដល់មន្ត្រីនគរបាលជាតិ<br>- អនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការបន្ថែមរបបសន្តិសុខសង្គមសម្រាប់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន<br>- អនុក្រឹត្យលេខ ៥០ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៦ ស្តីពីការបន្ថែមរបបសន្តិសុខសង្គមសម្រាប់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន<br>- អនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ ស្តីពីការកែប្រែនិងការដំឡើងរបបសន្តិសុខសង្គមសម្រាប់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន<br>- អនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៩ ស្តីពីការបន្ថែមរបបសន្តិសុខសង្គមសម្រាប់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន<br>- សារាចរអន្តរក្រសួងលេខ ០៤ សកអ. ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៤ ស្តីពីរបៀបបំពេញសំណុំលិខិត និងសម្រេចទទួលស្គាល់ជនពលី-ពិការ<br>- សារាចរណែនាំអន្តរក្រសួងលេខ ០០១/២០០៧ សណ.អក ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីរបបឧបត្ថម្ភចំពោះយោធិនពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ<br>- ប្រកាសអន្តរក្រសួងលេខ ១២៨ ប្រកអន ចុះថ្ងៃទី០៧ ខែវិច្ឆកា ឆ្នាំ២០០៧ ស្តីពីការបង្កើតគណៈកម្មការវាយតម្លៃកម្រិតថ្នាក់បាត់បង់សមត្ថភាពការងារចំពោះយោធិនទាំងពីរភេទនៃកងយោធពលខេមរភូមិន្ទ<br>- ប្រកាសអន្តរក្រសួងលេខ ១២៩/២០០៧ ប្រក.អន ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០៧ |

ស្តីពីការកំណត់អំពីបែបបទផ្ទេរប្រគល់ការគ្រប់គ្រងចំពោះនិវត្តជន និងជនបាត់បង់សមត្ថភាពការងារ

- ប្រកាសអន្តរក្រសួងលេខ ១៨៧៧ ប្រក. ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការកំណត់បែបបទផ្ទេរ ប្រគល់ការគ្រប់គ្រង និវត្តជន និងជនបាត់បង់សមត្ថភាពការងារ
- សារាចរណែនាំអន្តរក្រសួងលេខ០០១ ស.រ.ណ.ន ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីរបបឧបត្ថម្ភគោលនយោបាយចំពោះមន្ត្រីនគរបាលពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ
- សារាចរណែនាំអន្តរក្រសួងលេខ ០២១ ស.អ.យ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការត្រួតពិនិត្យផ្ទៀងផ្ទាត់អតីតយុទ្ធជនគ្រប់ប្រភេទ និងគ្រួសារ
- ប្រកាសលេខ ៦៧៨ ស.អ.យ. ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីនីតិវិធីអនុវត្តរបបឧបត្ថម្ភគោលនយោបាយចំពោះ ជនពលី មរណៈ ជនពិការ និវត្តជន ជនបាត់បង់សមត្ថភាពការងារ និងគ្រួសារ
- ប្រកាសលេខ ១៥៣ ស.អ.យ. ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៦ ស្តីពីនីតិវិធីកំណត់ប្រាក់ឧបត្ថម្ភមួយលើកដំបូងជូនជនពិការ
- ប្រកាសលេខ ៤៣០ ស.អ.យ. ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៦ ស្តីពីប្រាក់ឧបត្ថម្ភគោលនយោបាយធានារ៉ាប់រងសង្គមសម្រាប់ជនពិការជាអតីតយុទ្ធជន
- សារាចរណែនាំលេខ ០១៧ ស.អ.យ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការកែសម្រួលការកំណត់របបឧបត្ថម្ភ១លើកដំបូងជូនគ្រួសារជនពលី គ្រួសារជនមរណៈ និងជនពិការដែលជាអតីតយុទ្ធជន
- សារាចរណែនាំលេខ ០០៣ ស.អ.យ. ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការដំឡើងប្រាក់របប ១៥% ជូនជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារជាអតីតយុទ្ធជន
- ប្រកាសលេខ ២៨១ ស.អ.យ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់បេឡាជាតិអតីតយុទ្ធជន
- ប្រកាសលេខ ២៨២ ស.អ.យ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពីការបង្កើតរូបសញ្ញានៃបេឡាជាតិអតីតយុទ្ធជន
- សេចក្តីណែនាំលេខ ០០១ ស.អ.យ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការកែសម្រួលប្រាក់របបសន្តិសុខសង្គមជូនអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន
- សេចក្តីសម្រេចលេខ ០១៦ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យបេឡាជាតិអតីតយុទ្ធជនថ្នាក់រាជធានីខេត្ត
- សេចក្តីណែនាំលេខ ១៤៧០ ប.ជ.អ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការគ្រប់គ្រងស្ថិតិអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន
- សេចក្តីណែនាំលេខ ១៦០៣ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការផ្តល់ប្រាក់របបឧបត្ថម្ភប្រចាំខែ ចំពោះអ្នករស់នៅក្នុងបន្ទុករបស់អតីតយុទ្ធជនគ្រប់ប្រភេទ
- សារាចរណែនាំលេខ ០១១ សហវ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការអនុវត្តនីតិវិធី

| | |
|---|---|
| | សម្រាប់ការបើកផ្តល់បៀវត្សរៀងរាល់ពីរសប្តាហ៍ម្តងក្នុងខែនីមួយៗជូនមន្ត្រីរាជការស៊ីវិល និងមន្ត្រីសាធារណៈផ្សេងទៀត |
| អតិថិជនដែលមានសិទ្ធិទទួលសេវា | - អតីតយុទ្ធជនគ្រប់ប្រភេទ និងគ្រួសារអតីតយុទ្ធជនរួមមាន ៖<br>- ជនពលី<br>- ជនមរណៈ<br>- ជនពិការ<br>- និវត្តជន<br>- ជនបាត់បង់សមត្ថភាពការងារ និង<br>- គ្រួសាររបស់អតីតយុទ្ធជន |
| ស្តង់ដារសេវា | ១. និវត្តជនទទួលបាន ៖<br>យោធិន<br>- ប្រាក់ឧបត្ថម្ភគោលនយោបាយចំនួន ៨ខែ ពីអង្គភាពដើម (ក្រសួងសាមី)<br>- ប្រាក់សោធននិវត្តន៍ប្រចាំខែ = ប្រាក់សោធន ពី៥០% ទៅ ៨០% នៃបៀវត្សឋានន្តរសក្តិ + ប្រពន្ធ + កូន + តំបន់(បើមាន) + ប្រាក់អាទិភាព ១៥% ទៅ ២០% នៃបៀវត្សឋានន្តរសក្តិ(បើមាន)<br>- ក្រោយពេលទទួលមរណភាពទទួលបានប្រាក់ធានារ៉ាប់រងសង្គមចំនួន ១២ខែ នៃបៀវត្សឋានន្តរសក្តិ<br>នគរបាលជាតិ<br>- ប្រាក់ឧបត្ថម្ភគោលនយោបាយ ៨ខែ ពីអង្គភាពដើម (ក្រសួងសាមី)<br>- ប្រាក់សោធននិវត្តន៍ប្រចាំខែ = ប្រាក់សោធន ៨០% នៃបៀវត្សឋានន្តរសក្តិ + ២% នៃបៀវត្សឋានន្តរសក្តិ + ប្រពន្ធ + កូន + តំបន់(បើមាន) + ប្រាក់អាទិភាព ១៥% ទៅ ២០% នៃបៀវត្សឋានន្តរសក្តិ(បើមាន)<br>- ក្រោយពេលទទួលមរណភាពទទួលបានប្រាក់ធានារ៉ាប់រងសង្គមចំនួន ១២ខែ នៃបៀវត្សឋានន្តរសក្តិ<br>២. ជនបាត់បង់សមត្ថភាពការងារទទួលបាន ៖<br>យោធិន<br>- ប្រាក់ឧបត្ថម្ភគោលនយោបាយ ៦ខែ ពីអង្គភាពដើម (ក្រសួងសាមី)<br>- ប្រាក់សោធនបាត់បង់សមត្ថភាពការងារប្រចាំខែ ៖<br>○ កម្រិតទី១: ប្រាក់សោធន ១០០% នៃបៀវត្សឋានន្តរសក្តិ + អ្នកបម្រើ(ស្មើពលទោ) + ប្រពន្ធ + កូន + តំបន់(បើមាន)<br>○ កំរិតទី២: ប្រាក់សោធន ពី៥០% ទៅ ៦០% នៃបៀវត្សឋានន្តរសក្តិ + ប្រពន្ធ + កូន + តំបន់(បើមាន)<br>- ក្រោយពេលទទួលមរណភាពទទួលបានប្រាក់ធានារ៉ាប់រងសង្គមចំនួន ១២ខែ នៃបៀវត្ស |

| | |
|---|---|
| | ឋានន្តរសក្តិ<br>នគរបាលជាតិ<br>- ប្រាក់ឧបត្ថម្ភគោលនយោបាយ ៦ខែ ពីអង្គភាពដើម (ក្រសួងសាមី)<br>- ប្រាក់សោធនបាត់បង់សមត្ថភាពការងារប្រចាំខែ ៖<br>○ កម្រិតទី១: ប្រាក់សោធន ៧០% នៃបៀវត្សឋានន្តរសក្តិ + ៥០% នៃបៀវត្សឋានន្តរសក្តិ + ប្រពន្ធ + កូន + តំបន់(បើមាន)<br>○ និងកម្រិតទី២: ប្រាក់សោធន ពី៥០% ទៅ ៦០% នៃបៀវត្សឋានន្តរសក្តិ + ប្រពន្ធ + កូន + តំបន់(បើមាន)<br>- ក្រោយពេលទទួលមរណភាពទទួលបានប្រាក់ធានារ៉ាប់រងសង្គមចំនួន ១២ខែ នៃបៀវត្សឋានន្តរសក្តិ<br>៣. ពិការភាពទទួលបាន ៖<br>- ទទួលបានប្រាក់ឧបត្ថម្ភប្រចាំខែ ៖<br>○ សម្រាប់ជនពិការជាអតីតយោធិន និងនគរបាលជាតិ ៖ ប្រាក់ឧបត្ថម្ភប្រចាំខែ = ប្រាក់បៀវត្សសរុប(បៀវត្សឋានន្តរសក្តិ + ម្ហូប + តំបន់(បើមាន) + កូន + ប្រពន្ធ ឬប្តី) + ប្រាក់ជំនួយមុខរបួស + ប្រាក់បន្ថែមភាគរយ + ប្រាក់អ្នកបម្រើ(បើជាជនពិការថ្នាក់ទី១)<br>○ សម្រាប់ជនពិការជាអតីតមន្ត្រីរាជការស៊ីវិល ៖ ប្រាក់ឧបត្ថម្ភប្រចាំខែ = ប្រាក់បៀវត្សសរុប(បៀវត្សមូលដ្ឋាន + តំបន់(បើមាន) + កូន + ប្រពន្ធ ឬប្តី) + ប្រាក់ជំនួយមុខរបួស + ប្រាក់បន្ថែមភាគរយ + ប្រាក់អ្នកបម្រើ(បើជាជនពិការថ្នាក់ទី១)<br>○ សម្រាប់ជនពិការជាអតីតកងសេនាជន កងជីវពល ពលករ និងប្រជាពលរដ្ឋ ៖ ប្រាក់ឧបត្ថម្ភប្រចាំ = ប្រាក់ជំនួយមុខរបួស + ប្រាក់បន្ថែមភាគរយ + កូន + ប្រពន្ធ + អ្នកបម្រើ(បើជាជនពិការថ្នាក់ទី១)<br>- ក្រោយពេលទទួលមរណភាព ៖<br>○ ជនពិការប្រភេទ ក ជាយោធិន និងមន្ត្រីនគរបាលជាតិ ៖ ត្រូវបន្តបើកប្រាក់ឧបត្ថម្ភប្រចាំខែចំនួន ៣ខែ ជូនគ្រួសារសព ហើយទទួលបានប្រាក់បូជាសពចំនួន ៩ខែ នៃប្រាក់ឧបត្ថម្ភប្រចាំខែចុងក្រោយរបស់សាមីជន និងប្រាក់ឧបត្ថម្ភមួយលើកចំនួន ១៥ខែ នៃបៀវត្សសរុប<br>○ ជនពិការប្រភេទ ក ជាសេនាជន ៖ ត្រូវបន្តបើកប្រាក់ឧបត្ថម្ភប្រចាំខែចំនួន ៣ខែជូនគ្រួសារសព ហើយទទួលបានប្រាក់បូជាសពចំនួន ១.២០០.០០០រៀល ប្រាក់ជូនដំណឹង ជនពលីចំនួន ៣ខែ នៃប្រាក់ស្មើពលទោ និងប្រាក់ឧបត្ថម្ភមួយលើកចំនួន ១២ខែ នៃប្រាក់ស្មើពលទោ<br>○ ជនពិការប្រភេទ ខ ៖ ត្រូវបន្តបើកប្រាក់ឧបត្ថម្ភប្រចាំខែចំនួន ៣ខែជូនគ្រួសារសព ហើយទទួលបានប្រាក់បូជាសពចំនួន ៧ខែ នៃប្រាក់ឧបត្ថម្ភប្រចាំខែចុងក្រោយ |

| | |
|---|---|
| | របស់សាមីជន និងប្រាក់ឧបត្ថម្ភមួយលើកចំនួន ១២ខែ នៃបៀវត្សរ៍សរុប។<br>៤. ជនពលីទទួលបាន ៖<br>- ឪពុកបង្កើត ក្នុង១នាក់ ៨.០០០រៀល ក្នុងមួយខែ<br>- ម្តាយបង្កើត ក្នុង១នាក់ ៨.០០០រៀល ក្នុងមួយខែ<br>- ឬអាណាព្យាបាល ក្នុង១នាក់ ៨.០០០រៀល ក្នុងមួយខែ<br>- ប្រពន្ធ ឬប្តីក្នុង១នាក់ ១៥.០០០រៀល ក្នុងមួយខែ<br>- កូន ក្នុង១នាក់ ១០.០០០រៀល ក្នុងមួយខែ<br>៥. ជនមរណៈទទួលបាន ៖<br>- ឪពុកបង្កើត ក្នុង១នាក់ ៨.០០០រៀល ក្នុងមួយខែ<br>- ម្តាយបង្កើត ក្នុង១នាក់ ៨.០០០រៀល ក្នុងមួយខែ<br>- ឬអាណាព្យាបាល ក្នុង១នាក់ ៨.០០០រៀល ក្នុងមួយខែ<br>- ប្រពន្ធ ឬប្តីក្នុង១នាក់ ១៥.០០០រៀល ក្នុងមួយខែ<br>- កូន ក្នុង១នាក់ ១០.០០០រៀល ក្នុងមួយខែ |
| តម្រូវការឯកសារ<br>ដើម្បីទទួលបានសេវា | **ទទួលស្គាល់អតីតយុទ្ធជនថ្មីដែលផ្ទេរពីក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ និងក្រសួងស្ថាប័នពាក់ព័ន្ធ**<br>- លិខិតផ្ទេរអតីតយុទ្ធជនគ្រប់ប្រភេទ ០២ច្បាប់<br>- ព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាសចេញពីជួរ ០២ច្បាប់<br>- បញ្ជីរាយនាម ០២ច្បាប់<br>- លិខិតទទួលស្គាល់ ០២ច្បាប់<br>- វិញ្ញាបនបត្របញ្ជាក់កម្រិតបាត់បង់សមត្ថភាពការងារ ០២ច្បាប់<br>- លិខិតឧទ្ទេសនាមផ្តត់ផ្គង់ហិរញ្ញវត្ថុ ០២ច្បាប់<br>- ជីវៈប្រវត្តិសង្ខេប ០២ច្បាប់<br>- លិខិតចម្លងព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសចេញពីជួរ ០២ច្បាប់<br>**លុបអតីតយុទ្ធជនគ្រប់ប្រភេទ**<br>- សំណើរបស់ការិយាល័យ ប.ជ.អ រាជធានី ខេត្ត ០២ច្បាប់<br>- តារាងឧបសម្ព័ន្ធ ០២ច្បាប់<br>- លិខិតទទួលស្គាល់ជនពលី ឬជនមរណៈ ០២ច្បាប់<br>- ប្រវត្តិរូបសង្ខេប ០២ច្បាប់<br>- តារាងបញ្ជាក់ប្រាក់ឧបត្ថម្ភប្រចាំខែ ០២ច្បាប់<br>- សេចក្តីចម្លងសំបុត្រមរណភាព ០២ច្បាប់<br>- ប្រកាសទទួលស្គាល់ និងតារាងឧបសម្ព័ន្ធ របស់ក្រសួង ០២ច្បាប់<br>**បញ្ចូលប្រពន្ធ ឬ ប្តី និងកូនរបស់ជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារ**<br>- សំណើរបស់ការិយាល័យ ប.ជ.អ រាជធានី ខេត្ត ០២ច្បាប់<br>- តារាងឧបសម្ព័ន្ធនៃបញ្ជីរាយនាមអតីតយុទ្ធជន និងគ្រួសារ ០២ច្បាប់ |

| | |
|---|---|
| | - សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬសំបុត្រកំណើត ០២ច្បាប់<br>- លិខិតបញ្ជាក់ការសិក្សា ០២ច្បាប់<br>**ផ្ទេរអតីតយុទ្ធជនគ្រប់ប្រភេទពីរាជធានី ខេត្តមួយ ទៅរាជធានី ខេត្តមួយទៀត**<br>- សំណើរបស់ការិយាល័យ ប.ជ.អ រាជធានី ខេត្ត ០២ច្បាប់<br>- តារាងឧបសម្ព័ន្ធ នៃបញ្ជីរាយនាមអតីតយុទ្ធជន ០២ច្បាប់<br>- សៀវភៅបើកប្រាក់ និងសាលាកបត្រ ០២ច្បាប់<br>- សំណុំលិខិតរបស់សាមីខ្លួន ច្បាប់ដើម<br>- ពាក្យស្នើសុំផ្ទេររបស់សាមីខ្លួន ០២ច្បាប់<br>- ប្រកាសទទួលរបស់ក្រសួង ស.អ.យ ០២ច្បាប់<br>**បើកប្រាក់របបសន្តិសុខសង្គម និងប្រាក់ឧបត្ថម្ភផ្សេងៗជូនអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន**<br>- សំណើរបស់ការិយាល័យ ប.ជ.អ រាជធានី ខេត្ត (០២ច្បាប់)<br>- តារាងឧបសម្ព័ន្ធ នៃបញ្ជីរាយនាមរបស់អតីតយុទ្ធជន (២ច្បាប់)<br>- ប្រកាសទទួលស្គាល់ និងផ្តល់របបឧបត្ថម្ភ |
| យោបល់ | |

## ២១. ការផ្តល់សេវាដល់អតីតយុទ្ធជន និងគ្រួសារក្រីក្រនៅតាមសហគមន៍

| | |
|---|---|
| ឈ្មោះសេវា | ការផ្តល់សេវាជួយដល់អតីតយុទ្ធជននៅតាមសហគមន៍ |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា<br>- អគ្គនាយកដ្ឋានបច្ចេកទេស<br>- នាយកដ្ឋានអតីតយុទ្ធជន<br>- ការិយាល័យសម្បទានដីសង្គមកិច្ច និងអភិវឌ្ឍមណ្ឌលអតីតយុទ្ធជន<br>- ទូរស័ព្ទ ៖ ០៩២ ៧០ ៩២ ៩៣<br>- អាសយដ្ឋាន អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ |
| គោលបំណង នៃការផ្តល់សេវា | - យកចិត្តទុកដាក់ជួយអភិវឌ្ឍន៍ជីវភាពគ្រួសារអតីតយុទ្ធជនដែលជួបការលំបាកជាងគេ បង្កឱ្យមានសមត្ថភាព និងលទ្ធភាពប្រកបរបររកស៊ីចិញ្ចឹមជីវិត ដោយថ្លៃថ្នូរសមរម្យ<br>- ការផ្តល់សេវាអតីតយុទ្ធជន និងគ្រួសារក្រីក្រនៅតាមសហគមន៍ ដើម្បីជួយទ្រទ្រង់ជីវភាពរស់នៅបណ្តោះបណ្តាលវិជ្ជាជីវៈ និងលើកគម្រោងនានាក្នុងន័យអភិវឌ្ឍន៍ស្ថានភាពជីវភាពរបស់ពួកគាត់ កសាងសមត្ថភាព ស្តាបនា និងរៀបចំយន្តការសហការរវាងមន្ត្រីសង្គមកិច្ច អាជ្ញាធរមូលដ្ឋាន និងអតីតយុទ្ធជនផ្ទាល់ដើម្បីអនុវត្តគម្រោងនានា |
| មូលដ្ឋានគតិយុត្ត | - អនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- ប្រកាសលេខ ១៨៥៨ ស.អ.យ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យស្ថិតក្រោមនាយកដ្ឋានអតីតយុទ្ធជន<br>- សេចក្តីណែនាំលេខ ០០១ ស.អ.យ ចុះថ្ងៃទី ២៨ ខែមករា ឆ្នាំ២០១៦ ស្តីពីការងារអភិវឌ្ឍន៍អតីតយុទ្ធជននៅសហគមន៍ ឃុំ សង្កាត់ តាមរាជធានី ខេត្ត<br>- ប្រកាសលេខ ៩០២ ស.អ.យ. ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការដាក់ឲ្យប្រើប្រាស់សៀវភៅណែនាំស្តីពីនីតិវិធីប្រមូលទិន្នន័យពីស្ថានភាពជីវភាព និងតម្រូវការរបស់អតីតយុទ្ធជន និងគ្រួសារ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការអភិវឌ្ឍន៍សហគមន៍អតីតយុទ្ធជន ឃុំ សង្កាត់ តាមរាជធានី ខេត្ត ៖<br>• សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការអភិវឌ្ឍន៍សហគមន៍អតីតយុទ្ធជន ខេត្តស្វាយរៀង ចំនួន ៨០ ឃុំ-សង្កាត់<br>• សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការអភិវឌ្ឍន៍សហគមន៍អតីតយុទ្ធជន ខេត្តមណ្ឌលគីរី ចំនួន ២១ ឃុំ-សង្កាត់<br>• សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការអភិវឌ្ឍន៍សហគមន៍អតីតយុទ្ធជន ខេត្តកែប ចំនួន ០៥ ឃុំ-សង្កាត់ |

| | |
|---|---|
| | • សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការអភិវឌ្ឍន៍សហគមន៍អតីតយុទ្ធជន ខេត្តឧត្តរមានជ័យ ចំនួន ២៤ ឃុំ-សង្កាត់<br>• សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការអភិវឌ្ឍន៍សហគមន៍អតីតយុទ្ធជន ខេត្តត្បូងឃ្មុំ ចំនួន ៥៦ ឃុំ-សង្កាត់<br>• សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការអភិវឌ្ឍន៍សហគមន៍អតីតយុទ្ធជន ខេត្ត កណ្តាល ចំនួន ១២៧ ឃុំ-សង្កាត់<br>• សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការអភិវឌ្ឍន៍សហគមន៍អតីតយុទ្ធជន ខេត្តកំពង់ចាម ចំនួន ១០៨ ឃុំ-សង្កាត់<br>• សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការអភិវឌ្ឍន៍សហគមន៍អតីតយុទ្ធជន ខេត្តបន្ទាយមានជ័យ ចំនួន ៦៥ ឃុំ-សង្កាត់<br>• សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការអភិវឌ្ឍន៍សហគមន៍អតីតយុទ្ធជន ខេត្តរតនគិរី ចំនួន ០៩ ឃុំ-សង្កាត់<br>• សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការអភិវឌ្ឍន៍សហគមន៍អតីតយុទ្ធជន ខេត្តព្រះវិហារ ចំនួន ៥១ ឃុំ-សង្កាត់<br>• សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការអភិវឌ្ឍន៍សហគមន៍អតីតយុទ្ធជន ខេត្តព្រៃវែង ចំនួន ១១៦ ឃុំ-សង្កាត់<br>• សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការអភិវឌ្ឍន៍សហគមន៍អតីតយុទ្ធជន ខេត្តកោះកុង ចំនួន ២៩ ឃុំ-សង្កាត់<br>• សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការអភិវឌ្ឍន៍សហគមន៍អតីតយុទ្ធជន ខេត្តកំពត ចំនួន ៩៣ ឃុំ-សង្កាត់<br>• សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការអភិវឌ្ឍន៍សហគមន៍អតីតយុទ្ធជន ខេត្តកំពង់ឆ្នាំង ចំនួន ៦៩ ឃុំ-សង្កាត់<br>• សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការអភិវឌ្ឍន៍សហគមន៍អតីតយុទ្ធជន ខេត្តពោធិ៍សាត់ ចំនួន ៤៨ ឃុំ-សង្កាត់<br>• សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការអភិវឌ្ឍន៍សហគមន៍អតីតយុទ្ធជន ខេត្តកំពង់ស្ពឺ ចំនួន ៨៧ ឃុំ-សង្កាត់<br>• សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការអភិវឌ្ឍន៍សហគមន៍អតីតយុទ្ធជន ខេត្តប៉ៃលិន ចំនួន ០៨ ឃុំ-សង្កាត់<br>• សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការអភិវឌ្ឍន៍សហគមន៍អតីតយុទ្ធជន ខេត្តព្រះសីហនុ ចំនួន ២៧ ឃុំ-សង្កាត់ |
| អតិថិជនដែលមានសិទ្ធិទទួលសេវា | អតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន ដែលក្រីក្រនៅតាមសហគមន៍ |
| ស្តង់ដារសេវា | អតីតយុទ្ធជនអាចទទួលបានផ្ទះមួយខ្នងតម្លៃប្រមាណ ៨.០០០ដុល្លារអាមេរិក |

| | |
|---|---|
| តម្រូវការឯកសារដើម្បីទទួលបានសេវា | - ពាក្យស្នើសុំមានបិតរូបថត ៤x៦ ចំនួន ៣ច្បាប់<br>- សំណើរបស់ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- ប័ណ្ណសមធម៌ |
| យោបល់ | |

# ២២. ការអប់រំ និងបណ្តុះបណ្តាលកម្រិតឧត្តមសិក្សា

| | |
|---|---|
| ឈ្មោះសេវា | ការអប់រំ និងបណ្តុះបណ្តាលកម្រិតឧត្តមសិក្សា |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**<br>វិទ្យាស្ថានជាតិសង្គមកិច្ច<br>- អាសយដ្ឋាន៖ អគារលេខ២០B វិថីឌួងងៀប២ ភូមិដំណាក់៣ សង្កាត់ស្ទឹងមានជ័យ ៣ ខណ្ឌមានជ័យ រាជធានីភ្នំពេញ<br>- ទូរស័ព្ទ៖ ០៨៩ ៣៨៤ ៣០៩ / ០១២ ៨៦២ ៩១១<br>- ទូរសារអេឡិចត្រូនិច (E-Mail)៖ nisa@nisa-edu.gov.kh<br>- វេបសាយ (website)៖ www.nisa-edu.gov.kh |
| គោលបំណង នៃការផ្តល់សេវា | ដើម្បីបង្កើនធនធានមនុស្សលើវិស័យសង្គមកិច្ច សម្រាប់ស្ថាប័នរដ្ឋ អង្គការ និងឯកជន ដោយផ្សារភ្ជាប់ទៅនឹងតម្រូវការប្រទេសជាតិ និងសង្គម ឆ្លើយតបទៅនឹងទីផ្សារការងារ និងមុខរបរ ។ |
| មូលដ្ឋានគតិយុត្ត | - អនុក្រឹត្យលេខ ២៣៣ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ ស្តីការបង្កើតវិទ្យាស្ថានជាតិសង្គមកិច្ច<br>- ប្រកាសលេខ ៧២៥ ស.អ.យ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់វិទ្យាស្ថានជាតិសង្គមកិច្ច<br>- ប្រកាសលេខ ៤២៧ ស.អ.យ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការបង្កើតដេប៉ាតឺម៉ង់គោលនយោបាយនិងអភិបាលកិច្ច និងដេប៉ាតឺម៉ង់ភាសាអង់គ្លេស<br>- សេចក្តីសម្រេចលេខ ២៨ អយក.សសរ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការបង្កើតដេប៉ាតឺម៉ង់ និងមុខជំនាញនៅវិទ្យាស្ថានជាតិសង្គមកិច្ច ។ |
| អតិថិជនដែលមាន សិទ្ធទទួលសេវា | - សិស្ស-និស្សិតដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (ផ្តល់អាទិភាពចំពោះសិស្ស-និស្សិត ក្រីក្រ និងពិការ) |
| ស្តង់ដាសេវា | - អនុវត្តតាមស្តង់ដាជាតិសម្រាប់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា<br>- ជំនាញបណ្តុះបណ្តាលមាន ៖<br>• បរិញ្ញាបត្រសង្គមកិច្ចវិទ្យា<br>• បរិញ្ញាបត្រសង្គមវិទ្យា<br>• បរិញ្ញាបត្រកិច្ចគាំពារសង្គម<br>• បរិញ្ញាបត្រអង់គ្លេស<br>• បរិញ្ញាបត្ររដ្ឋបាលសាធារណៈ<br>• បរិញ្ញាបត្រគ្រប់គ្រងសាធារណៈ<br>• បរិញ្ញាបត្រគោលនយោបាយសង្គម<br>• បរិញ្ញាបត្រគោលនយោបាយសាធារណៈ |

| | |
|---|---|
| | • បរិញ្ញាបត្រវិស្វកម្មឧបករណ៍សិប្បនិម្មិត និងរណប |
| តម្រូវការឯកសារ ដើម្បីទទួលបានសេវា | ពាក្យសុំចូលរៀនដោយភ្ជាប់មកជាមួយនូវៈ<br>- ប្រវត្តិរូបសង្ខេប (បិតរូបថត ៤X៦)<br>- រូបថត(៤X៦) ចំនួន ០២សន្លឹក<br>- សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្របណ្ដោះអាសន្ន ឬសញ្ញាបត្រមានតម្លៃស្មើ<br>- លិខិតបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន (ចំពោះតែនិស្សិតក្រីក្រ និងពិការ) ។ |
| យោបល់ | |

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ
ទូរស័ព្ទ ទូរសារ ៖ (៨៥៥) ២៣ ៧២ ៦០ ៨៦
គេហទំព័រ .www.mosvy.gov.kh